# ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០២០

## កិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារឆ្នាំ២០១៩ និងលើកទិសដៅបន្តរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://grandnewsasia.com/ 31/12/2019 ម៉ោង 14:53 pm

កំពង់ឆ្នាំង ៖ នៅរសៀលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកំពង់ឆ្នាំង ប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារឆ្នាំ២០១៩និងលើកទិសដៅសម្រាប់អនុវត្តបន្តនៅឆ្នាំ២០២០។ កិច្ចប្រជុំនេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោក ឈួរ ច័ន្ទឌឿន អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ឆ្នាំង និងមានការអញ្ជើញចូលរួមពីលោកស្រី ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ ព្រមទាំងថ្នាក់ដឹកនាំមន្ទីរ អង្គភាព កងកម្លាំងទាំងបី ថ្នាក់ដឹកនាំក្រុង ស្រុក ជាសមាជិកគណៈកម្មាធិការ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត។

លោកអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការ បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សមត្ថកិច្ច មន្ទីរជំនាញ និងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ក្នុងការអប់រំផ្សព្វផ្សាយ បង្ការ បង្ក្រាប ដើម្បីទប់ស្កាត់អំពើជួយដូរមនុស្សនៅទូទាំងខេត្ត យ៉ាងមាន ប្រសិទ្ធភាព។ ក្នុងឱកាសនោះដែរ លោក ក៏បានផ្តាំផ្ញើដល់គណៈកម្មាធិការក៏ដូចជាលេខាធិការដ្ឋាន សូមបន្តខិតខំអនុវត្តឲ្យបានជោគជ័យនូវផែនការការងារដែលបានដាក់ចេញសម្រាប់អនុវត្តក្នុងឆ្នាំ២០២០ និងទិសដៅការងារដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ សំដៅលុបបំបាត់ឲ្យបានអំពើជួញដូរមនុស្សគ្រប់រូបភាព៕

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានបើកកិច្ចប្រជុំប្រចាំឆ្នាំ ២០១៩ និងទិសដៅបន្តឆ្នាំ២០២០

https://www.facebook.com/deputygovernoryousophear/ 02-01-2020

ខេត្តសៀមរាប៖ ព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) បានបើកកិច្ចប្រជុំប្រចាំឆ្នាំ២០១៩ ក្រោមអធិបតីភាព លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមពី ស្នងការរងនគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត តំណាងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត គណៈអភិបាលក្រុង-ស្រុក និងតំណាងអង្គការដៃគូជាតិ-អន្តរជាតិ សរុប៥៤នាក់ ក្នុងនោះស្រី ៣៥នាក់ បន្ទប់ប្រជុំរដ្ឋបាលសាលាខេត្តសៀមរាប។ កិច្ចប្រជុំបានដំណើរការតាមរបៀបវារៈរួមមាន៖

កិច្ចប្រជុំបានធ្វើការពិភាក្សាលើបញ្ហាប្រឈមសំខាន់ៗ ពាក់ព័ន្ធនឹងការអន្តរាគមន៍ជួយជនរងគ្រោះ ការអនុវត្តច្បាប់ ការពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីក្រុមការងារប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស ការផ្តល់សេវាជួយជនរគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ របស់មន្ទីរជំនាញ អង្គការដៃគូពាក់ព័ន្ធ។ បន្ថែមពីនោះ លោកស្រីប្រធានអង្គប្រជុំបានស្នើ និងជំរុញដល់អ្នកចូលរួមទាំងអស់បន្តកិច្ចសហការលើការអនុវត្តសកម្មភាព និងត្រូវពិនិត្យឡើងវិញនូវចំណុចខ្វះខាតនានាពេលអនុវត្តកន្លងមក ពិសេសការអនុវត្តសកម្មភាពឲ្យឆ្លើយតបទៅនឹងបញ្ហាជាក់ស្តែង និងគោរពក្រមសីលធម៌វិជ្ជាជីវៈក្នុងនាមជាអ្នកផ្តល់សេវាជូនប្រជាពលរដ្ឋ។ លើសពីនោះទៅទៀត លោកស្រី បានជំរុញឲ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់រៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ ២០២០ និងពង្រឹងទៅការរៀបចំកិច្ចប្រជុំតាម ក្រុង-ស្រុក និងឃុំ-សង្កាត់ លើការងារបង្ការទប់ស្កាត់ ការជួយជនរង

គ្រោះ និងបង្កើនការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព (ការឯកសារត្រឹមត្រូវតាមច្បាប់កំណត់) ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឱកាសការងារក្នុងស្រុក ឲ្យបានទូលំទូលាយ។

នៅក្នុងឆ្នាំ២០២០ខាងមុខនេះ លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធ កិច្ចប្រជុំយុត្តិធម៌ព្រហ្មទណ្ឌ កិច្ចប្រជុំយុត្តិធម៌អនីតិជន ការប្រជុំផ្សព្វផ្សាយជាសាធារណៈជាមួយប្រជាពលរដ្ឋ សិស្សានុសិស្ស គ្រប់និកាយ សាសនា នៅក្នុងខេត្ត ទៅតាមផែនការដែលបានរៀបចំ និងស្នើសុំឲ្យមានកិច្ចសហការពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ទាំងផ្នែកបច្ចេកទេស និងធនធាន។

# ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០២០

## ក្រុមហ៊ុនបោក! ក្រុមហ៊ុននាំពលករទៅប្រទេសកូរ៉េ ម្នាក់ៗអស់រាប់ពាន់ដុល្លារ វើផ្ទះ គេចខ្លួនបាត់

https://kbn.news/ January 2, 2020

**ភ្នំពេញ៖** យុវជនមួយក្រុម ដែលចាញ់បោកក្រុមហ៊ុន JLY ជ្រើសរើសពលករទៅបម្រើការងារនៅប្រទេសកូរ៉េម្នាក់ៗអស់រាប់ពាន់ដុល្លារ មិនដឹងប្រធានក្រុមហ៊ុនវេចលុយវើផ្ទះ គេចខ្លួនបាត់ទៅដល់ណា នាំគ្នាផ្អើល រត់មករកសុំអន្តរាគមន៍ពីសមត្ថកិច្ចផ្នែកព្រហ្មទណ្ឌ អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នាព្រឹកថ្ងៃទី០២ ខែមករា ឆ្នាំ២០២០នេះ ។

បុរសរងគ្រោះម្នាក់ ក្នុងចំណោមជនរងគ្រោះចាញ់បោកក្រុមហ៊ុនចំនួន៣០នាក់ ឈ្មោះ ជួប ជួន អាយុ២៨ឆ្នាំ រស់នៅភូមិឆ្កែកូន ឃុំគោកឃ្មុំ ស្រុកថ្មគោល ខេត្តបាត់ដំបង បានឲ្យដឹងថា ពួកគាត់មានគ្នាប្រមាណ៣០នាក់ រស់នៅខេត្តផ្សេងៗគ្នា កាលពីអំឡុងតែតុលា ឆ្នាំ២០១៨ ពួកគាត់នាំគ្នាទៅដាក់ពាក្យបង់លុយនៅក្រុមហ៊ុនJLY ជ្រើសរើសពលករទៅបម្រើការងារនៅប្រទេសកូរ៉េ ដែលមានទីតាំងស្ថិតនៅភូមិក្បាលដំរី២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ ម្នាក់ៗអស់៣ពាន់ដុល្លារ ដោយខាងក្រុមហ៊ុន ចេញឯកសារវិក័យប័ត្រ ត្រឹមត្រូវ រួចឲ្យត្រឡប់ទៅផ្ទះវិញ ដើម្បីរង់ចាំថ្ងៃចាកចេញទៅធ្វើការនៅប្រទេសកូរ៉េ នៅពេលដ៏ខ្លីខាងមុខ ។

ក៏ប៉ុន្តែការទន្ទឹងរង់ចាំ បានអូសបន្លាយពីមួយខែទៅមួយខែ អស់រយៈពេលច្រើនខែទៅហើយ រហូតមកដល់ឆ្នាំថ្មី ២០២០ ស្រាប់តែពួកគាត់ទំនាក់ទំនងទៅខាងក្រុមហ៊ុនមិនបាន ទើបនាំគ្នាផ្អើលឆោឡោ មកដល់ស្នាក់ការក្រុមហ៊ុន JLY មិនដឹងប្រធានក្រុមហ៊ុនវេចលុយវើផ្ទះ គេចខ្លួនបាត់ទៅដល់ណា ក៏នាំគ្នារត់មករកសមត្ថកិច្ចផ្នែកព្រហ្មទណ្ឌ អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ឲ្យជួយអន្តរាគមន៍តែម្តងទៅ ។ ក្រុមហ៊ុនជ្រើសរើសពលករទៅបម្រើការងារនៅប្រទេសកូរ៉េ ឈ្មោះ JLYនេះ មានប្រជាពលរដ្ឋរងគ្រោះ នាំគ្នាមកតវ៉ា២លើកមកហើយ ហើយនេះជាលើកទី៣ហើយដែលក្រុមហ៊ុនបោកប្រាស វេចលុយរត់បាត់ ទុកឲ្យប្រជាពលរដ្ឋជាអ្នកចាញ់បោក ម្នាក់ៗលក់ដីស្រែចម្ការ ចងការគេ អស់ម្នាក់រាប់ពាន់ដុល្លារ យំមិនចេញ ៕

## សេចក្តីជូនដំណឹងស្តីពីពលករទំនាក់ទំនងមិនបាន

https://www.facebook.com/mtosbcambodia/ MTOSB Cambodia 03-01-2020

គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស សូមជូនដំណឹងដល់ពលករ ដែលមានឈ្មោះ ខន សល់ (KHORN SOL) ភេទ ប្រុស អាសយដ្ឋាន ភូមិអន្លង់កួប ឃុំរបស់មង្គល ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ សូមប្រញាប់ទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ឱ្យបានមុនថ្ងៃសុក្រ ទី០៩ ខែមករា ឆ្នាំ២០២០ ម៉ោង០៣:០០នាទីល្ងាច ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣ ៦៥២៥៧៧៧, ០៨៨ ៣៥៩៨ ៨៨៨ និង ០១២ ៤៦៦ ២២២ នៅរៀងរាល់ម៉ោងធ្វើការ។

* បញ្ជាក់៖ គណៈកម្មាធិការបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបរទេស មិនអាចទំនាក់ទំនង តាមរយៈលេខទូរស័ព្ទរបស់គាត់ និងគ្រួសាររបស់គាត់បានទៀយ។ អាស្រ័យហេតុនេះ សូមបងប្អូន និងសាធារណជនមេត្តាជួយផ្សព្វផ្សាយបន្ត។ សូមអរគុណ!

## រថយន្តបុករថយន្តធ្វើឲ្យពលករខ្មែរប្រុសស្រី៧នាក់រងរបួសធ្ងន់ ស្រាលនៅថ្ងៃឆ្លងឆ្នាំសកល

http://nokorwatnews.com/ 02-01-2020

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរប្រុស ស្រី៧នាក់ រងរបួសធ្ងន់ស្រាល ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ នៅក្នុងថ្ងៃចូលឆ្នាំសកលនៅខេត្តរ៉ាក់យ៉ង កាលពីវេលាម៉ោង ០៣ និង១៥នាទី រសៀល ថ្ងៃច័ន្ទ ទី០១ ខែមករា ឆ្នាំ ២០២០ ចំណុចផ្លូវជាតិលេខ១៣ ទល់មុខរោងចក្រសៃកូ ស្ថិតនៅសង្កាត់នីគមផាត់ណា ស្រុកនីគមផាត់ណា ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ។

ប្រភពពីសមត្ថកិច្ចថៃ អះអាងថា ជនរងគ្រោះ មានពលករខ្មែរ ចំនួន ០៧នាក់ និងជនជាតិថៃ ០១នាក់ ក្នុងនោះមានស្ត្រី ០៥នាក់ ប្រុស ០៣នាក់ ។ ប្រភពសមត្ថកិច្ចថៃប្រាប់ថា នៅថ្ងៃកើតហេតុជនរងគ្រោះនាំគ្នាធ្វើដំណើរទៅកំសាន្តនៅថ្ងៃឈប់សម្រាក ក្នុងឱកាសបុណ្យចូលឆ្នាំសកល ប៉ុន្តែអកុសលបានធ្វើដំណើរមកដល់ចំណុចកើតហេតុត្រូវរថយន្តមួយគ្រឿងទៀតម៉ាក Ford Ranger មកបុកគូទពីក្រោយបណ្ដាយឲ្យពលករដែលជិះផ្នែកខាងក្រោយរថយន្តរងរបួសតែម្ដង។ ក្រោយពេលកើតហេតុ ជនរងគ្រោះត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យនីគមផាត់ណា ខេត្តរ៉ាក់យ៉ង ។

បច្ចុប្បន្នជនរងគ្រោះដែលជាពលករខ្មែរ បានចេញពីមន្ទីរពេទ្យមួយចំនួនហើយ នៅសល់តែស្ត្រី ឈ្មោះ ឌុក សឿន អាយុ ៣៦ឆ្នាំ ស្រុកកំណើតរស់នៅខេត្តកំពត កំពុងព្យាបាលបន្តនៅមន្ទីរពេទ្យ ព្រោះទើបតែដឹងខ្លួន ។ ចំពោះហេតុការណ៍ដែលបង្កឲ្យកើតគ្រោះថ្នាក់ចរាចរណ៍ និងមនុស្សរងរបួសជាច្រើននាក់លើកនេះ សមត្ថកិច្ចថៃកំពុងរង់ចាំម្ចាស់រថយន្តទាំងពីរចូលមកដោះស្រាយតាមនីតិវិធីផ្លូវច្បាប់។ ប្រភពព័ត៌មាន៖បានឲ្យដឹងថា ជនរងគ្រោះទាំងអស់ជាពលករខ្មែរធ្វើការនៅក្នុងរោងចក្រខ្ទិះដូង ស្ថិតនៅក្នុងខេត្តឈុនបុរី ។ ជនរងគ្រោះមានស្រុកកំណើតរស់នៅខេត្តប៉ៃលិន,ខេត្តព្រៃវែង ,ខេត្តកំពត ៕ វណ្ណា

# ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២០

## នៅប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ពីសមត្ថកិច្ចថៃ ចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 03-01-2020

នៅប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៨និង៣០នាទី ថ្ងៃទី០៣ ខែមករា ឆ្នាំ ២០២០ បានទទួលពលករខ្មែរឆ្លងដែន ខុសច្បាប់ពីសមត្ថកិច្ចថៃ ចំនួន ០៣នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

# ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ
# ពីសមត្ថកិច្ចថៃបញ្ជូនមកចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 04-01-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នារសៀលថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ បានទទួលពលករខ្មែរដែលសមត្ថកិច្ចថៃបញ្ជូនមកចំនួន ០៣នាក់ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង០៣នាក់នេះ មកពីខេត្តបាត់ដំបង០១នាក់, ខេត្តបន្ទាយមានជ័យ០១នាក់ និងខេត្តសៀមរាប ០១នាក់៕

# ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០២០

## ស៊ើបអង្កេតការជួញដូរ មនុស្សតាមឌីជីថល និង ធនាគារ ជួយពន្លឿនក្នុងការចាប់ខ្លួនជនល្មើស

https://m.postkhmer.com/ គុង សុប្រាជ្ញ 07 January 2020 | 14:40 ICT

កាលពីថ្ងៃទី ១២ ខែធ្នូកន្លងទៅ រាជរដ្ឋាភិបាលបានប្រារព្ធពិធីទិវាជាតិប្រឆាំងអំពើជួញដូរមនុស្សលើកទី ១៣ ដើម្បីបង្កើនយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សគ្រប់ប្រភេទតាមរយៈការអំពាវនាវឲ្យមានការសហការគ្នាជាមួយប្រទេសជាមិត្ត ដែលសកម្មភាពនេះនៅតែកើតមានឡើងដូចជាការស្វែងរកការងារការរៀបអាពាហ៍ពិពាហ៍ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ និងការជួញដូរទារកជាដើម និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ឆ្នាំ ២០១៩-២០២៣។

កាលពីឆ្នាំ ២០១៧ រដ្ឋាភិបាលបានជួយធ្វើមាតុភូមិនិវត្តន៍ ជនរងគ្រោះកម្ពុជាពីបរទេសចំនួន ៩៩០ នាក់ ដែលភាគច្រើនមកពីថៃ ម៉ាឡេស៊ី ចិន និងវៀតណាម។ រីឯការបង្ក្រាបវិញនៅឆមាសទី ១ ដើមឆ្នាំ ២០១៩ របាយការណ៍ប៉ូលិសថា ការបង្ក្រាបសរុបបាន ៨០ ករណីចំពោះសកម្មភាពការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងសង្គ្រោះជនរងគ្រោះ។ បើមើលទៅលើរបាយការណ៍អំពើជួញដូរមនុស្សឆ្នាំ ២០១៨ ក្រសួងការបរទេសអាមេរិកនៅតែរក្សាកម្រិត ២ ឬ Tier 2 Watch list ដដែលសម្រាប់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ ផ្អែកតាមរបាយការណ៍កិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនេះ គឺដោយសារតែកម្ពុជាមានឆន្ទៈ និងខិតខំក្នុងអនុវត្តច្បាប់ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាមិត្តតែកម្ពុជានៅមានការខ្វះខាតផ្នែកបច្ចេកទេសក្នុងប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ និងប្រព័ន្ធធនាគារនៅឡើយ? ដោយការវិវត្តសកម្មភាពរបស់ជនល្មើសជួញដូរមនុស្សនៅលើពិភពលោកនេះមានការធ្វើបច្ចុប្បន្នភាព និងទំនើបកម្មទៅតាមសម័យបច្ចេកវិទ្យាឌីជីថល (Digital) និងការផ្ទេរសាច់ប្រាក់ទៅតាមប្រព័ន្ធធនាគារ និងការដកសាច់ប្រាក់តាមទូ ATM ផងដែរ។

កាលពីឆ្នាំទៅ ខ្ញុំបានចូលរួមសន្និសីទភាពជឿជាក់ (Trust Conference) ដែលរៀបចំដោយទីភ្នាក់ងារសារព័ត៌មាន Thomson Reuters Foundation នៅទីក្រុងឡុងដ៍ចក្រភពអង់គ្លេស ស្តីពីការជួញដូរមនុស្ស និងការធ្វើការងារហួសកម្លាំងនៅសម័យទំនើបត្រូវបានគេលើកឡើង ពីប្រធានបទការបង្ក្រាបអំពើជួញដូរមនុស្សតាមឌីជីថល និងប្រព័ន្ធធនាគារមកពិភាក្សាគ្នា និងការផ្តល់អនុសាសន៍ឲ្យរដ្ឋនីមួយៗបង្កើនប្រព័ន្ធទំនាក់ទំនងឲ្យបានប្រសើរឡើង ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរនេះ។ វាគ្មិនដែលជាមន្ត្រីជាន់ខ្ពស់មកពីទីស្នាក់ការកណ្តាលធនាគារ Standard Chartered បានប្រាប់ខ្ញុំថា៖ «ប្រសិនបើអ្នកដឹងពីជនល្មើសជួញដូរមនុស្សតាមរយៈធនាគារដែលជាដៃគូនឹងធនាគាររបស់ Standard Chartered សូមប្រាប់មកខ្ញុំ។ ខ្ញុំនឹងជួយស្វែងរកជនល្មើសនោះតាមប្រព័ន្ធធនាគារ»។

តាមរយៈបទយកការណ៍បែបស៊ើបអង្កេតរបស់សារព័ត៌មាន The Economist កាលពីខែមីនា ឆ្នាំ ២០១៨ ដែលមានរយៈពេល ៣០ នាទីនៅលើ YouTube ក្រោមប្រធានបទ៖ «How can banks be used to stop

human trafficking?» តើធនាគារអាចបញ្ឈប់អំពើជួញដូរមនុស្សយ៉ាងដូចម្តេច? នៅក្នុងឯកសារនេះបានបង្ហាញពីរបៀបស៊ើបអង្កេតខ្លះៗតាមរយៈបច្ចេកវិទ្យាឌីជីថលរបស់ប្រព័ន្ធធនាគារ ដើម្បីតាមចាប់ឧក្រិដ្ឋជនតាមការផ្ទេរលុយតាមធនាគារ ការបង្ហាញផែនទី និងទីតាំងដកលុយចេញពីទូ ATM។ មួយផ្នែកទៀតគឺសមត្ថកិច្ចប្រើបច្ចេកវិទ្យាស៊ើបអង្កេតតាមអនឡាញ ដើម្បីរកទីតាំងផ្សព្វផ្សាយសេវាផ្លូវភេទ និងកន្លែងដែលកេងប្រវ័ញ្ចពលកម្ម។ នៅក្នុងឯកសារនេះក៏បង្ហាញពីបទពិសោធល្អនៅប្រទេសកាណាដា ស្តីពីការធ្វើយុទ្ធនាការស៊ើបអង្កេតតាមឌីជីថល និងធនាគារឃើញថា ការបង្រ្កាបទៅលើអំពើជួញដូរមនុស្ស និងផ្លូវភេទមានកើនឡើងដល់ទៅ ៣៥០ ភាគរយនៅឆ្នាំ ២០១៧ បើប្រៀបធៀបជាមួយនឹងឆ្នាំ ២០១៦។ ឧទាហរណ៍ដូចករណីជួញដូរមនុស្សតាមរយៈការពពោះជំនួស សមត្ថកិច្ចបានចាប់ខ្លួនអ្នកស្រី Tammy Davis-Charles ជនជាតិអូស្រ្តាលីពីបទជួញដូរមនុស្ស ហើយបានកាត់ទោសឲ្យជាប់គុករយៈពេល ១៨ ឆ្នាំ ហើយអ្នកស្រីត្រូវបានដោះលែងឲ្យមានសេរីភាពកាលពីឆ្នាំទៅរួចហើយ និងអ្នករត់ការឲ្យគាត់ក៏ជាប់ដែរ។

តែករណីនេះសមត្ថកិច្ចអាចឆែកមើលតាមប្រព័ន្ធទំនាក់ទំនងឌីជីថល និងប្រព័ន្ធធនាគារគឺរកឃើញអ្នកពាក់ព័ន្ធបណ្តាញទាំងអស់ ជាពិសេសឪពុកម្តាយរបស់ទារកដែលជាជនបរទេសនៅបរទេស និងស្រ្តីដែលជាជនជាតិខ្មែរពពោះជំនួសគឺឃើញទាំងអស់ ពីព្រោះគាត់បានផ្ទេរលុយទៅស្ត្រីទាំងអស់តាមរយៈធនាគារ និងទទួលសាច់ប្រាក់ពីឪពុកម្តាយតាមធនាគារអន្តរជាតិ។ ក្រៅពីនេះគឺអាចដឹងថា នរណាជាឪពុកម្តាយជាមួយអ្នកពពោះឲ្យនរណាទាំងអស់គឺជាភ័ស្តុតាងក្នុងការស៊ើបអង្កេត និងឃាត់ខ្លួនបានទាំងអស់ និងសហការជាមួយប្រទេសដែលជនល្មើសប្រព្រឹត្ត ដើម្បីធ្វើបត្យាប័នអនុវត្តតាមច្បាប់បាន។

កន្លងមកប្រព័ន្ធធនាគារធ្វើកិច្ចការពង្រឹងប្រព័ន្ធតាមដាន និងស៊ើបអង្កេត ការលាងលុយកខ្វក់បានល្អច្រើន រីឯសមត្ថកិច្ចសព្វថ្ងៃធ្វើទៅតាមការរាយការណ៍តៗគ្នា ជួនកាលទៅរកទីតាំងមិនឃើញច្បាស់លាស់នោះទេធ្វើឲ្យខាតពេលវេលាច្រើន ជួនកាលយឺតពេក ជនល្មើសដឹងខ្លួនមុនរត់បាត់ក៏មានដែរ។ ម្យ៉ាងទៀតការប្រើប្រព័ន្ធ App និងប្រព័ន្ធ Alert ក៏អាចជួយផ្តល់ព័ត៌មានការតាមដានស៊ើបអង្កេត និងបញ្ជាក់ទីតាំងនៅតាមផែនទីបាន។

កន្លងមកអង្គការ InSTEDD បានផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីអង្គការមិនមែនរដ្ឋាភិបាលទប់ស្កាត់ការជួញដូរមនុស្សមួយចំនួននៅភ្នំពេញផងដែរ ស្តីអំពីប្រព័ន្ធ Alert ជាសំឡេងនៅក្នុងទូរស័ព្ទក្នុងករណីមានការជួញដូរមនុស្សនេះ។ ដូចគ្នានេះដែរក្រុមស្ម័គ្រចិត្តសម្អាតបរិស្ថាន Go Green បានសហការគ្នាជាមួយអង្គការ InSTEDD តាមរយៈគម្រោង SPIDER បានចូលរួមជួយសាលារាជធានីភ្នំពេញតាមរយៈឌីជីថល App Go Green ដើម្បីបញ្ជាក់ដៅទីតាំងនៅលើផែនទីរាជធានីភ្នំពេញ ដែលមានសំរាមដើម្បីគេទៅសម្អាតសំរាមនោះ។ អ៊ីចឹងបើដូចគ្នាគឺគ្រាន់តែបង្កើតឲ្យមានឌីជីថល App សម្រាប់កំណត់ទីតាំងរបស់ជនល្មើស ឬក៏ជនរងគ្រោះដោយសារការជួញដូរមនុស្ស ឬក៏ផ្លូវភេទ គឺមានភាពងាយស្រួលដល់សមត្ថកិច្ច គ្រាន់តែមើលតាមដានតាម App នេះហើយអន្តរាគមន៍ទាន់ពេលវេលាគឺមានការចូលរួមពីប្រជាពលរដ្ឋដែលដឹងអំពីសកម្មភាពរបស់ពួកគេគឺគ្រាន់តែចុចសញ្ញា «Pin»នៅទីតាំងកើតហេតុ។

សរុបមកវិញការពង្រឹងការស៊ើបអង្កេតតាមឌីជីថល និងតាមប្រព័ន្ធធនាគារ ដែលមានលក្ខណៈវិទ្យាសាស្រ្តលឿនអាចជួយសមត្ថកិច្ចឈានដល់ការចាប់ខ្លួនជនល្មើស និងបណ្តាញបទល្មើសជួញដូរមនុស្សនេះបានទាន់ពេលវេលា។ ហេតុដូច្នេះហើយ រាជរដ្ឋាភិបាលគួរតែបន្ថែមយុទ្ធសាស្រ្តថ្មីៗតាមបែបបច្ចេកវិទ្យាឌីជីថល និងការសហការជាមួយធនាគារទាំងជាតិ និងទាំងអន្តរជាតិជួយស៊ើបអង្កេតអំពើជួញដូរមនុស្ស និងផ្លូវភេទនេះកាន់តែលឿន៕

## ខ្សែជីវិតអ្នកស្រី រុន រំដួល ដែលប្រថុយឆ្លងដែនខុសច្បាប់ទៅថៃ ដើម្បីរកការងារធ្វើ

https://thmeythmey.com/ 04, Jan 2020 , 6:59 pm ដោយ: ប៉ូ សាគុន

ឧត្តរមានជ័យ៖ បើទោះបីជាដឹងថា ការលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ប្រឈមនឹងបញ្ហាច្រើន ដែលអាចត្រូវមេខ្យល់បោកប្រាស់ ឬថៅកែរំលោភសិទ្ធិ ដោយមិនបើកប្រាក់ខែឱ្យ ឬអាចត្រូវគ្រោះថ្នាក់ដល់ស្លាប់ខ្លួន ដោយប្រការច្រើនយ៉ាងក្តី ក៏អ្នកស្រី រុន រំដួល នៅតែខំផ្សង។ ហ៊ានប្រថុយមិនខ្លាចគ្រោះថ្នាក់ ក៏ព្រោះតែអ្នកស្រី រំដួល គិតថា នេះជាជម្រើសតែមួយដែលអាចរកប្រាក់មកចិញ្ចឹមកូន និងម្តាយចាស់នៅផ្ទះ។

ស្រុកកំណើតនៅភូមិក្រសាំង សង្កាត់បុស្សរ៉ូ ក្រុងសំរោង ខេត្តឧត្តរមានជ័យ អ្នកស្រី រុន រំដួល បានសម្រេចចិត្តធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ កាលពីប្រមាណជាង៥ឆ្នាំមុន។ ធ្លាប់ត្រូវប៉ូលិសថៃចាប់ដាក់គុកមួយខែកន្លះ ក្រោមបទចោទលួចឆ្លងដែនដោយខុសច្បាប់ ទាំងដែលអ្នកស្រីមានកូនខ្ចីនៅជាមួយផង។ តែក៏ថាការឆ្លងដែនដោយខុសច្បាប់ ប្រឈមនឹងបញ្ហាច្រើន ហើយឧបសគ្គដែលគួរឱ្យភ័យខ្លាចបំផុត គឺគ្រោះថ្នាក់ដល់អាយុជីវិតដោយប្រការផ្សេងៗ តែអ្នកស្រី រុន រំដួល ដែលមានកូនតូច និងម្តាយចាស់នៅផ្ទះ នៅតែខំប្រថុយដើម្បីរកប្រាក់មកផ្គត់ផ្គង់គ្រួសារ ជាច្រើនលើកច្រើនសារ។

តម្លៃធ្វើប៉ាស្ព័រ ឬលិខិតឆ្លងដែន និងឯកសារមួយចំនួនទៀត ដើម្បីអាចរកការងារបានធ្វើនៅប្រទេសថៃ ត្រូវចំណាយអស់ប្រមាណ ២៤,០០០ បាត គិតជាប្រាក់ខ្មែរ ប្រហែលជាង ៣លានរៀល។ នេះជាព័ត៌មានដែលអ្នកស្រី រំដួល ទទួលបានពីពលករដូចគ្នាដែលធ្លាប់បានធ្វើ ហើយស្ត្រីរូបនេះអះអាងថាខ្លួនមិនមានលទ្ធភាពចំណាយឡើយ។«ខ្ញុំប្រាប់ត្រង់ខ្ញុំមិនដែលបានធ្វើលិខិតឆ្លងដែនទេ។ ខ្ញុំដឹងថាការឆ្លងដែនខុសច្បាប់វាលំបាកមែន ត្រូវតម្រួតចាប់ត្រូវគេធ្វើបាប ឬគេបាញ់ចោលក៏វាសមមុខ ប៉ុន្តែខ្ញុំក្រណាស់មិនមានលទ្ធភាពធ្វើទេ ខ្ញុំក៏ត្រូវតែធ្វើបែបនេះ។ ពេលខ្លះធ្វើបានហើយទៅដល់ទីនោះគេបោកទៀត គឺត្រូវជំពាក់គេច្រើន។ បងប្អូនរបស់ខ្ញុំដែលធ្វើលិខិតឆ្លងដែនទាំងអស់ពេលខ្លះចង់ទៅធ្វើការងារកសាង បែរជាបានទៅធ្វើការងារចុះទូកទៅវិញ ដូច្នេះធ្វើហើយចោលតែប្រាក់ហ្នឹងឯង»។ អ្នកស្រី រំដួល រៀបរាប់ទាំងទឹកមុខស្រពោន។ ប៉ុន្តែទោះជាយ៉ាងណា ស្ត្រីកូនមួយរូបនេះមានក្តីបារម្ភមួយទៀត៖«ខ្ញុំខ្លាចជំពាក់គេច្រើន មិនអាចរកប្រាក់មកសងគេវិញបាន។ ខ្ញុំទៅទាំងមិនមានសមត្ថភាព ទៅទាំងផ្សង បើគេល្អក៏បានលុយ បើគេអាក្រក់ក៏មិនបានលុយ។ ខ្ញុំទើបតែខ្ចីប្រាក់គេជាង២ម៉ឺនបាត យកមកដាំជំឡូងនៅឆ្នាំនេះ ហើយខ្ញុំមិនទាន់បានសងគេទេ»។

ចុះឡើងស្រុកថៃ ដូចជាចុះឡើងផ្ទះខ្លួនឯង អ្នកស្រី រំដួល ស៊ូទ្រាំធ្វើការទាំងប្រថុយប្រថាន ដោយពេលខ្លះថៅកែមិនបើកប្រាក់ខែឱ្យក៏មាន ហើយអ្នកស្រីក៏មិនហ៊ានតវ៉ាដែរ។ ភ្នែកសំឡឹងមើលមុខកូនប្រុសដែលអង្គុយនៅក្បែរទាំងស្រងូត ស្ត្រីដែលមានតែម្តាយ ហើយឪពុកស្លាប់ចោលរូបនេះ បន្ថែមដូច្នេះ៖«ពេលខ្លះខ្ញុំមិនមានលុយមកផ្ទះវិញទេ។ ខ្ញុំទៅមកៗ ជួនកាលខ្ញុំទៅបានមួយឆ្នាំ មានការងារស្រួលក៏ខ្ញុំនៅបានយូរ ពេលខ្លះការងារលំបាកពេកខ្ញុំក៏មិនមានលុយសល់។ ទៅធ្វើការខុសច្បាប់បែបនេះថៅកែមិនឱ្យប្រាក់ឈ្នួលថ្លៃទេ ប៉ុន្តែខ្ញុំនៅតែតស៊ូ»។ មាឌធាត់បន្តិច សម្បុរស្រអែម អង្គុយក្រោមផ្ទះជាប់សសរ ជិតកូនប្រុសរបស់ខ្លួន អ្នកស្រី រុន រំដួល រៀបរាប់ពីដំណើរជីវិតឆ្លងដែនខុសច្បាប់ទាំងអួលដើមក ដោយសំដីរដឺនបែបអ្នកស្រុកលើថា«ខ្ញុំក្រក្សត់ណាស់មិនមានអ្វីហូប ហើយការធ្វើស្រែចម្ការក៏មិនសូវមាន។ ខ្ញុំឆ្លងដែនតាមគេ ដើរគ្រប់ទីកន្លែង បើត្រូវជាប់គុកច្រវាក់ក៏ជាប់ទៅចុះ។ ខ្ញុំមិនមានស្រែចម្ការធ្វើទេ ខ្ញុំទៅស៊ីឈ្នួលធ្វើការឱ្យអ្នកស្រុកបានតែ១ថ្ងៃឬ២ថ្ងៃក៏មិនសល់លុយ ព្រោះគេក៏មិនសម្បូរការងារ។ ដូច្នេះខ្ញុំក៏ទៅធ្វើការស្រុកគេទាំងប្តីនិងប្រពន្ធ។ កូនខ្ញុំទុកនឹងម៉ែ ហើយម៉ែមិនមានការងារអ្វីធ្វើទេ ចាំតែកូនផ្តល់លុយឱ្យ។ កន្លះខែខ្ញុំផ្ញើឱ្យម៉ែ១ពាន់បាត ហើយគាត់មើលចៅ៤ទៅ៥នាក់។ អស់ប្រាក់របស់ខ្ញុំ គាត់ចាយរបស់បង អស់របស់បង គាត់ក៏ចាយរបស់ប្អូន»។

មិនមានចំណេះដឹងជ្រៅជ្រះ ដូច្នេះអ្នកស្រី រ៉ដួល បានត្រឹមធ្វើការជាកម្មករដេកដំឡូងឱ្យអ្នកនៅក្នុងស្រុកភូមិជាមួយ ប៉ុន្តែទោះជាយ៉ាងណា ប្រាក់ដែលរកបាន មិនអាចធ្វើឱ្យជីវភាពរបស់គ្រួសារអ្នកស្រី បានប្រសើរឡើយ ដូច្នេះការចំណាកស្រុកគឺជាជម្រើសចុងក្រោយរបស់ស្ត្រីវ័យ២៧ឆ្នាំរូបនេះ។«នៅស្រុកនេះខ្ញុំមិនដឹងទៅរកអ្វីបានទេ មានតែគេជួលដកដំឡូងមួយថ្ងៃបាន២រយបាត យកមកចាក់សាំងម៉ូតូ ផង ចាក់សាំងគោយន្តផង ណាម្ហូបកូន គឺចំណាយអស់គ្មានសល់ទេ។ បើខ្ញុំទៅធ្វើការនៅថៃ ខ្ញុំអាចសន្សំប្រាក់សល់ខ្លះផ្ញើមកផ្ទះ»។ នេះជាការរៀបរាប់របស់អ្នកស្រី រ៉ដួល។ ចំណាកស្រុកទៅធ្វើការនៅប្រទេសថៃទាំងប្តីនិងប្រពន្ធ ដោយទុកកូនប្រុសឱ្យនៅជាមួយម្តាយអាយុជិត៧០ឆ្នាំ នារីពាក់អាវយឺតពណ៌ខ្មៅដៃវែង ដែលមានផ្ទៃមុខមូលក្រឡុងបង្កប់នូវទុក្ខព្រួយរូបនេះ ទៅធ្វើជាកម្មករកាប់អំពៅនៅប្រទេសថៃ។ស្ត្រីវ័យ២៧ឆ្នាំរូបនេះ បាននិយាយដូច្នេះថា៖«ខ្ញុំកាប់អំពៅមិនគិតថ្លៃទេ គឺម៉ោយកតែម្តង ថ្ងៃខ្លះខ្ញុំរកបានប្រាក់៧រយទៅ៨រយបាត ហើយប្តីរកបានជាង១ពាន់ឬ២ពាន់បាត អាស្រ័យតាមថ្ងៃបានឬមិនបាន។ បើថ្ងៃដែលរកមិនបានវិញ មួយថ្ងៃបានតែ៣រយបាត ពីរនាក់បាន៦រយបាត។ ធ្វើការនៅទីនោះគេមានកន្លែងឱ្យស្នាក់ ជួនកាលគេទិញតង់ឱ្យស្នាក់នៅក្នុងព្រៃ»។ ក្រោមហេតុផលនៃសេចក្តីទុក្ខវេទនា នៃការធ្វើទុកបុកម្នេញពីថៅកែផង ដោយការធ្វើដំណើរប្រកបដោយគ្រោះថ្នាក់ ហើយត្រូវគេចពីតម្រួតថៃខ្លះផងនោះ ស្ត្រីដែលមានបងប្អូន៦នាក់ ដែលសុទ្ធតែចំណាកស្រុកដើម្បីរកការងារធ្វើ រូបនេះ ផ្តាំទៅប្រជាជនខ្មែរ កុំឱ្យលួចឆ្លងចូលទឹកដីថៃដោយខុសច្បាប់ដូចជាខ្លួន។«ខ្ញុំចង់ប្រាប់ដល់ពុកម៉ែបងប្អូនប្រជាពលរដ្ឋទាំងអស់ មានប្រាក់ក៏សូមធ្វើលិខិតឆ្លងដែនឱ្យបានគ្រប់ៗគ្នាកុំឱ្យដូចខ្ញុំ។ ខ្ញុំទៅថៃទាំងលំបាក ជួនកាលគេបោកជួនកាលក៏សល់លុយ។ អ្នកខ្លះទ្រាំធ្វើការមិនបានក៏រត់មកវិញជួបគ្រោះថ្នាក់ស្លាប់ក៏មាន។ ព្រោះតែខ្ញុំក្រពេកទើបខ្ញុំទៅទាំងផ្សងព្រេង»។ នេះជាខ្សែជីវិតរបស់ស្ត្រីចំណាកស្រុកខាងលើ៕

## រថយន្តសណ្តោងដឹកដើមអំពៅ កិនពលករខ្មែរម្នាក់ស្លាប់ នៅក្នុងខេត្តស្រះកែវ

http://kampucheathmey.com/ 7/1/2020 11:28 Am

ប្រទេសថៃ ៖ ពលករខ្មែរម្នាក់ ដែលជាកម្មករស៊ីឈ្នួលកាប់ដើមអំពៅ នៅក្នុងប្រទេសថៃ ត្រូវបានរថយន្តសណ្តោងដែលចូលទៅដឹកដើមអំពៅ កិនស្លាប់យ៉ាងអាណោចអាធ័មជាទីបំផុត ខណៈដែលពលករខ្មែររូបនេះ បានឡើងជិះលើរថយន្តនោះហើយត្រូវដើមអំពៅជ្រែរអិលធ្លាក់ពីលើរថយន្តដោយទាំងមនុស្សធ្លាក់ទៅដីទៅជាមួយផង។

យោងតាមការផ្សាយព័ត៌មានពីកាសែត ថៃរ៉ាត់ ប្រទេសថៃ បានឲ្យដឹងថា កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ វេលាម៉ោង៦និង៣០នាទី ព្រឹក មានករណីពលរដ្ឋខ្មែរធ្វើការ ស៊ីឈ្នួលកាប់អំពៅម្នាក់ ត្រូវរថយន្តសណ្តោងកិនស្លាប់យ៉ាងអាណោចអាធ័ម នៅត្រង់ចំណុចក្នុងចម្ការអំពៅមួយកន្លែង ក្នុង ភូមិណងប្រាយ៉ាប្លុង ឃុំបរ៉ៃ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ ។ កាសែត បានស្រង់សម្តីសាក្សីមួយចំនួន ដោយបានលើកឡើងថា ជនរងគ្រោះ ដែលស្លាប់បាត់បង់ជីវិត គឺជាពលករខ្មែរ មកបម្រើការជាកម្មករកាប់ដើមអំពៅ និងលើកដើមអំពៅឡើងលើរថយន្ត ដើម្បីដឹកចេញពីចម្ការ ភេទប្រុស អាយុ ១៧ឆ្នាំ ដោយ មូលហេតុគឺ ជនរងគ្រោះបានឡើងទៅលើរថយន្តសណ្តោងនោះ បន្ទាប់ពីបានលើកដើមអំពៅឡើងលើរថយន្តរួច ប៉ុន្តែស្រាប់តែដើមអំពៅទាំងនោះ បានរអិលជ្រែ ធ្លាក់ពីលើរថយន្ត ដោយទាំងមនុស្ស ទៅជាមួយផង បន្ទាប់មកក៏ត្រូវត្លរថយន្តខាងក្រោយ កិនស្លាប់នៅកន្លែងកើតហេតុតែម្តង។

ក្រោយពេលកើតហេតុសមត្ថកិច្ចថៃបានចុះត្រួតពិនិត្យសព រួចក៏បានបញ្ជូនសពទៅរក្សាទុកនៅមន្ទីរពេទ្យដើម្បីធ្វើ កោសល្យវិច័យ រួចប្រគល់ទៅឲ្យក្រុមគ្រួសារ ឬសាច់ញាតិ ក្នុងការរៀបចំបញ្ជូនទៅកាន់ ស្រុកកំណើតវិញ៕

**សោ និយមរ័ត្ន**

## សាច់ញាតិសម្រេចបូជាសពពលករខ្មែរម្នាក់នៅប្រទេសថៃ ដែលស្លាប់ដោយសារថយន្តកិនក្នុងចម្ការអំពៅ

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី 2020-01-07

សាច់ញាតិពលករខ្មែរម្នាក់សម្រេចបូជាសពជនរងគ្រោះនៅខេត្តស្រះកែវ ប្រទេសថៃ ដែលស្លាប់ដោយសារឡានកិន ពេលធ្វើការក្នុងចម្ការអំពៅកាលពីថ្ងៃទី៦ មករា។ អ៊ុំស្រីបង្កើតជនរងគ្រោះ លោកស្រី ឈឿន ឈន់ ប្រាប់អាស៊ីសេរីថា ជនរងគ្រោះឈ្មោះ រាន ធៃ ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅឃុំមោង ស្រុកស្រីស្នំ ខេត្តសៀមរាប ត្រូវបានឡានកិនស្លាប់នៅលើគំនរអំពៅ កាលពីព្រឹកថ្ងៃទី៦ មករា។ លោកស្រីបន្តថា ក្រោយពេលស្លាប់ គឺប៉ូលិសថៃបានទៅពិនិត្យសាកសព និងបានបញ្ជូនសពទៅធ្វើបុណ្យនៅស្រុកអារញ្ញខេត្តស្រះកែវ នៅព្រឹកថ្ងៃទី៧ មករា។ លោកស្រីបញ្ជាក់ថា មូលហេតុដែលធ្វើបុណ្យនៅប្រទេសថៃ ដោយសារគ្មានប្រាក់ដឹកសពទៅធ្វើបុណ្យនៅស្រុកកំណើត ព្រោះគ្រួសារជនរងគ្រោះក្រីក្រ៖ «ថៅកែ និងប៉ូលិសអី គេមកជួយធ្វើបុណ្យជាច្រើននាក់។

ខ្ញុំយកកូនមក ដូចនាំកូនមកស្លាប់ស្រុកគេ។ ខ្ញុំឃំបោកខ្លួនបោកប្រាណស្តាយកូនស្លាប់ទាំងក្មេង។ ខ្ញុំឃើញកូនបែកក្បាល បែកមុខ ក៏វាស្លូតអស់និយាយមិនកើតទេ។ ដោយហេតុថា ក្រក៏នាំកូនមករកស៊ីខ្លាចបានប្រាក់ខ្លះ ព្រោះនៅផ្ទះគ្មានការងារធ្វើ មកដល់មិនទាន់បាន ១ខែផង ស្រាប់តែកូនស្លាប់វាវង្វេងអស់លើងខ្ញុំ»។ លោកស្រីបន្ថែមថា ជនរងគ្រោះបានធ្វើដំណើររួមជាមួយពលករខ្មែរប្រមាណ ២០នាក់ ចេញពីឃុំមោង ដើម្បីទៅស៊ីឈ្នួលកាប់អំពៅនៅប្រទេសថៃ កាលពីខែធ្នូកន្លងទៅ។ លោកស្រីថា ពួកគាត់ធ្វើការបានប្រហែល ៣សប្តាហ៍ ក៏ជួបគ្រោះថ្នាក់តែម្តង។ ក្រោយពីបូជាសពហើយ គឺពលករទាំងនោះគ្រោងត្រឡប់ទៅកម្ពុជាវិញ ដើម្បីយកឆ្អឹងរបស់ជនរងគ្រោះទៅធ្វើបុណ្យនៅខេត្តសៀមរាបបន្តទៀត នៅដើមសប្តាហ៍ខាងមុខនេះ៕

# ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០២០

## (គ.ខ.ប.ជ) ខេត្តសៀមរាប និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ជួបសំណេះសំណាលជាមួយអតីតពលករ និងក្រុមគ្រួសាររបស់ពលករដែលកំពុងចំណាកស្រុកនៅក្រៅប្រទេស

https://www.facebook.com/deputygovernoryousophear/ January 8 at 10:30 PM •

ខេត្តសៀមរាប ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ ក្រុមការងារលេខាធិការដ្ឋាននៃគណ:កម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) បានសម្របសម្រួលជូនអង្គការបេសកកម្មយុត្តិធម៌ និងអន្តរជាតិ (IJM) ដោយមានកិច្ចសហការពីរដ្ឋបាលស្រុកក្រឡាញ់ ឃុំសែនសុខ ឃុំចន្លាសដៃ និងឃុំដូនពែង ស្រុកអង្គរជុំ បានចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលជាអតីតពលករ និងក្រុមគ្រួសាររបស់ពលករដែលកំពុងចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស បានចំនួន០៣ឃុំ ក្នុងនោះ នៅស្រុកក្រឡាញ់បានចំនួន០២ឃុំរួមមាន ឃុំសែនសុខ (ភូមិប្រទៀង ភូមិគោកភ្វាស និងភូមិគោកយាង) ដែលមានចំនួនចូលរួមសរុប ៣៥នាក់ ឃុំចន្លាសដៃ (ភូមិព្រះលាន និងភូមិចន្លាសដៃ) ដែលមានចំនួនចូលរួម ៣២នាក់ និងនៅភូមិខ្វាស់ ឃុំដូនពេង ស្រុកអង្គរជុំ ដែលមានចំនួនចូលរួម១២នាក់ ស្រី១១នាក់ សរុបរួម ៧៩នាក់។

កិច្ចជំនួបនេះផងដែរ ក៏មានការអញ្ជើញចូលរួមពីលោកស្រី អភិបាលរងស្រុកក្រឡាញ់ លោកមេឃុំសមាជិកក្រុមប្រឹក្សាឃុំសែនសុខ ឃុំ ចន្លាសដៃ ស្រុកក្រឡាញ់ និងឃុំដូនពេង ស្រុកអង្គរជុំផង។ ការចុះប្រមូលព័ត៌មាន ពីប្រជាពលរដ្ឋដែលធ្លាប់បានធ្វើការចំណាកស្រុក និងក្រុមគ្រួសារពលករដែលធ្លាប់បាន និងកំពុងចំណាកស្រុកនៅក្រៅប្រទេសនេះ ដើម្បីធ្វើការសិក្សាស្វែងយល់លើបញ្ហាបន្ថែមអំពីករណីជួញដូរកំលាំងពលកម្មលើពលករ

កម្ពុជា នៅក្នុងប្រទេសគោលដៅ ពិសេសប្រទេសថៃ និងប្រទេសម៉ាឡេស៊ី ដើម្បីកំណត់អំពីតម្រូវការរបស់ជនរងគ្រោះដោយអំពីជួញដូរកម្លាំងពលកម្មទាក់ទងនឹងផ្នែកច្បាប់ និងផ្នែកសង្គមកិច្ច។

## កម្លាំងសមត្ថកិច្ចទាហានថៃប្រចាំកុងត្រួលធ្វើការឃាត់ខ្លួនពលករ ពីបទចំណាកស្រុក ខុស ច្បាប់

https://www.facebook.com/ 09-01-2020

ករណីពលករខ្មែរធ្វើការក្នុងប្រទេសថៃ គ្មានលិខិតឆ្លងដែនធ្វើដំណើរទៅផ្ទះវិលត្រឡប់ទៅស្រុកកំណើតវិញ ត្រូវកម្លាំងសមត្ថកិច្ចទាហានប្រចាំកុងត្រួលធ្វើការឃាត់ខ្លួនពីបទចំណាកស្រុកខុសច្បាប់ ព្រមទាំងឃាត់ខ្លួនជនជាតិថៃ ដែលជាម្ចាស់រថយន្តទទួលដឹកសម្ភារៈរបស់ពលករទាំងនោះផងដែរ ។ "ដូច្នេះហើយបងប្អូនពលករដែលធ្វើការស្នាក់នៅក្នុងប្រទេសថៃ ត្រូវប័ណ្ណអនុញ្ញាតកាងារនៅ ទិដ្ឋាការស្នាក់យ៉ាងត្រឹមត្រូវតាមច្បាប់របស់ប្រទេសថៃ ទើបមិនជួបបញ្ហាដូចបងប្អូនពលករខ្មែរយើងរូបនេះ"។

## ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២០

## សំណូមពរដល់អ្នកពាក់ព័ន្ធបន្តចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជួញដូរមនុស្សគ្រប់ទម្រង់

http://www.cen.com.kh/archives/ January 11, 2020

រាជធានីភ្នំពេញ៖ សិក្ខាសាលាស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងគ្រោះថ្នាក់បងង្កដោយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ត្រូវបានធ្វើឡើងនៅថ្ងៃទី១០ ខែមករា ឆ្នាំ ២០២០ នៅសាលប្រជុំក្រសួងអប់រំយុវជន និងកីឡា។

លោក ស សុខា រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ដែលជាអធិបតី បានប្រសាសន៍ថ្លែងអំណរគុណដល់អ្នកពាក់ព័ន្ធដែលបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផ្សព្វផ្សាយបង្ការទប់ស្កាត់បញ្ហាគ្រឿងញៀន និងការជួញដូរមនុស្ស និងសំណូមពរដល់អាជ្ញាធរមានសមត្ថកិច្ច អ្នកពាក់ព័ន្ធទាំងអស់ យុវកាយរឹទ្ធិ កាកបាទក្រហម សិល្បករ សិល្បការិនី ពិធីករ ពិធីការិនី សង្គមស៊ីវិល សូមបន្តចូលរួមទាំងអស់គ្នាឲ្យបានសកម្មជាប់ជាប្រចាំដូចភ្លៀងរលឹមដើម្បីសុវត្ថិភាពសហគមន៍ ។

លោកស្រី សឿ សុជាតា អនុរដ្ឋលេខាធិការប្រធានក្រុមការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រឆាំងការជួញដូរមនុស្ស ប្រចាំក្រសួងអប់រំ យុវជន និងកីឡា បានធ្វើសេចក្តីរាយការណ៍ពីវឌ្ឍនភាពការងារបង្ការទប់ស្កាត់បញ្ហាគ្រឿងញៀន និងបញ្ហាជួញដូរមនុស្ស សំដៅពង្រឹងគុណភាព ប្រសិទ្ធភាពធនធនមនុស្សនៅកម្ពុជា។

លោក សាម៉ន បណ្ឌិត អនុរដ្ឋលេខាធិការក្រសួងព័ត៌មានបានមានប្រសាសន៍ថា វិស័យព័ត៌មានដើរតួនាទីសំខាន់ក្នុងការចូលរួមផ្សាយព័ត៌មានចំណេះដឹងទូទៅនានា និងច្បាប់ពាក់ព័ន្ធបញ្ហាគ្រឿងញៀន និងបញ្ហាជួញដូរមនុស្សដល់ប្រជាពលរដ្ឋបានយល់ដឹង។

លោកស្រីឧត្តមសេនីយ៍ឯក ប៊ុន សំខាន់ អគ្គលេខាធិការគណកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស បានប្រសាសន៍ថា អំពើជួញដូរមនុស្សគឺជាបទល្មើសឧក្រិដ្ឋកម្មឆ្លងដែនមានអង្គការចាត់តាំង ដែលតម្រូវឲ្យមានការប្រឆាំងទប់ស្កាត់ការជួញដូរនិងសង្គ្រោះជនរងគ្រោះពីអំពើជួញដូរគ្រប់ទម្រង់។

លោកនាយឧត្តមសេនីយ៍ មាស វិរិទ្ធ អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានថ្លែងសាទរពីវឌ្ឍនភាព និងថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងពាក់ព័ន្ធ ដែលបានចូលរួម

ប្រយុទ្ធប្រឆាំងបង្ការ ទប់ស្កាត់ បញ្ហាគ្រឿងញៀនដើម្បីប្រយោជន៍រួម គោលដៅតែមួយ គឺកសាងបាននូវធនធានមនុស្សប្រកបដោយប្រសិទ្ធភាពជាធនធានបន្តវេនដ៏មានសក្តានុពលរបស់ប្រទេសជាតិ។

ក្នុងចំណាប់អារម្មណ៍របស់មន្ទីរក្រសួងអប់រំ យុវជន និងកីឡាខេត្តកោះកុង បន្ទាយមានជ័យ បាត់ដំបង ព្រៃវែង រាជធានីភ្នំពេញ កណ្តាល និងអង្គការភ្លេន Plan សុទ្ធតែបានបង្ហាញពីឆន្ទៈរួមចូលរួមបង្ការទប់ស្កាត់បញ្ហាគ្រឿងញៀន និងបញ្ហាជួញដូរមនុស្សដើម្បីអនាគតយើងកូនចៅយើង៕ ដោយៈបញ្ញាស័ក្តិ

## សមត្ថកិច្ចខេត្តប៉ៃលិនចុះបង្ក្រាបទីតាំងបម្រើសេវាផ្លូវភេទចាប់ខ្លួនមនុស្សប្រុស ស្រី ៦នាក់មានទាំងវៀតណាម ខ្មែរ ថៃ

http://khmer.peoplenews.asia/ ដោយ ៖ SOVANNA ROTH ថ្ងៃទី11 ខែ01 ឆ្នាំ2020 ម៉ោង 1:58 PM

ខេត្តប៉ៃលិន៖ ទីតាំងបម្រើសេវាផ្លូវភេទនៅជាយដែនខ្មែរ ថៃមួយកន្លែង ដែលបានលួចបើកដំណើរការលួចលាក់ជាយូរមកហើយនោះ ពេលនេះត្រូវបានសមត្ថកិច្ចនគរបាលព្រហ្មទណ្ឌនៃស្នងការដ្ឋាននគរបាលខេត្តប៉ៃលិនធ្មក់ចុះបង្ក្រាបជាក់ស្តែងក្នុងចាប់ឃាត់ខ្លួនមនុស្សចំនួន៦នាក់មានប្រុស២នាក់ជនជាតិ ថៃម្នាក់និងខ្មែរ ម្នាក់ដែលបាននាំគ្នាទៅរកសេវាផ្លូវភេទនេះ ។

ប្រតិបត្តិការនេះត្រូវបានធ្វើឡើង កាលពី ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្ថិតនៅចំណុចផ្ទះឈ្មោះ សុខ ស្រីលីន ជាជនជាតិវៀតណាម ក្នុងភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិនរកឃើញវត្ថុតាងស្រោមអនាម័យសម្រាប់ បំរើផ្លូវមួយចំនួន ។តាមប្រភពព័ត៌មានបានឲ្យដឹងថា តាមពិតទីតាំងមួយនេះលបលួចបើកបម្រើសេវាផ្លូវភេទយូរមកហើយ មិនដឹងថាសមត្ថកិច្ចគាត់មិនដឹងសោះមែនឬក៏ដឹដែរមិនទាន់មានពេលបង្ក្រាបនោះទេ ទើបតែពេលនេះសមត្ថកិច្ចបានឆ្លៀតធ្មក់ចុះបង្ក្រាបជាល់ស្តែងឃើញមានវត្ថុតាងសម្រាប់បម្រើផ្លូវភេទប្រាកដមែន។

ជនសង្ស័យដែលសមត្ថកិច្ចឃាត់ខ្លួនទី១ឈ្មោះ សុខ ស្រីលីន (ម្ចាស់ផ្ទះ) ភេទស្រី អាយុ ៣៥ឆ្នាំ ជនជាតិវៀតណាម ,ទី២ឈ្មោះ ង្វៀង ធីហុង (ហៅ រក្សា) ភេទស្រី អាយុ ២៥ឆ្នាំ ជនជាតិវៀតណាម,ទី៣ឈ្មោះ ធិន ណាវ៉ាន់ (ហៅ អាម៉ី) ភេទស្រី អាយុ ២២ឆ្នាំ ជនជាតិ វៀតណាម,ទី៤ឈ្មោះ ថៃ នីតែលិន ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិវៀតណាម,ទី៥ឈ្មោះ ម៉ៃទ្រី ថាណាផាសាត់ថាណា (ហៅ ម៉ៃទី) ភេទប្រុស អាយុ ៤៥ឆ្នាំ មុខរបរ គ្រូពេទ្យជនជាតិថៃ និងទី៦ឈ្មោះ ឆាត ឡុង ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរសន្តិសុខ ដែលបច្ចុប្បន្នស្នាក់នៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។

ការឃាត់ខ្លួនជនសង្ស័យ ខាងលើ សមត្ថកិច្ចជំនាញ ក៏បានធ្វើការឆែកឆេរ ប្រទះឃើញស្រោមអនាម័យមួយចំនួន នៅក្នុងកាបូបដៃជនសង្ស័យ និងស្រោមអនាម័យ ដែលប្រើប្រាស់រួច នៅក្នុងធុងសំរាមសរុបចំនួន១០ស្រោម។ ជនសង្ស័យខាងលើ ត្រូវសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន រៀបចំកសាងសំណុំរឿង ដើម្បីអនុវត្តតាមនីតិវិធី៕

## បុរសជនជាតិចិនម្នាក់ស្រលាញ់ ពលការិនីខ្មែរ ខ្លាំងពេក ខំតាមមករហូតដល់ស្រុកខ្មែរ បង្ខំឲ្យនាងត្រឡប់ទៅ ចិន វិញទាំងខុសច្បាប់

http://khmer.peoplenews.asia/ ដោយ ៖ SOVANNA ROTH ថ្ងៃទី11 ខែ01 ឆ្នាំ2020 ម៉ោង 5:48 PM

ភ្នំពេញ ៖ ស្ត្រីវ័យក្មេងជាអតីតពលការិនីធ្វើការនៅប្រទេសចិននិងមានទំនាក់ទំនងស្នេហាស៊ីជម្រៅដូចប្តីប្រពន្ធជាមួយនិងបុរសជនជាតិចិនម្នាក់នេះរហូត ធ្វើឲ្យបុរសនោះបំភ្លេចនាងមិនបានក៏តាមមកលេងនាងដល់ស្រុកខ្មែរ តែដល់ពេលត្រឡប់ទៅចិនវិញបានបង្ខំឲ្យនាងទៅជាមួយដែរ ដោយអះអាងថាខ្លួនបានទិញនាងពីឪពុកម្តាយនាងរួចហើយ ធ្វើឲ្យនាងស្រឡាំងកាំង ទើបបង្កជាទំនាស់ប្រតាយប្រតប់គ្នា រត់ទៅប្តឹងប៉ូលិសប៉ុស្តិ៍កាកាបទី១ ឲ្យជួយអន្តរាគមន៍ កាលពីវេលាម៉ោង១០និង៣០នាទីព្រឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ នៅមុខព្រលានយន្តហោះពោធិចិនតុង ភូមិក្បាលដំរី១ សង្កាត់កាកាបទី១ ខណ្ឌពោធិសែនជ័យ ។

វត្តមានភាគីអ្នកទាំង២ មកដល់ប៉ុស្តិ៍នគរបាល ស្ត្រីជនជាតិខ្មែរ បានឲ្យដឹងថា នាងមានស្រុកកំណើតនៅឯខេត្តកំពង់ចាម កន្លងមកធ្លាប់ទៅធ្វើការងារស្របច្បាប់ នៅឯប្រទេសចិន ហើយក៏មានស្នេហា ជាមួយបុរសជនជាតិចិនខាងលើនេះ រស់នៅជាមួយគ្នាដូចប្តីប្រពន្ធ ពិតប្រាកដមែន លុះវិលមកស្រុកខ្មែរវិញ នាងគ្មាន ឯកសារលិខិតឆ្លងដែន ស្របច្បាប់ណាដើម្បីត្រឡប់ ទៅស្រុកចិនវិញទេ អស់រយៈពេលច្រើនខែមកហើយ ស្រាប់តែប៉ុន្មានថ្ងៃនេះ លេចមុខបុរសជនជាតិចិនខាងលើ វិលមកលេងស្រុកខ្មែរ តាមទៅលេងនាងដល់ផ្ទះឯខេត្តកំពង់ចាម ។ ប្រភពបន្តថា លុះមកដល់ព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២០នេះ បុរសជនជាតិចិនខាងលើ ត្រូវកំណត់វិលទៅស្រុកចិនវិញ ហើយសុំឲ្យនាងជូនដំណើររូបគេ ដល់ព្រលានយន្តហោះ ។ គ្រាដែលមកដល់ ព្រលានហើយ បែរជាប្រាប់ថារូបគេបានទិញនាងឲ្យលុយទៅឪពុកម្តាយនាងរួចហើយ ត្រូវតែឡើងយន្តហោះទៅស្រុកចិនជាមួយរូបគេវិញ ។ សម្ដីដ៏ភ្ញាក់ផ្អើលនេះធ្វើឲ្យ ស្ត្រីខ្មែររូបនេះ ប្រកែក មិនទៅស្រុកចិនវិញទេព្រោះ គ្មានឯកសារ គ្មានលិខិតឆ្លងដែន ស្របច្បាប់ផងនឹង នាងទទួលស្គាល់ហើយ ស្រឡាញ់គ្នា គ្រានៅស្រុកចិន តែវិលមកស្រុកខ្មែរ ពុំស្របច្បាប់ឡើយ នាងមិនទៅជាមួយទេ ទើបកើតជារឿងឈ្លោះ ប្រកែក ប្រតាយប្រតប់គ្នា បានក្រុមអ្នករត់ម៉ូតូកង់បីឃើញ ជួយឃាត់ និងដឹកនាំជួយជូនទៅប្តឹងនៅប៉ុស្តិ៍កាកាបទី១ ។

ក្រោយពីភាគីទាំង២ បុរសជនជាតិចិន ជាមួយស្ត្រីជនជាតិខ្មែរ សមត្ថកិច្ច ហៅនាំសាកសួរ ភាគីខាងជនជាតិចិន ដល់ម៉ោងឡើងយន្តហោះហើយ សុំចាកចេញទៅវិញ ហើយកុំឲ្យខកខាន ការធ្វើដំណើរ វិលទៅស្រុកឆ្ងាយផង ប៉ូលិស ឲ្យស្ត្រីខ្មែរវិលទៅស្រុកកំណើតវិញ រីឯជនជាតិចិន បន្តដំណើរឡើងយន្តហោះ ដើម្បីបញ្ចប់រឿង ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ GDI January 10 at 4:13 PM •

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៥ និង ៣០នាទី ថ្ងៃទី១០ ខែមករា ឆ្នាំ ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៣នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## តើពលករខ្មែរអាចមកធ្វើការនៅក្នុងប្រទេសអូស្ត្រាលីដោយស្របច្បាប់បានដែរឬទេ?

https://www.sbs.com.au/language/ 11-01-2020

ថ្មីៗនេះ មានការផ្ទុះឡើងវិញម្តងទៀតនូវដំណឹងជ្រើសរើសបុគ្គលិកមកធ្វើការផ្នែកបេះបន្លែផ្លែឈើនៅក្នុងប្រទេសអូស្ត្រាលី។ ប្រិយមិត្តយើងបានទាក់ទងមកSBSខ្មែរ ដើម្បីសុំការពន្យល់បំភ្លឺថា "តើរដ្ឋាភិបាលអូស្ត្រាលីអនុញ្ញាតិឲ្យពលករខ្មែរមកធ្វើការនៅក្នុងប្រទេសអូស្ត្រាលីដែរឬទេ?"។ សូម្បីតែគេហទំព័ររបស់ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជាក៏បានបញ្ជាក់ផងដែរថានេះគឺជាករណីឆបោក។ តើពលករខ្មែរអាចមកធ្វើការនៅក្នុងប្រទេសអូស្ត្រាលីដោយស្របច្បាប់បានដែរឬទេ? តើការលបលួចធ្វើការងារដោយបំពានលក្ខខណ្ឌទិដ្ឋាការនៅក្នុងប្រទេសអូស្ត្រាលីប្រឈមនឹងផលវិបាកអ្វីខ្លះ?

## ពលករខ្មែរ និងភូមាខុសច្បាប់ ចំនួន១៩ នាក់ត្រូវបានកម្លាំងសមត្ថកិច្ចចម្រុះ ខេត្តឈុនបុរី ឃាត់ ខ្លួន

https://www.facebook.com/LabourOfficial/ 10/01/20

យោងតាមរបាយការណ៍ពីខេត្តឈុនបុរី ប្រទេសថៃ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ នេះបានអោយដឹងថា កម្លាំងសមត្ថកិច្ចចម្រុះប្រចាំខេត្តឈុនបុរី ប្រទេសថៃ បានធ្វើការចុះត្រួតពិនិត្យការដ្ឋានសំណង់មួយកន្លែងស្ថិតនៅក្នុងស្រុកសាមេត ខេត្តឈុនបុរី បានរកឃើញពលករបរទេសធ្វើការសំណង់សរុបចំនួន ៦៦នាក់ សមត្ថកិច្ចបានរកឃើញពលករខុសច្បាប់ខ្មែរ និងភូមាចំនួន១៩នាក់។

តាមការបញ្ជាក់របស់សមត្ថកិច្ចបានអោយដឹងថា ពលករបរទេសទាំងអស់ធ្វើការសំណង់នៅទីនេះ ដោយទទួលបានប្រាក់ឈ្នួលក្នុងមួយថ្ងៃ ៣៥០បាត ដោយមានថៅកែមួយចំនួនលួចជួលពលករខុសច្បាប់ធ្វើការ អាចធ្វើឲ្យពលករទាំងនោះប្រឈមនៅការមិនទទួលបានសិទ្ធិគាំពារផ្សេងៗ ពីច្បាប់ការងារ នឹងងាយរងគ្រោះដោយការជិះជាន់ កេងប្រវ័ញ្ចកម្លាំងពលកម្មទៀតផង។

## ពលករខ្មែរម្នាក់ដើរឆ្លងផ្លូវ ត្រូវរថយន្តបុកស្លាប់ យ៉ាងអាណោចអាធ័ម

https://www.facebook.com/LabourOfficial/ 10/01/20

យោងតាមប្រភពពីខេត្តនុនថាក់បុរី ប្រទេសថៃ បានអោយដឹងថា បុរសពលករខ្មែរឈ្មោះ Ang krorm ភេទប្រុស អាយុ៥២ឆ្នាំ ត្រូវរថយន្តបុកស្លាប់ កាលពីវេលាម៉ោង១១:៥០នាទី យប់ឈានថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ នៅត្រង់ចំណុចផ្លូវជាតិលេខ៣៤០ ស្ថិតនៅក្នុងភូមិ៩ សង្កាត់លាក់ហា ស្រុកបាងបួរថង ខេត្តនុនថាក់បុរី ប្រទេសថៃ។ ប្រភពពីកន្លែងកើតហេតុ បានប្រាប់ឲ្យដឹងថា បុរសពលករខ្មែរខាងលើបានដើរឆ្លងផ្លូវត្រូវរថយន្ត ម៉ាក Toyota Altis ពាក់ស្លាកលេខ ២៧១៦ ក្រុងថេប បុកពេញទំហឹងបន្ទាប់មកត្រូវរថយន្តសណ្តោងមិនស្គាល់ ម៉ាកបន្ថែមបណ្តាលឲ្យស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ។

## មានករណីពលករខ្មែរត្រូវខ្សែភ្លើងឆក់ស្លាប់ទាំងព្រឹកយ៉ាងអាណោចអាធ័ម

https://www.facebook.com/LabourOfficial/ 1/01/20

ប្រភពពីខេត្តឈុនបុរី ប្រទេសថៃបានអោយដឹងថា មានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ ខន ភេទប្រុស អាយុ៣៦ឆ្នាំ ស្រុកកំណើតរស់នៅភូមិស្ពានរង ខេត្តព្រៃវែង មុខរបរជាពលករធ្វើការនៅក្នុងរោងចក្រផ្លាសស្ទិចនៅ

ខេត្តឈុនបុរី ប្រទេសថៃត្រូវខ្សែភ្លើងឆក់ស្លាប់កាលពីវេលាម៉ោង ០៦ព្រឹក ថ្ងៃសៅរ៍ ទី១១ ខែមករា ឆ្នាំ២០២០ បន្ទាប់ពីជនរងគ្រោះបានដើរបើកម៉ូទ័របូមទឹក ប៉ុន្តែអកុសលកុងតាក់ម៉ូទ័រឆ្លងចរន្តអគ្គិសនីបណ្តាលឲ្យឆក់ជនរងគ្រោះស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ។ បច្ចុប្បន្នសាច់ញាតិជនរងគ្រោះកំពុងដំណើរធ្វើឯកសារបញ្ជូនសាកសពជនរងគ្រោះទៅធ្វើបុណ្យនៅឯស្រុកកំណើត ។

## ប៉ូលិសហ្វីលីពីនគ្នាក់ផ្អើលខ្លាំងក្នុងពេលឆ្មក់បង្រ្កាបហាងខារ៉ាអូខេចិនសម្រាប់តែជនជាតិចិន ឃើញស្រីពេស្យាច្រើនអនេក

http://khmeread.com/ January 13, 2020 01:26AM

ពេស្យាចារ គឺជាអាជីពមួយមានវ័យចំណាស់ជាងគេបំផុតនៅលើពិភពលោកប៉ុន្តែការវិវឌ្ឍថ្មីនៃការជួញដូរផ្លូវភេទបានធ្វើឱ្យប៉ូលិសហ្វីលីពីនចូលទៀងអេះក្បាលខ្លួនឯង ព្រោះតែការកើនឡើងខ្លាំងនៃពេស្យាចារចិនសម្រាប់តែផ្គត់ផ្គង់ដល់អតិថិជនចិន។ នេះយោងតាមកាសែត South China Morning Post សរសេរកាលពីថ្ងៃអាទិត្យទី១២មករា។ ទូរទស្សន៍ហ្វីលីពីន ABS-CBN បានរាយការណ៍ថា អ្នករកស៊ីផ្លូវភេទជនជាតិចិនជិត ៣០០ នាក់និងអតិថិជនរបស់ពួកគេត្រូវបានចាប់ខ្លួនក្នុងការឆ្មក់បង្ក្រាបដោយការិយាល័យស៊ើបអង្កេតជាតិ (NBI) និងប៉ូលិសជាតិហ្វីលីពីនលើផ្ទះបនចំនួន ១២ កន្លែងនៅក្នុងទីក្រុងចំនួន ៦ នៅក្នុងឆមាសទី ២ នៃឆ្នាំចុង២០១៩។ ពួកភ្នាក់ងារសម្ងាត់ជឿថា រាល់ផ្ទះបនដែលបង្ក្រាបទាំងអស់នោះគឺគ្រប់គ្រងដោយជនជាតិចិនដីគោកសម្រាប់អតិថិជនចិន។

ប្រភពមួយនៅ NBI ដែលបានចូលរួមក្នុងការឆ្មក់បង្ក្រាប បានពិពណ៌នាផ្ទះបនទាំងអស់នោះថាជា "ការវិវឌ្ឍថ្មី"។ អតិថិជន ស្រីពេស្យា អ្នកគ្រប់គ្រង និង ម្ចាស់របស់ផ្ទះបនទាំងនោះគឺមកពីចិនដីគោកទាំងអស់ ។ ប្រភពនោះបាននិយាយថា អ្នកគ្រប់គ្រងត្រូវជាប់ពន្ធនាគារនិងត្រូវបានចោទប្រកាន់ពីបទជួញដូរមនុស្ស ដែលជាបទឧក្រិដ្ឋមួយមិនអាចបង់ប្រាក់នៅក្រៅឃុំបានទេ ហើយករណីចោទទាំងនោះនឹងត្រូវប្តឹងលើម្ចាស់ដទៃទៀត ដែលប៉ូលិសមិនអាចចាប់ខ្លួនបាន ពីព្រោះពួកគេនៅក្រៅប្រទេសហ្វីលីពីន។

ស្ត្រីជនជាតិចិន ដែលគាត់ពិពណ៌នាថា "ក្មេង មានអាយុប្រហែលពី ១៨ ទៅ ៣០ ឆ្នាំ" ត្រូវបានបញ្ជូនទៅមណ្ឌលជ្រកកោន លិខិតឆ្លងដែនរបស់ពួកគេត្រូវបានរឹបអូស និង ត្រូវបញ្ជូនទៅកាន់ការិយាល័យអន្តោប្រវេសន៍។ អតិថិជនមករ៉េសិចមិនត្រូវបានចាប់ខ្លួនទេ ប៉ុន្តែព័ត៌មានលម្អិតអំពីលិខិតឆ្លងដែនរបស់ពួកគេក៏ត្រូវបានបញ្ជូនទៅការិយាល័យអន្តោប្រវេសន៍ដែរ។ ប្រភពដដែលបាននិយាយថា ទីភ្នាក់ងាររដ្ឋាភិបាលជាច្រើនបាននិងកំពុងចាត់វិធានការប្រឆាំងនឹងក្រុមពេស្យាចាររបស់ចិន។

ប្រភព NBI បានពិពណ៌នាផ្ទះបន ដែលក្រុមរបស់លោកបានឆ្មក់បង្ក្រាបថាជា "គ្រឹះស្ថានដ៏ធំសម្បើម" ដែលសុំសិទ្ធិបើកធ្វើជាហាងខារ៉ាអូខេ។ លោកបានបន្ថែមថា "យើងមិនបានដឹងថាមានអំពើពេស្យាចារកំពុងកើតឡើងនៅទីនោះទេ" ដោយលោកនិយាយថាទទួលបានតម្រុយពីអ្នកទម្លាយរឿងសម្ងាត់ជនជាតិចិននិងហ្វីលីពីន។ លោកនិយាយទៀតថា មានជនជាតិចិនដែលព្រួយបារម្ភ បានមករកពួកយើង ហើយប្រាប់ពួកយើងថា "អ្នកគួរតែពិនិត្យតាមហាងខារ៉ាអូខេទាំងនោះ"៕

# ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០

## អភិបាលរងខេត្តព្រៃវែង ចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយ សម្រាប់ការលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម

http://www.freshnewsasia.com/index.php/ 2020-01-13

**(ព្រៃវែង)៖** លោកស្រី លៀង ស្រីម៉ុល អភិបាលរងខេត្តព្រៃវែង និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយ ក្នុងចំណោមអាទិភាពជាច្រើន សម្រាប់ការលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម ក៏ដូចជាលើកកម្ពស់ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់មនុស្ស ព្រោះថា អំពើជួញដូរមនុស្ស ជាបទឧក្រិដ្ឋ ដែលជនល្មើសជួញដូរមនុស្ស បានប្រើគ្រប់កលល្បិចដើម្បីកេងប្រវ័ញ្ច រំលោភបំពានលើមនុស្សផងដែរ ដោយមិនខ្វាយខ្វល់ពីទុក្ខវេទនា និងអាយុជីវិតរបស់មនុស្សផងដែលចង់រស់រានជួបជុំគ្រួសារ និងសេចក្តីសុខដែរនោះ។

ការលើកឡើងបែបនេះរបស់លោកស្រី លៀង ស្រីម៉ុល នៅក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងទិវាជាតិលើកទី១៣ **«ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៩»** នៅព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ដែលមានការអញ្ជើញចូលរួម មន្ទីរអង្គភាពនានាជុំវិញខេត្ត កងកម្លាំងទាំងបី អង្គការដៃគូរ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សិស្សានុសិស្ស និងគរុសិស្ស ប្រមាណ៧០០នាក់។ លោកស្រីលៀង ស្រីម៉ុល បានបន្តថា អំពើជួញដូរមនុស្ស និងអំពើការធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសាកល ដែលនៅតែបន្តកើតមានអាស្រ័យកត្តា ចំនួន៣ គឺ៖ ការអប់រំសង្គម, ការអនុវត្តច្បាប់ និងការឆក់ឱកាសពីជនល្មើស។ រូបភាពនៃអំពើជួញដូរមនុស្ស មិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេតែក្នុងឆ្នាំកន្លងទៅក៏មានលេចចេញនូវបាតុភាពមួយចំនួនដែលមានទំនោរទៅអំពើជួញដូរសរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន ដែលហៅថា **«បទអន្តរកាវីរនៃអំពើពពោះជំនួស»**។ នេះជាកង្វល់ថ្មីទៀតដែលគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបាននឹងកំពុងតែដាក់វិធានការស៊ើបអង្កេតស្រាវជ្រាវ និងបង្ក្រាបជាបណ្តើរៗ ឱ្យបានទាន់ពេលវេលា និងសិក្សាអំពីបរិបទច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធបន្ថែមទៀត ដើម្បីជៀសវាងការជុះដាលនៃបទល្មើសដែលនាំ ឱ្យបង្កគ្រោះថ្នាក់កាន់តែច្រើនឡើង ដល់សង្គម និងមនុស្សគ្រប់វ័យ ។

លោកស្រីបានបញ្ជាក់ថា ស្ថិតក្នុងស្ថានភាពនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលមានការចូលរួមពីបណ្តាស្ថាប័ន ជាសមាជិកគ្រប់លំដាប់ថ្នាក់ ព្រមទាំងដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនានា បាននិងកំពុងរួមដៃគ្នា ធ្វើសកម្មភាពឥតឈប់ឈរ ប្រកបដោយការលះបង់ខ្ពស់ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងសម្តេចក្រឡាហោម ស ខេង ឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបន្តខិតខំពុះពារគ្រប់ឧបសគ្គ និងការលំបាកនានា ដើម្បីដោះស្រាយបញ្ហាដ៏ក្តៅគគុកនេះអស់ពីសមត្ថភាព៕

## ស្ត្រីជាប្រពន្ធពលករបារម្ភបញ្ហាបំណុលកាន់តែខ្លាំងក្រោយប្តីស្លាប់ពេលទៅធ្វើការងារនៅថៃ

https://vodkhmer.news/ លោក យុត សុគន្ធ ១៣ មករា ២០២០ ម៉ោង ២:៥៩ ល្ងាច

ក្រុមគ្រួសារសពរបស់ពលករខ្មែរម្នាក់ដែលស្លាប់ដោយសារឆក់ខ្សែភ្លើងពេលទៅបំពេញការងារ និងរស់នៅក្នុង ប្រទេសថៃកាលពីចុងសប្តាហ៍មុន អំពាវនាវសុំឲ្យអាជ្ញាធរកម្ពុជា និងថៃ ជួយឧបត្ថម្ភ ព្រោះថា ទន្ទឹមនឹងការរងទុក្ខសោកបាត់បង់ប្តី បញ្ហាបំណុលកំពុងដាក់បន្ទុកថែមមួយកម្រិតទៀត។ អ្នកស្រី ឡាក់ ចាន់រី នៅភូមិព្រៃខ្លា ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ប្រាប់វីអូឌីថា កាលពីថ្ងៃទី១១ ខែមករានេះ ស្វាមីអ្នកស្រីឈ្មោះ ឌាង ព្រហ្ម ហៅ

៥ន បានស្លាប់ដោយសារធក់ខ្សែភ្លើងពេលកំពុងស្នាក់នៅបន្ទប់ជួលមួយស្ថិតក្នុងស្រុកស៊ីរាឆា ខេត្តឈុនបុរី ប្រទេសថៃ។ អ្នកស្រី ឡាក់ ចាន់រី ឲ្យដឹងថា ក្រោយស្វាមីស្លាប់ភ្លាម អ្នកស្រីបានដឹកសពមកបូជានៅស្រុកកំណើតក្នុងខេត្តកំពង់ធំ ដោយពុំមានអាជ្ញាធរណាជួយមើលការខុសត្រូវ ឬឧបត្ថម្ភនោះទេ។

ស្ត្រីមេម៉ាយវ័យ២៩ឆ្នាំរូបនេះ រៀបរាប់ថា គ្រួសារអ្នកស្រីបានខ្ចីលុយពីធនាគារជាង១ម៉ឺនដុល្លារមកសង់ផ្ទះ ហើយអ្នកស្រី និងស្វាមីបានចំណាកស្រុកទៅធ្វើការងារនៅប្រទេសថៃរយៈពេល៦ឆ្នាំហើយ ដើម្បីរកលុយសងធនាគារវិញ។ អ្នកស្រីបញ្ជាក់ថា ដល់ពេលនេះប្ដីស្លាប់ចោលទៀត ធ្វើឱ្យបន្ទុកកាន់តែធ្ងន់ធ្ងរ។ អ្នកស្រីបន្ថែមថា៖ «**ពេលអត់ពីគាត់ទៅ ខ្ញុំនឹងទៅសុំការងារគេធ្វើកន្លែងចាស់វិញនៅប្រទេសថៃ ដើម្បីយកមកដោះស្រាយសងបំណុលគេ។ ព្រោះខ្ញុំជំពាក់ច្រើនណាស់។ ហើយគាត់ទៅចោលខ្ញុំទៀត។ ខ្ញុំមិននឹកស្មានថា ខ្លួនខ្ញុំធ្លាក់ខ្លួនដល់ថ្នាក់នេះទេ។ ខ្ញុំសូមលើកម្រាមដៃដប់សុំឲ្យអាជ្ញាធរពាក់ព័ន្ធជួយដល់គ្រួសារខ្ញុំផង**»។ អ្នកស្រី ឡាក់ ចាន់រី បញ្ជាក់ថា ក្រោយបុណ្យ៧ថ្ងៃរួចហើយ អ្នកស្រីនឹងធ្វើដំណើរទៅប្រទេសថៃវិញធ្វើការងារបន្ត ហើយទុកកូនម្នាក់ដែលរៀនដល់ថ្នាក់ទី៧ ឱ្យរស់នៅជាមួយសាច់ញាតិ។

មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃអង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា តាមផ្លូវច្បាប់នៅពេលដែលពលករមានគ្រោះថ្នាក់ការងារ ឬជួបឧបទ្ទវហេតុហូតដល់ស្លាប់ គឺពលករទាំងនោះត្រូវទទួលបានសំណងផ្សេងៗពីអាជ្ញាធរថៃ ដូចជា សំណងសម្រាប់ក្រុមគ្រួសារ សំណងសម្រាប់រៀបចំបុណ្យសព និងថ្លៃដឹកជញ្ជូន ជាដើម។ មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុករូបនេះបន្តថា ប្រសិនអាជ្ញាធរថៃមិនបានដោះស្រាយជូនទេ គឺតំណាងស្ថានទូត និងតំណាងកុងស៊ុលកម្ពុជា ត្រូវតែជួយសម្របសម្រួលពលករទាំងនោះទទួលបានសំណងផ្សេងៗ និងយុត្តិធម៌សម្រាប់ពួកគេ។ លោកបន្ថែម៖ «**ស្ថានទូតកម្ពុជាត្រូវតែចុះទៅសម្របសម្រួលកិច្ចការងារហ្នឹង ដោយជួយដឹកសពត្រឡប់មកធ្វើពិធីបុណ្យតាមប្រពៃណីរបស់ខ្មែរយើង។ ទី២ ត្រូវសម្របសម្រួលដាក់ពាក្យបណ្ដឹង ធ្វើយ៉ាងម៉េចឲ្យពលករទាំងអស់ហ្នឹង ទទួលបានយុត្តិធម៌ទាំងសំណង និងទាំងការទទួលខុសត្រូវរបស់ថៅកែចំពោះការធ្វេសប្រហែសដែលបណ្ដាលឱ្យពលករស្លាប់ជាដើមហ្នឹង**»។ លោក ឌី ថេហូយ៉ា ឲ្យដឹងទៀតថា តាមព័ត៌មានដែលទទួលបាន គឺពលករខ្មែរប្រមាណជា១០នាក់ដែលបម្រើការងារនៅប្រទេសថៃ បានជួបគ្រោះថ្នាក់ការងារស្លាប់ ហើយលោកថា ស្ថានទូតខ្មែរប្រចាំប្រទេសថៃមិនទាន់បានដើរតួនាទីល្អក្នុងការជួយសម្របសម្រួលដោះស្រាយនៅឡើយទេ។

អ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លោក ហេង សួរ មានប្រសាសន៍ថា ពលករដែលធ្វើការស្របច្បាប់តែងតែមានការធានារ៉ាប់រងពេលជួបគ្រោះថ្នាក់ការងារ។ អ្នកនាំពាក្យរូបនេះ បញ្ជាក់ថា ពេលមានគ្រោះថ្នាក់ការងារជាយថាហេតុដែលនាំឱ្យរបួស ពិការ ឬបាត់បង់ជីវិត គឺពលករទាំងនោះតែងតែទទួលបានការព្យាបាល និងសំណងទៅតាមច្បាប់នៃប្រទេសនីមួយៗ។ លោក ហេង សួរ បញ្ជាក់ថា ក្នុងករណីជាពលករពុំមានឯកសារត្រឹមត្រូវគឺ ទីប្រឹក្សាទទួលបន្ទុកពលករនៅតាមស្ថានទូតនានារបស់ក្រសួងការងារ និងស្ថានទូតប្រចាំប្រទេសនីមួយៗតែងតែជួបជាមួយក្រសួងទទួលបន្ទុកវិស័យការងារនៃប្រទេសនោះ ដើម្បីស្វែងរកសំណងជូនក្រុមគ្រួសារពលកររងគ្រោះថ្នាក់។

របាយការណ៍របស់ក្រសួងការងារបញ្ជាក់ថា ពលករខ្មែរជាង ១លាន ១សែននាក់ហើយ កំពុងធ្វើការនៅប្រទេសថៃ ដោយចំនួននេះ ក្រសួងមិនបានបង្ហាញពីតួលេខនៃអ្នកដែលទៅធ្វើការដោយខុសច្បាប់នោះទេ។ ចំណែកមន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា ប៉ាន់ប្រមាណថា ចំនួនពលករធ្វើការងារនៅប្រទេសថៃ អាចមានច្រើនជាងតួលេខរបស់ក្រសួង៕

# សហជីពការងារមកពីអាមេរិក ប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការ លើវិស័យការងារជាមួយកម្ពុជា ឱ្យបានប្រសើរឡើង

https://www.dap-news.com/national/ ByVNT108 Posted on January 13, 2020

ភ្នំពេញ៖ សហព័ន្ធសហជីពការងារអាមេរិក និងសភានៃអង្គការឧស្សាហកម្ម (AFL-CIO) បានបង្ហាញឆន្ទៈបន្តកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ក្នុងការជំរុញការធ្វើពាណិជ្ជកម្ម ផ្សារភ្ជាប់លក្ខខណ្ឌការងារ រវាងប្រទេសទាំងពីរ ឱ្យកាន់តែមានភាពល្អប្រសើរ រួមទាំងការចូលរួម ដោះស្រាយបញ្ហាវិវាទការងារ ដូចជាការពង្រឹងមន្ត្រីអធិការកិច្ច ការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីពជាដើម។

ការសម្តែងការពេញចិត្តនេះ ត្រូវបានធ្វើឡើង ក្នុងជំនួបពិភាក្សាការងារ រវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោកស្រី ខេតធី ហ្វេនហ្គោល (Cathy Feingold) នាយិកាផ្នែកកិច្ចការអន្តរជាតិ នៃសហព័ន្ធសហជីពការងារអាមេរិក និងសភានៃអង្គការឧស្សាហកម្ម (AFL-CIO) នារសៀលថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ នៅទីស្តីការក្រសួង។ នាឱកាសនោះ លោក អ៊ិត សំហេង បានលើកឡើងពីលទ្ធផល នៃកិច្ចសហប្រតិបត្តិការ ជួយជ្រោមជ្រែងដល់កម្ពុជា ពីសំណាក់សហរដ្ឋអាមេរិក តាំងពីឆ្នាំ១៩៩៧មក។ លោករដ្ឋមន្ត្រី អ៊ិត សំហេង បានបន្តថា ដើម្បីលើកកម្ពស់ និងសម្រួលដល់ការកសាង សមត្ថភាពរូបវន្ត និងស្ថាប័នក្នុងការបង្កើតសុខដុមរមនា នៅកន្លែងការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមជាមួយមជ្ឈមណ្ឌលអាមេរិកាំង សម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) បានចុះអនុស្សរណៈ នៃការយោគយល់គ្នា នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ក្នុងគោលបំណងបង្កើត នូវក្របខណ្ឌសហប្រតិបត្តិការ បច្ចេកទេសរវាងក្រសួង និង ACILS ក្នុងគោលដៅចូលរួមចំណែក ក្នុងការអនុវត្តគោលនយោបាយ ពាក់ព័ន្ធនឹងវិស័យការងារ ទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង។ ជាមួយគ្នានោះ លោករដ្ឋមន្ត្រីក៏បានថ្លែងអំណរគុណ ដល់សហជីព AFI-CIO តាមរយៈ ACILS ដែលបានចូលរួមលើកកម្ពស់ លក្ខខណ្ឌការងារនៅកម្ពុជា និងជំរុញការអនុវត្តការងាររបស់ ACILS ឱ្យស្របតាមអនុស្សរណៈ នៃការយោគយល់គ្នាខាងលើនេះ។

លោករដ្ឋមន្ត្រីបានជំរុញឱ្យ ACILS អនុវត្តកាតព្វកិច្ចការ ចុះបញ្ជីឱ្យស្របតាមច្បាប់ជាធរមាន ព្រមទាំងបន្តពង្រឹង កិច្ចសហប្រតិបត្តិការ រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយនឹងអង្គការ ACILS តាមរយៈ៖

- ការលើកកម្ពស់សមត្ថភាពសហជីពមូលដ្ឋាន
- ការផ្សព្វផ្សាយច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និងច្បាប់ស្តីពីរបបសន្តិសុខសង្គម
- ការពង្រឹងសមត្ថភាព មន្ត្រីផ្សះផ្សាវិវាទការងារ
- ការលើកកម្ពស់ភាពសុខដុមរមនា ក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងការលើកកម្ពស់កិច្ចសន្ទនាសង្គម
- ការពង្រឹងនិរន្តរភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

លោកស្រី ខេតធី ក៏បានបង្ហាញពីការពេញចិត្ត ចំពោះការធ្វើពាណិជ្ជកម្ម ផ្សារភ្ជាប់លក្ខខណ្ឌការងារ ដែលកម្ពុជា បាននិងកំពុងធ្វើជាមួយ សហរដ្ឋអាមេរិក និងបានប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការ ជាមួយកម្ពុជាបន្តទៀត ដើម្បីឱ្យការធ្វើពាណិជ្ជកម្ម ផ្សារភ្ជាប់លក្ខខណ្ឌការងារនេះ កាន់តែមានភាពល្អប្រសើរថែមទៀត។

គួរបញ្ជាក់ថា អង្គការ AFL-CIO ជាសហព័ន្ធសហជីពធំជាងគេ នៅសហរដ្ឋអាមេរិក ដែលមានទីស្នាក់ការកណ្តាល នៅទីក្រុងវ៉ាស៊ីនតោន។ ACILS មានវត្តមានដំបូងនៅកម្ពុជា នាចុងឆ្នាំ១៩៩៣ ក្រោមឈ្មោះថា Asian American Free Labor Institute (AAFLI)៕

# ឯកអគ្គរាជទូតស៊ុយអែតថ្មី ប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការលើវិស័យការងារជាមួយកម្ពុជាឱ្យកាន់តែប្រសើរ

http://www.cen.com.kh/archives/ January 14, 2020

(ភ្នំពេញ)៖ ឯកអគ្គរាជទូតស៊ុយអែតថ្មីប្រចាំនៅកម្ពុជា បានបង្ហាញការប្តេជ្ញាចិត្តក្នុងការបន្តកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យកាន់តែល្អប្រសើរជាងមុន ពិសេសលើគម្រោងអភិវឌ្ឍន៍ជាច្រើនដែលកំពុងអនុវត្តនៅកម្ពុជា។ លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០នេះ បានជួបពិភាក្សាការងារជាមួយលោកBjörn Häggmark ឯកអគ្គរាជទូតស៊ុយអែតថ្មីប្រចាំនៅកម្ពុជា ។ ទន្ទឹមនឹងគ្នានេះដែរ ភាគីទាំងពីរបានបង្ហាញការវាយតម្លៃលើកិច្ចសហប្រតិបត្តិការដ៏ល្អនាពេលកន្លងមក លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានសន្យាពង្រឹងនូវទំនាក់ទំនង កិច្ចសហប្រតិបត្តការដ៏ល្អនេះទៀតដើម្បីជួយអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាវិស័យដ៏សំខាន់មួយក្នុងការធានាបាននូវសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ និងការអភិវឌ្ឍសង្គម។

ជាមួយគ្នានេះ លោកឯកអគ្គរាជទូតស៊ុយអែតថ្មី បានប្តេជ្ញាបន្តគម្រោងទំនាក់ទំនងលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរវាងកម្ពុជា និងស៊ុយអែត ក្នុងនោះមានដូចជា គម្រោងអភិវឌ្ឍន៍ទាំងឡាយដែលធ្វើឡើងតាមរយៈអង្គការSIDA ដែលបានជួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមទាំងការបង្កើតមជ្ឈមណ្ឌលការងារនៅតាមបណ្តារាជធានី-ខេត្តនានា។ កម្ពុជាបាននឹងកំពុងបន្តការគាំទ្រយ៉ាងសកម្មដល់កិច្ចព្រមព្រៀងសកល (Global Deal) របស់រដ្ឋាភិបាលស៊ុយអែត ដែលជាគំនិតផ្តួចផ្តើមសាកល និងមានគោលបំណងក្នុងការដោះស្រាយរួមគ្នានូវបញ្ហាប្រឈមនានានៅក្នុងទីផ្សារការងារ និងជំរុញឱ្យមនុស្សគ្រប់រូបអាចទទួលបានផលប្រយោជន៍ពីសាកលភាវូបនីយកម្ម។ ជាការពិតណាស់ កិច្ចសន្ទនាសង្គមមិនមែនជាយន្តការថ្មីក្នុងការអនុវត្តការងារ ក្នុងការគ្រប់គ្រង និងដោះស្រាយនូវទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជានោះទេ។ កម្ពុជាបាននិងកំពុងប្រើប្រាស់យន្តការនេះក្នុងក្របខណ្ឌជាច្រើនដូចជា៖ យន្តការគ្រប់គ្រងរបស់បេឡាជាតិរបបសន្តិសុខសង្គម យន្តការនៃការដោះស្រាយវិវាទការងារ យន្តការនៃការចរចារកំណត់ប្រាក់ឈ្នួលអប្បបរមា និងនីតិវិធីនៃការតាក់តែងច្បាប់ និងគោលនយោបាយនានាដែលធ្វើឡើងដោយមានការពិភាក្សា និងចូលរួមពីត្រីភាគី។ល។

លោក អ៊ិត សំហេង លើកឡើងថា បន្ទាប់ពីកម្ពុជាបានផ្តល់ការគាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសាកលនេះ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តពង្រឹងការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព និងធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការធានាបាននូវលក្ខខណ្ឌការងារល្អប្រសើរ និងភាពសុខដុមក្នុងទំនាក់ទំនងវិជ្ជាជីវៈ។ ពង្រឹងការអនុវត្តច្បាប់ស្តីពីសហជីព ដើម្បីធានាបាននូវសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដែលតំណាងឱ្យសម្លេង និងឆន្ទៈពិតប្រាកដរបស់កម្មករនិយោជិត និងនិយោជក ក្នុងការការពារនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពួកគេ និងជាដៃគូសន្ទនាដ៏មានប្រសិទ្ធភាពក្នុងកិច្ចសន្ទនាសង្គម។ ពង្រឹងការអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាដែលជាក្របខ័ណ្ឌគតិយុត្តិរឹងមាំក្នុងការការពារប្រកបដោយនិរន្តរភាពនូវប្រាក់ឈ្នួលរបស់កម្មករនិយោជិត និងធានានូវការប្រើប្រាស់យន្តការចរចារត្រីភាគីតាមបែបប្រជាធិបតេយ្យក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត ដោយឈរលើលក្ខណៈវិនិច្ឆ័យបែបវិទ្យាសាស្ត្រ ដើម្បីភាពរីកចម្រើនទាំងអស់គ្នា។

ពង្រឹងយន្តការដោះស្រាយវិវាទការងារឱ្យកាន់តែមានប្រសិទ្ធភាព ទាំងនៅដំណាក់កាលផ្សះផ្សានៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការដោះស្រាយក្រៅប្រព័ន្ធតុលាការដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល សំដៅធានាបាននូវយុត្តិធ៌មការងារ កាត់បន្ថយបាននូវបញ្ហាប្រឈមរវាងនិយោជក និងកម្មករនិយោជិត ឬតំណាងរបស់

ពួកគេ ក៏ដូចជាបង្កើនភាពជឿជាក់មកលើប្រព័ន្ធដោះស្រាយវិវាទរវាងភាគីពាក់ព័ន្ធ ដែលកាន់តែធ្វើឱ្យវប្បធម៌នៃកិច្ចសន្ទនាសង្គមមានភាពរឹងមាំ។ បន្តពង្រឹងយន្តការអធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងភាពជឿជាក់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាបាននូវការគោរពលក្ខខណ្ឌការងារ និងសិទ្ធការងាររបស់កម្មករនិយោជិត និងនិយោជក ទប់ស្កាត់ ក៏ដូចជាបង្ការមិនឱ្យមានបញ្ហាផ្សេងៗដែលឈានទៅរកវិវាទ និងការតវ៉ានានា។

ជម្រុញការអនុវត្តន៍គោលនយោបាយគាំពារសិទ្ធិ និងផលប្រយោជន៍របស់ពលកររទេសន្តប្រវេសន៍ទាំងក្នុងក្របខណ្ឌជាតិ ក៏ដូចជាតំបន់ និងជាមួយប្រទេសពាក់ព័ន្ធដើម្បីការពារពលករកម្ពុជាដែលធ្វើការនៅបរទេស។ បន្តចូលរួមអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងរបបសន្តិសុខសង្គមឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការពង្រឹងយន្តការផ្លាស់ប្តូរការប្រឹក្សាគ្នារវាងអ្នកប្រើប្រាស់សេវា អ្នកគ្រប់គ្រង និងផ្តល់សេវា ក៏ដូចជាអ្នកដែលមានកាតព្វកិច្ចផ្តល់ការឧបត្ថម្ភសេវា។ និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាសំដៅគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ និងគាំពារវិស័យការងារ៕ ដោយៈកូឡាប

## ឃាត់ខ្លួនជនសង្ស័យ០២នាក់ អំពើជួញដូរមនុស្សឆ្លងដែន

http://cambodiapolice.com/policekh/ 10:58 pm 13 មករា 2020

ខេត្តកំពង់ចាម៖ ដោយអនុវត្តដីកាបង្គាប់អោយចាប់ខ្លួន លេខ៩៣៧ និង៩៣៨ របស់លោក រស់ សាម៉ីឌីចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។ នៅវេលាម៉ោង១៣និង១៥នាទី ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ព្រមទាំងកម្លាំងអធិការដ្ឋាននគរបាលស្រុកស្ទឹងត្រង់ បានសម្រេចឃាត់ខ្លួនជនសង្ស័យ០២នាក់ ពីបទនាំយកចេញដោយមិនស្របច្បាប់សំរាប់ឆ្លងដែន និងអំពើលក់ដូរមនុស្សសំរាប់នាំឆ្លងដែនដែលប្រព្រឹត្តនៅ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ ។

មន្ត្រីនគរបាលខេត្តកំពង់ចាមបានឲ្យដឹងថា៖ ជនសង្ស័យរួមមាន១/.ឈ្មោះ កាន គ្រីន ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ ។ ២/.ឈ្មោះ ឡាច ម៉ៅ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ (ទាំងពីរនាក់មានទីលំនៅក្នុង ភូមិស្រែវដ្តលឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម) ។ បច្ចុប្បន្នជនសង្ស័យទាំងពីរនាក់ ត្រូវបានសមត្ថកិច្ចប្រគល់ជូននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីអនុវត្តនីតិវិធីបន្ត ៕

## កងកម្លាំងនគរបាលវរៈព្រំដែនគោកលេខ៨១៩ សហការណ៍ល្បាតតាមខ្សែបន្ទាត់ព្រំដែន

http://cambodiapolice.com/policekh/ 10:30 am 13 មករា 2020

ខេត្តបាត់ដំបង៖ នៅថ្ងៃ អាទិត្យ ៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២០ អនុវត្តតាមអនុសាសន៍ដឹកនាំរបស់លោក ឧត្តមសេនីយ៍ទោ អ៊ុច សុខុន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ក៏ដូចមតិរបស់លោកឧត្តមសេនីយ៍ត្រី ពុំ ចាន់ ស្នងការរងផែនការងារវរៈព្រំដែនលោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលកាពារព្រំដែនគោកលេខ៨១៩ បានចាត់តាំង លោកអនុសេនីយ៍ឯក សាត់ ស៊ី សុផាន់ ណារិទ្ធិ នាយប៉ុស្តិ៍ព្រំដែនបឹងអូរជាង ដឹកនាំកម្លាំងសហការណ៍ជាមួយកម្លាំងកងខេមរភូមិន្ទ ចេញល្បាតណាត់ជួបជាមួយទាហានឈុតខ្មៅ ភាគី(ថៃ) កងរយលេខ៥៤៥ នៅចំណុចអូរព្រំដែន នៃភូមិសាស្ត្រទទួលខុសត្រូវ ក្នុងគោលបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ត្រួតពិនិត្យទប់ស្កាត់រាល់បទល្មើសគ្រប់ប្រភេទ ដែលលួចលបឆ្លងដែនខុសច្បាប់ ក្នុងភូមិសាស្ត្រ និងការរិតចំណងសាមគ្គីភាពរវាងកងកម្លាំងប្រដាប់អាវុធ

ក្នុងភូមិសាស្ត្រ ជាមួយភាគីកងកម្លាំងឈុតខ្មៅ(ថៃ) ក៏ដូចជាការផ្លាស់ប្តូរនូវរាល់ព័ត៌មានជូនគ្នាទៅវិញទៅមកដើម្បីរក្សាបាននូវសន្តិសុខ តាមខ្សែបន្ទាត់ព្រំដែនផងដែរ ៕

## ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២០

### ជប៉ុន កំពុងខិតខំប្រឹងប្រែង ទទួលយកកម្មសិក្សា ការីបច្ចេកទេសកម្ពុជា ទៅធ្វើការ

https://www.dap-news.com/national/ ByPH104 Posted on January 15, 2020

ភ្នំពេញ ៖ លោក អ៊ីម៉ាម៊ីរ៉ាក់ ម៉ាសាហ៊ីរ៉ុ សមាជិករដ្ឋសភា និងជាប្រធានសម្ព័ន្ធមិត្តភាពសភា ជប៉ុន-កម្ពុជា បានថ្លែងថា បច្ចុប្បន្នជប៉ុន កំពុងតែខិតខំប្រឹងប្រែង ចាត់វិធានការដើម្បីទទួលកម្លាំងពលកម្ម កម្លាំងកម្មសិក្សាការីបច្ចេកទេសកម្ពុជា ឲ្យមកធ្វើការនៅជប៉ុន ។

ក្នុងជំនួបពិភាក្សាការងារជាមួយ សម្តេច សាយ ឈុំ ប្រធានព្រឹទ្ធសភា នៅថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២០ លោក អ៊ីម៉ាម៊ីរ៉ាក់ ម៉ាសាហ៊ីរ៉ុ សង្ឃឹមថា តាមរយៈកម្មសិក្សាការីបច្ចេកទេសទាំងអស់នេះ នឹងទទួលចំណេះដឹងជាច្រើន អំពីបច្ចេកទេស វិជ្ជាជីវៈ របៀបគ្រប់គ្រងក្រុមហ៊ុន ការងារ ហើយនៅថ្ងៃអនាគត ពេលត្រឡប់ទៅប្រទេសកម្ពុជាវិញ នឹងយកជំនាញទាំងអស់នេះ ទៅជួយអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ឱ្យកាន់តែរីកចម្រើនថែមទៀ។ លោកមានប្រសាសន៍ថា"បច្ចុប្បន្ននេះប្រទេសជប៉ុនកំពុងតែខិតខំប្រឹងប្រែងចាត់វិធានការដើម្បីទទួលកម្លាំងពលកម្ម កម្លាំងកម្មសិក្សាការីបច្ចេកទេសរបស់ប្រទេសកម្ពុជា ឱ្យមកធ្វើការនៅប្រទេសជប៉ុន"។

ចំណែក សម្តេច សាយ ឈុំ បានឲ្យដឹងថា ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ត្រូវបានដំឡើងកម្រិតទំនាក់ទំនងកម្ពុជា-ជប៉ុន មានការីកចម្រើនឥតឈប់ឈរ ហើយបានត្រូវបានលើកម្ពស់ឱ្យទៅជាកិច្ចសហប្របតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រ នាពេលបច្ចុប្បន្ននេះ។ សម្តេចបន្តថា តាមរយៈនៃកិច្ចសហប្រតិបត្តិការថ្មីនេះ រដ្ឋាភិបាលនៃប្រទេសទាំងពីរកាន់តែទទួលបាននូវវឌ្ឍនភាពថ្មីៗជាច្រើន លើគ្រប់ វិស័យ រួមមាន៖ វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ ការចងសម្ព័ន្ធមេត្រីភាពរវាងខេត្ត ក្រុង ការផ្លាស់ប្តូរ ដ៏ទូលំទូលាយរវាងប្រជាជន និងប្រជាជន និងការគាំទ្រគ្នា ទៅវិញ ទៅមក ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ លើឆាកអន្តរជាតិ ។

ឆ្លៀតឱកាសនោះដែរ ប្រធានព្រឹទ្ធសភា ក៏បានស្នើគណៈប្រតិភូជួយផ្សព្វផ្សាយ និងលើកទឹកចិត្តអ្នកវិនិយោគ និងអ្នកទេសចរជប៉ុន មកបណ្តាក់ទុនវិនិយោគ និងធ្វើទេសចរណ៍ឱ្យកាន់តែច្រើនបន្ថែមទៀតនៅកម្ពុជា៕ ដោយ អេង ប៊ូឆេង

### លេខា គ.ខ.ប.ជ.ខេត្តកំពង់ឆ្នាំង បានរៀបចំអបអរសាទរទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://t.me/c/1200010743/156 កំពង់ឆ្នាំង 15-01-2020

ថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ដោយមានការគាំទ្រយកចិត្តទុកដាក់ខ្ពស់ និងការណែនាំចង្អុលទិស ពីឯកឧត្តម ឈួរចន្ទឿន អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ឆ្នាំង ក្រុមលេខាគខបជខេត្តកំពង់ឆ្នាំងបានរៀបចំអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ " បង្ហាញពីឆន្ទៈដ៏មុះមុតរបស់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់រូប ក្នុងការរួមគ្នាសហការគ្នា ដេើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស" ក្រោមអធិបតីភាព ឯកឧត្តម ឈួរ ច័ន្ទឿន អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើ

ជួញដូរមនុស្ស។ សមាសភាពអញ្ជើញចូលរួម ឯកឧត្តម ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត តំនាងសាលាតំបូង ស្ថាប័នអយ្យកា កម្លាំងប្រដាប់អាវុធទាំង៣ ថ្នាក់ដឹកនាំខេត្ត មន្ទីរ អង្គភាព ក្រុមប្រឹក្សា អភិបាល អភិបាលរងក្រុងស្រុក ទទួលការងារប្រយុទ្ធប្រឆាំងការជួញដូរ អធិការក្រុងស្រុកទាំង៨ ក្រុមយុវជន សហភាពសហពន្ធ័យុវជនកម្ពុជា សាខាសមាគមនារី យុវជនកាបាទក្រហម យុវជនស្រលាញ់សន្តិភាព សមាគមយុវជនមុស្លីមកម្ពុជា តំណាងសាសនា និងអង្គការសង្គមស៊ីវិល យុវជនកាយរិទ្ធ សរុប 200នាក់ នៅសាល«ខ»សាលាខេត្តកំពង់ឆ្នាំង ។

## អ្នកនាំពាក្យៈនៅមជ្ឈិមបូព៌ា មានពលករ និងនិស្សិតខ្មែរជាង២០០នាក់

https://thmeythmey.com/ 14, Jan 2020 , 9:39 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រាប់ថា បច្ចុប្បន្នពលករខ្មែរ មាន៦៨នាក់ ចំណែកលោក រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ យុវជន និង កីឡា ផ្តល់ព័ត៌មានថា និស្សិតខ្មែរនៅទីនោះ មាន១៤៩នាក់ ដែលកំពុងធ្វើការនិងសិក្សា តាមបណ្តាប្រទេសនានា នៅតំបន់មជ្ឈិមបូព៌ា ដូចជា អារ៉ាប៊ីសាអូឌីត អេហ្ស៊ីប និង រដ្ឋកូវ៉ែត ជាដើម។ អ្នកពាក្យទាំងពីរ សុទ្ធតែអះអាងថា កម្ពុជា មិនទាន់មានគម្រោងជម្លៀសពលករនិងនិស្សិតខ្មែរទាំងនោះចេញពីតំបន់បជ្ឈិមបូព៌ាទេ ដោយគ្រាន់តែបញ្ជាក់ថា បច្ចុប្បន្ន កម្ពុជា កំពុងតាមដានស្ថានភាពជម្លោះរវាងអាមេរិកនិងអ៊ីរ៉ង់នៅតំបន់បជ្ឈិមបូព៌ានេះយ៉ាងយកចិត្តទុកដាក់។

លោក រស់ សុវាចា ប្រាប់សារព័ត៌មានថ្មីៗ តាមបណ្តាញទំនាក់ទំនងតេឡេក្រាម កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ថា ក្រសួងអប់រំ បានបញ្ជូននិស្សិតខ្មែរ១១៦នាក់ ទៅសិក្សានៅប្រទេសអេហ្ស៊ីប និង៣៣នាក់ទៀត ទៅសិក្សានៅរដ្ឋកូវ៉ែត។ លោក បញ្ជាក់ដូច្នេះថា៖«ក្រសួងកំពុងបន្តយកចិត្តទុកដាក់កម្រិតខ្ពស់តាមដានស្ថានការណ៍ [នៅមជ្ឈិមបូព៌ា] នេះ»។

ចំណែកលោក ហេង សួរ ថ្លែងថា បច្ចុប្បន្ន ស្ថានការណ៍នៅមជ្ឈិមបូព៌ា មិនទាន់ឈានដល់ចំណុច ដែលត្រូវជម្លៀសពលករខ្មែរឡើយ។ ក្នុងកិច្ចសម្ភាសជាមួយសារព័ត៌មានថ្មីៗ តាមទូរស័ព្ទ កាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០២០ អ្នកនាំពាក្យក្រសួងការងារ និយាយបែបនេះថា៖ «ពលរដ្ឋកម្ពុជាទាំង៦៨នាក់នោះ ក្រសួងបានទាក់ទងជាមួយជាប្រចាំ តាមរយៈស្ថានអគ្គរាជទូតនៅទីនោះ ដោយឃើញថា មិនទាន់ដល់ចំណុចមួយ ដែលត្រូវជម្លៀសនៅឡើយទេ ព្រោះអារ៉ាប៊ីសាអូឌីតនៅឆ្ងាយពីចំណុចហានិភ័យមួយចំនួន។ ប៉ុន្តែក្រសួង និងរដ្ឋាភិបាល ជាពិសេសស្ថានទូតប្រចាំនៅតំបន់នោះ កំពុងតាមដានលើសភាពការនេះ»។ លោក បន្ថែមថា ពលករខ្មែរទាំង៦៨នាក់នោះ គឺជាអ្នកបំពេញការងារបម្រើការតាមផ្ទះ។

ជុំវិញរឿងនេះ សារព័ត៌មានថ្មីៗមិនអាចទាក់ទងលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានឡើយ ដោយសារតែលោក មិនលើកទូរស័ព្ទ។ យ៉ាងណា លោក ធ្លាប់លើកឡើងដូចអ្នកនាំពាក្យទាំងពីរខាងលើដែរថា រដ្ឋាភិបាល មិនទាន់មានគម្រោងជម្លៀសពលរដ្ឋខ្មែរចេញពីតំបន់មជ្ឈិមបូព៌ានោះទេ។ ថ្លែងប្រាប់សារព័ត៌មានថ្មីៗកាលពីថ្ងៃទី៧ ខែមករា អ្នកនាំពាក្យការបរទេស និយាយដូច្នេះថា៖«យើងមិនមានពលរដ្ឋច្រើនទេ ហើយក៏មិនមានផែនការជម្លៀសពលរដ្ឋចេញពីកន្លែងនោះដែរ ព្រោះយើងមានស្ថានទូតយើងប្រចាំប្រទេសកូវ៉ែត និងស្ថានទូតខ្មែរប្រចាំអេហ្ស៊ីប កំពុងយកចិត្តទុកដាក់តាមដានបញ្ហានេះ ដើម្បីដោះស្រាយឱ្យទាន់សភាពការណ៍»។

ស្របពេលដែលជម្លោះរវាងអាមេរិក និងអ៊ីរ៉ង់ កាន់តែអាក្រក់ ប្រទេសនៅតំបន់អាស៊ានមួយចំនួន ដូចជា ថៃ និងហ្វីលីពីន ជាដើម បានចេញមកប្រកាសពីគម្រោងជម្លៀសពលរដ្ឋពួកគេ ចេញពីតំបន់មជ្ឈិមបូព៌ា។ ប្រជាជនហ្វីលីពីនប្រមាណ៦ពាន់នាក់ មានវត្តមាននៅក្នុងអ៊ីរ៉ាក់ និង១,៦ពាន់នាក់នៅក្នុងអ៊ីរ៉ង់។ ពួកគេភាគច្រើន ជាអ្នកបម្រើការតាមផ្ទះ និងជាបុគ្គលិករបស់ក្រុមហ៊ុនអន្តរជាតិនានា។

ចំណែកប្រជាជនថៃ មាន២៥៧នាក់ ដែលកំពុងបម្រើការងារក្នុងប្រទេសអ៊ីរ៉ង់ និង ២៥នាក់ផ្សេងទៀត នៅក្នុងប្រទេសអ៊ីរ៉ាក់ ។ ភាគច្រើននៃពលករថៃទាំងនោះ បម្រើការងារក្នុងភោជនីយដ្ឋាន កន្លែងម៉ាស្សា និងអាជីវកម្មលក់សាច់ត្រី ជាដើម។ មេដឹកនាំប្រទេសទាំងពីរ កំពុងព្រួយបារម្ភពីសុវត្ថិភាពពលរដ្ឋខ្លួន និងស្នើឲ្យភាគីពាក់ព័ន្ធទាំងអស់នៃជម្លោះអាមេរិក និងអ៊ីរ៉ង់ មានអត់ធ្មត់ខ្ពស់ និងបញ្ចៀសការប្រើកម្លាំងក្នុងគោលដៅបន្ធូរបន្ថយភាពតានតឹង ព្រមទាំងរក្សាសន្តិភាពនិងស្ថិរភាពក្នុងតំបន់។

ជម្លោះនៅមជ្ឈិមបូព៌ា មានភាពសភាពកាត់តែធ្ងន់ធ្ងរ បន្ទាប់ពីអាមេរិក ធ្វើឃាតឧត្តមសេនីយ៍ Qasem Soleimani មេទ័ពរបស់អ៊ីរ៉ង់។ ជាការសងសឹក អ៊ីរ៉ង់ បានបាញ់មីស៊ីលបាលីស្ទិកជាង១០គ្រាប់ ទៅលើបន្ទាយឈរជើងអាមេរិកចំនួនពីរ ដែលតាំងនៅលើទឹកដីអ៊ីរ៉ាក់។ តែការបាញ់មីស៊ីលនេះ ពុំបានបង្កឲ្យទ័ពអាមេរិកណាម្នាក់បាត់បង់ជីវិតឡើយ៕

## ករណីពលករខ្មែរធ្វើការសំណង់ធ្លាក់ពីលើអគារ២ជាន់នៅក្នុងខេត្តរ៉ាក់យ៉ង

https://www.facebook.com/LabourOfficial/ 15/01/20

ប្រភពពីខេត្តរ៉ាក់យ៉ង ប្រទេសថៃ កាលពីថ្ងៃអង្គារ ទី១៤ ខែមករា ឆ្នាំ២០២០ ម្សិលមិញនេះបានអោយថាមានករណីបុរសពលករខ្មែរ វ័យ ៣០ឆ្នាំ មិនស្គាល់ឈ្មោះម្នាក់ បានរងគ្រោះថ្នាក់ធ្លាក់ពីលើអាគារសំណង់កំពុងសាងសង់មួយដែលមានកម្ពស់២ជាន់ នៅម្តុំតាឡាតរ៉យសៅ ស្ថិតក្នុងសង្កាត់បានភេរ ស្រុកមឿង ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ក្នុងហេតុការណ៍គ្រោះថ្នាក់នេះបណ្តាលបុរសពលករខ្មែរម្នាក់រងរបួស។ ក្រោយពេលកើតហេតុជនរងគ្រោះត្រូវបានអ្នកដើរលក់ឆ្នោត ប្រទះឃើញហេតុការណ៍ជួយទំនាក់ទំនងហៅរថយន្តសង្គ្រោះអោយដឹកយកទៅព្យាបាលនៅមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង រីឯមូលហេតុដែលបង្កឲ្យកើតគ្រោះថ្នាក់លើពលកររូបនេះ នៅមិនទាន់ដឹងច្បាស់នៅឡើយទេ។

## ជីវិតស្ត្រីមេម៉ាយចំណាកស្រុកមកធ្វើការក្នុងប្រទេសថៃ

https://www.facebook.com/LabourOfficial/ 14/01/20

លោកស្រី ម៉ៃ ពេញ អាយុ ៤៣ឆ្នាំ ជាស្ត្រីម៉េម៉ាយ មានកូនតូចប្រុសស្រី ចំនួន ០២នាក់ លោកស្រី មានកំណើតរស់នៅភូមិឈ្នួលមានជ័យ ឃុំឈ្នួលមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ លោកស្រីបានប្រាប់ក្រុមការងារស្មគ្រចិត្តក្នុងប្រទេសថៃ អោយដឹងថា ដោយសារតែជីវភាពគ្រួសារនៅឯប្រទេសកម្ពុជាលំបាក លោកស្រីនិងកូនតូចបានចំណាក់ស្រុកមកធ្វើការរស់នៅប្រទេសថៃ អស់រយៈពេលជាង ៤ឆ្នាំមកហើយ ។ លោកស្រី បានមកធ្វើការជាកម្មករវេចខ្ចប់ជូតកញ្ចក់នៅក្នុងខនដូមួយកន្លែងនៅស្រុកបាងឡាមុង ខេត្តឈុនបុរី ប្រទេសថៃ អំឡុងពេលគាត់ធ្វើការក្នុងប្រទេសថៃ គាត់ខិតខំប្រឹងប្រែងធ្វើការ ដើម្បីរកប្រាក់អោយកូនប្រុសស្រីរបស់ ចំនួន ០២នាក់របស់គាត់បានរៀនសូត្រក្នុងប្រទេសគេ ដូចកូនរបស់ពលរដ្ឋថៃ។

ប៉ុន្តែដោយសារការខំប្រឹងប្រែងធ្វើការធ្ងន់អស់រយៈពេលជាច្រើនរបស់លោកស្រីបានធ្វើអោយលោកស្រី មានជំងឺប្រចាំកាយដោយមិនដឹងខ្លួន នៅថ្ងៃមួយ លោកស្រី បានរអិលធ្លាក់ពី ជណ្តើរកម្ពស់ពីកាំ ធ្វើអោយជំងឺប្រចាំកាយលោកស្រី ដែលពួនក្នុងរាងកាយលោកស្រី ចាប់ផ្តើមបង្ហាញខ្លួនបន្តិចម្តងៗរហូតដល់លោកស្រីចាប់ផ្តើមក្រោកមិនរួចធ្វើការមិនកើតត្រូវបានមេការថៃ បញ្ជូនលោកស្រីទៅព្យាបាលនៅមន្ទីរពេទ្យ ក្រោយពីលោកស្រីសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ លោកគ្រូពេទ្យបានប្រាប់លោកស្រីថា ឆ្អឹងជេ◌ីងរបស់លោស្រី មានជំងឺវីរុសសុ◌ីឆ្អឹង ហើយបច្ចុប្បន្នឆ្អឹងជើងរបស់លោកស្រីត្រូវវីរុសស៊ីអស់មួយចំនួន ហើយកំពុងស្ថិតក្នុងដំណាក់កាលត្រូវព្យាបាលជាបន្ទាន់ បន្ទាប់មកលោកគ្រូពេទ្យបានធ្វើការវះកាត់លើកទីមួយបានធ្វើអោយលោកស្រីរាងធូរមួយកំរិត ។ ប៉ុន្តែលោកស្រីមិនអាចធ្វើ

ការកើតដូចមុនទៀតទេ និងស្ថានភាពព្យាបាលបន្តនៅកំណាក់កាលទី២ គឺតម្រូវអោយលោកស្រី ត្រូវវះកាត់ផ្លាស់ប្តូរឆ្អឹង ហើយចំណាយក្នុងការវះកាត់ផ្លាស់ប្តូរឆ្អឹងនេះមានតម្លៃរាប់ម៉ឺនបាត អាចឈានដល់សែនបាត ។

ដោយសារតែលោកស្រីមិនអាចធ្វើការបានដូចមុនក្រុមហ៊ុនដែលជួលអោយស្រីធ្វើការសម្រេច ឈប់ជួលស្រីអោយធ្វើការបន្ត ដោយក្រុមហ៊ុនព្រមផ្តល់ប្រាក់សំណងមួយចំនួន តាមច្បាប់ការងារ ជូនដល់ស្ត្រី ប៉ុន្តែប្រាក់នេះមិនគ្រប់គ្រាន់សម្រាប់លោកស្រីយកទៅប្រកបរបរចិញ្ចឹមជីវិតតទៅមុខទៀតបានទេ។ បន្ទាប់ពីថៅកែលោកស្រីសម្រេចឈប់ជួលស្រីបន្ត ឯកសារទិដ្ឋការស្នាក់នៅរបស់លោកស្រី ក៏ជិតផុតសុពលភាពនៅក្នុងប្រទេសថៃផងដែរ។ លោកស្រីបានរៀបរាប់ទាំងទឹកភ្នែកថា ប្រសិនគាត់ត្រូវវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ ជីវិតគាត់និងលំបាកណាមួយកូនរបស់គាត់ចង់រៀនបន្តនៅក្នុងប្រទេសថៃ នៅឯប្រទេសកម្ពុជា គាត់គ្មានផ្ទះសម្បែងរស់នៅនោះទេ ដោយអាស្រ័យរស់នៅលើដីរបស់មីងជីដូនមួយ បណ្តោះអាសន្នប៉ុណ្ណោះ ។

ចំពោះករណីរបស់លោកស្រី ម៉ៃ ពើញ អជ្ញាធរសង្គមកិច្ចថៃនិងបណ្តាញអង្គការសង្គមស៊ីវិលនានាក្នុងខេត្តឈុនបុរីកំពុងពិភាក្សាគ្នាស្វែងរកជំនួយដើម្បីជួយអន្តរាគមន៍ដល់លោកស្រី និងកូនប្រុសស្រី ដើម្បីបង្កើតមុខរបរអោយលោកស្រីនៅវិលត្រលប់ទៅប្រទេសកម្ពុជាវិញនាខាងមុខ។

## មន្ត្រីស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួបសំណេះសំណាល និងពន្យល់ណែនាំ ដល់បងប្អូនពលករខ្មែរ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok January 13 at 8:57 PM •

នាថ្ងៃច័ន្ទ ៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ មន្ត្រីស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួបសំណេះសំណាល និងពន្យល់ណែនាំ ដល់បងប្អូនពលករខ្មែរ អំពីសេវាបញ្ជាក់លិខិតស្នាមនៅស្ថានទូត ច្បាប់ការងារនៅក្នុងប្រទេសថៃ សិទ្ធិនិងអត្ថប្រយោជន៍ដែលបងប្អូនពលករអាចទទួលបាន ព្រមទាំងការស្នើសុំជំនួយពីស្ថានទូតក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។

# ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២០

## អភិបាលខេត្តកំពង់ឆ្នាំងអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវរួមសហការគ្នាទប់ស្កាត់រាល់អំពើជួញដូរមនុស្សពិសេសស្ត្រីនិងកុមារ

https://grandnewsasia.com/ 16-01-2020

កំពង់ឆ្នាំង៖ លោក ឈួរ ច័ន្ទឿន អភិបាលខេត្តកំពង់ឆ្នាំង បានអំពាវនាវបែបនេះនាព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំងក្នុងពិធីប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខួបលើកទី១៣ ក្រោមប្រធានបទ «បង្ហាញពីឆន្ទះដ៏មុះមុតរបស់រាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋគ្រប់រូប ក្នុងការរួមសហការគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស» ។ ពិធីនេះមានការចូលរួមពីលោកស្រី ប៊ិន សុភី អភិបាលរងខេត្តនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោក អម សុភា អភិបាលរងខេត្ត សមាជិក ក្រុមប្រឹក្សាខេត្ត ប្រធានអង្គភាពជុំវិញខេត្ត សមាជិកគ.ខ.ប.ជ ខេត្តក្រុងស្រុកទាំង៨ តំណាងអង្គការក្រៅរដ្ឋាភិបាល ស.ស.យ.ក យុវជនកាកបាទក្រហម កាយឫទ្ធិ សមាគមនារី យុវជនស្រឡាញ់សន្តិភាពសរុបចំនួន២០០នាក់។

លោកស្រី ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងថា អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសកលដែលនៅតែបន្ត

កើតមាន អាស្រ័យដោយកត្តាសំខាន់៣ គឺការអប់រំសង្គម ការអនុវត្ត ច្បាប់ និងការធេក់ឱកាសពីជនល្មើស។រូបភាពអំពើជួញដូរ មនុស្សមិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ កន្លងទៅក៏មានលេចចេញបាតុភាពមួយចំនួនដែលទំនោរទៅរកអំពើជួញដូរសេរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារក ក្រោមរូបភាពដែលហៅថា អំពើជួលពរពោះជំនួសទៀតផងដែលនេះជាកង្វល់ថ្មីមួយទៀតដែលចាំបាច់ត្រូវ មានវិធានការស៊ើបអង្កេតស្រាវជ្រាវ និងបង្រ្កាបឲ្យបានទាន់ពេលវេលា៕

## បញ្ជូនជនប្រុស-ស្រី ២ នាក់ ទៅតុលាការពាក់ព័ន្ធនាំមនុស្សទៅចិន

https://www.postkhmer.com/ គឹម សារុំ | Publication date 16 January 2020 | 13:08 ICT

**ភ្នំពេញៈ** ជនប្រុស-ស្រី ២ នាក់ ត្រូវបានសមត្ថកិច្ចបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញកាលពីថ្ងៃទី ១៤ មករា ក្រោយពីចាប់ខ្លួនបាន ១ ថ្ងៃ តាមដីការបស់តុលាការនៅភូមិត្រពាំងឈូក ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមពាក់ព័ន្ធនឹងការនាំនារីខ្មែរទៅប្រទេសចិន ដោយខុសច្បាប់ដែលបានប្រព្រឹត្តនាខែកក្កដាឆ្នាំមុន។

លោកឧត្តមសេនីយ៍ទោ ប៉ាក យូលាង អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនប្រាប់កាលពីថ្ងៃទី ១៤ មករា ថា ជនសង្ស័យប្រុស-ស្រី ២ នាក់នោះ ឈ្មោះ កាន គ្រីន ភេទស្រី អាយុ ៣០ ឆ្នាំ និងឈ្មោះ ឡាច ម៉ៅ ភេទប្រុស អាយុ ២៩ ឆ្នាំ ពួកគេរស់នៅភូមិស្រែរំដួល ឃុំជងក្ដារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ជនសង្ស័យទាំង ២ ពាក់ព័ន្ធនឹងបទល្មើសនាំស្ត្រីខ្មែរឆ្លងដែនខុសច្បាប់ទៅប្រទេសចិននោះ គឺខាងនាយកដ្ឋានរបស់លោកអនុវត្តតាមដីកាចាប់ខ្លួនរបស់តុលាការដែលបង្គាប់ឲ្យចាប់ខ្លួន ដោយលោក រស់ សាមុីឌី ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។ លោកថ្លែងថាៈ «រឿងនោះខ្ញុំមិនដឹងថា ក្រុមជនសង្ស័យនាំមនុស្សខុសច្បាប់ឆ្លងដែនទៅប៉ុន្មាននាក់ទេ។ តែខាងខ្ញុំបានបញ្ជូនពួកគាត់ទៅតុលាការហើយនៅថ្ងៃនេះ (ថ្ងៃទី ១៤ មករា)»។

អ្នកនាំពាក្យសាលាដំបូងរាជធានីភ្នំពេញលោក គុជ គឹមឡុង មិនអាចទាក់ទងសុំអត្ថាធិប្បាយបានទេពីម្សិលមិញ។

ដោយឡែកលោកស្រី អៀម វណ្ណី ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាមទទួលផែនការប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនប្រាប់នៅថ្ងៃទី ១៤ មករា ថា ជនសង្ស័យទាំង ២ នាក់ខាងលើគឺកម្លាំងសមត្ថកិច្ចគ្រាន់តែសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សក្នុងនាមអាជ្ញាធរដែនដីប៉ុណ្ណោះ។ «ករណីនេះខ្ញុំមិនដឹងថា ពួកគេនាំមនុស្សប៉ុន្មាននាក់ទេ ខ្ញុំគ្រាន់ដឹងថាពាក់ព័ន្ធនាំស្ត្រីខ្មែរទៅរៀបការប្ដីនៅប្រទេសចិន»។

លោក ប៉ាក ជាតិ អធិការស្រុកស្ទឹងត្រង់ប្រាប់ដែរថា នៅវេលាម៉ោង ១៣ និង ១៥ នាទី ថ្ងៃទី ១៣ ខែមករា សមត្ថកិច្ចនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរួមទាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការនគរបាលខេត្តកំពង់ចាមសហការជាមួយកម្លាំង សមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកស្ទឹងត្រង់បានឃាត់ខ្លួនជនសង្ស័យ ២ នាក់តាមដីកាដែលការចាប់នេះធ្វើឡើងនៅទីកន្លែងដូចរៀបរាប់ខាងលើ។ ជនទាំង ២ នាក់ពាក់ព័ន្ធពីបទនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន និងអំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែនដែលប្រព្រឹត្តនៅឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមកាលពីថ្ងៃទី ៩ ខែកក្កដាឆ្នាំមុន។

ទោះយ៉ាងណាមិនមានប្រភពណាមួយបញ្ជាក់ឲ្យដឹងពីចំនួនស្ត្រីខ្មែរប៉ុន្មាននាក់ ដែលត្រូវបានគេនាំយកឆ្លងដែន ដោយខុសច្បាប់ទៅប្រទេសចិននោះទេ។ ករណីជួញដូរមនុស្សនេះត្រូវបានលោកស្រី ជីម ណារិន មន្ត្រីសម្របសម្រួលនៃសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តកំពង់ចាមបញ្ជាក់ថា សកម្មភាពនៃអំពើជួញដូរមនុស្សនៅខេត្តកំពង់ចាមបានកក្រើកខ្លាំងនៅអំឡុងឆ្នាំ ២០១៤ តែលោកស្រីមិនបានចាំតួលេខទេ។ ប៉ុន្តែសកម្មភាពជួញដូរ

បានថយចុះជាបណ្ដើរៗដោយនៅក្នុងឆ្នាំ ២០១៩ កន្លងមកមានតែ ២ ករណីប៉ុណ្ណោះ ដែលបានកើតឡើងក្នុងខេត្តមួយនេះ។

លោកស្រី ណារិន បញ្ជាក់ថា៖ «ដោយសារតែពេលស្ត្រីដែលចង់ទៅចិន គាត់ទៅធ្វើលិខិតបញ្ជាក់នៅសាលាឃុំហើយពេលនោះមន្ត្រីឃុំពន្យល់ពួកគាត់ពីបញ្ហាប្រឈមនានាក្នុងប្រទេសចិន។ អ៊ីចឹងវាថយចុះចំនួនអ្នកទៅចិនហើយមេខ្យល់ក៏អត់ហ៊ានបោកដែរ»៕

## មន្ត្រីស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួបសំណេះសំណាល និងពន្យល់ណែនាំ ដល់បងប្អូនពលករខ្មែរ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok 15-01-2020

នាថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ មន្ត្រីស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួបសំណេះសំណាល និងពន្យល់ណែនាំ ដល់បងប្អូនពលករខ្មែរ អំពីសេវាបញ្ជាក់លិខិតស្នាមនៅស្ថានទូត ច្បាប់ការងារនៅក្នុងប្រទេសថៃ សិទ្ធិនិងអត្ថប្រយោជន៍ដែលបងប្អូនពលករអាចទទួលបានបម្រាមទោសបញ្ញត្តិនិងការស្នើសុំជំនួយពីស្ថានទូតក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។

## កម្លាំង អជ្ញាធរ ខេត្ត សាមុតប្រាកាន ឃាត់ ខ្លួន ពលករ ខុស ច្បាប់ ចំនួន ២៦ នាក់កំពុង លួច ធ្វើ ការ ខុស ច្បាប់ ដោយ គ្មាន ប័ណ្ណ អនុញ្ញាត ការងារ

https://www.facebook.com/LabourOfficial/ 16/01/20

ប្រភពពីខេត្តសាមុតប្រាកាន ប្រទេសថៃ កាលពីថ្ងៃពុធទី១៥ ខែមករា ឆ្នាំ២០២០ ម្សិលមិញបានអោយថាកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ ខេត្តសាមុតប្រាកាន បានចុះឃាត់ខ្លួនពលករចំណាកស្រុកខុសច្បាប់ប្រុសស្រី ចំនួន ២៦នាក់ ខណៈពេលដែលពលករខុសច្បាប់ទាំងនោះកំពុងលួចធ្វើការខុសច្បាប់ នៅក្នុងរោងចក្រមួយកន្លែងស្ថិតនៅក្នុងស្រុកថាប់ផាដែង ខេត្តសាមុតប្រាកាន ប្រទេសថៃ។ តាមការបញ្ជាក់របស់សមត្ថកិច្ចពលករខុសច្បាប់ ទាំងអស់នោះត្រូវសមត្ថកិច្ចបញ្ជូនយកទៅធ្វើប្រវត្តិរូបនៅអធិការដ្ឋានតម្រួតស្រុកថាប់ផាដែង ដើម្បីដំណើរការតាមនីតិវិធីច្បាប់មុននិងបញ្ជូនទៅប្រទេសរបស់ពួកគេវិញ។

## ទីប្រឹក្សាទទួលបន្ទុកពលករនៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុនបានជួបសំណេះសំណាលសួរសុខទុក្ខ កម្មសិក្សាការីចំនួន៣៦នាក់

https://www.facebook.com/Labourcounsellorinjapan/ Labour Counsellor in Japan 16-01-2020

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ទីប្រឹក្សាទទួលបន្ទុកពលករនៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុនបានជួបសំណេះសំណាលសួរសុខទុក្ខ កម្មសិក្សាការីចំនួន៣៦នាក់ ដែលកំពុងធ្វើការងារកសិកម្មនៅខេត្ត Aichi និងពន្យល់អំពីបទបញ្ញត្តិពាក់ព័ន្ធ នឹងផលវិបាកនៃការរត់គេចពីកន្លែងធ្វើការងារ ទៅធ្វើការខុសច្បាប់នៅកន្លែងផ្សេង និងនីតិវិធីដើម្បីប្រែក្លាយពីកម្មសិក្សាការី ទៅជាពលករជំនាញ។ ប្រសិនបើបងប្អូនមានចម្ងល់ ឬបញ្ហាការងារ សូមទាក់ទងមកស្ថានទូតដើម្បីប្រឹក្សាយោបល់ និងស្វែងរកដំណោះស្រាយ។

## ករណី គ្រោះថ្នាក់ ចរាចរណ៍ នៅខេត្ត ប៉ាធុមថានី មាន ពលករ ខ្មែរ ០៧នាក់

https://www.facebook.com/LabourOfficial/ 16/01/20

ប្រភពពីខេត្តប៉ាធុមថានី ប្រទេសថៃបានអោយដឹងថា មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានឡើងកាលពីយប់ថ្ងៃពុធ ទី១៥ ខែមករា ឆ្នាំ២០២០ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះ មានពលករខ្មែរកំពុងធ្វើដំណើរក្នុងរថយន្តនេះរងរបួសធ្ងន់ និងស្រាលចំនួន០៨នាក់ ក្នុងនោះមានជនជាតិថៃម្នាក់។ ឈ្មោះ ជនរងគ្រោះ ៖

១.ឈ្មោះ រ៉ន ឌី ភេទ អាយុ៣០ឆ្នាំ ស្រុកកំណើតរស់នៅខេត្តបាត់ដំបង

២.ឈ្មោះ បារាំង ភេទប្រុស អាយុ៣០ឆ្នាំ ស្រុកកំណើតរស់នៅ ខេត្តបន្ទាយមានជ័យ

៣.ឈ្មោះ ងែក ភេទប្រុស អាយុ៤០ឆ្នាំ ស្រុកកំណើត រស់នៅខេត្តបន្ទាយមានជ័យ

៤.ឈ្មោះ ចន ភេទប្រុស អាយុ២៧ឆ្នាំ ស្រុកកំណើត រស់នៅខេត្តបន្ទាយមានជ័យ

៥.ឈ្មោះ ពយ ភេទប្រុស អាយុ៣៦ឆ្នាំ ស្រុកកំណើត រស់នៅខេត្តបន្ទាយមានជ័យ

៦.ឈ្មោះ យន់ ភេទប្រុស អាយុ ៣៨ឆ្នាំ ស្រុកកំណើត រស់នៅខេត្តបន្ទាយមានជ័យ

៧.ឈ្មោះ ហុង ភេទប្រុស អាយុ ២២ឆ្នាំ ស្រុកកំណើត រស់នៅខេត្តបន្ទាយមានជ័យ (របួសធ្ងន់)

៨.អ្នក បើកបររថយន្ត ជាជនជាតិ ថៃ (របួសធ្ងន់)

តាមការបញ្ជាក់ពីសាច់ញាតិជនរងគ្រោះបានអោយដឹងថា ពលករខ្មែរទាំងអស់ធ្វើការនៅផ្សារតាឡាតថៃស្ថិតក្នុងខេត្តប៉ាធុមថានី បច្ចុប្បន្នពលករខ្មែរដែលរងគ្រោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យថាំសាតរ៉ាំងសិត,មន្ទីរពេទ្យថាន់យ៉ាក់ប៊ុរីខ្លែងសងប៉ាធុមថានី,មន្ទីរពេទ្យបាងកករ៉ាំងសិត មូលហេតុបង្កឲ្យកើតគ្រោះថ្នាក់ចរាចរណ៍លើនេះគឺបណ្តាលមកពីរថយន្តដាច់ចង្កូតទៅបុកនិងបង្គោលភ្លើង ។

# ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២០

## Grab ដំណើរការកម្មវិធីលើកកម្ពស់សេដ្ឋកិច្ចជនពិការ និងកម្មវិធីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា

https://thmeythmey.com/ 17, Jan 2020 , 11:29 am ដោយ: ថ្មីៗ

ភ្នំពេញ-កម្ពុជា៖ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២០ - Grab (ហ្គ្រេប) ដែលជាកម្មវិធីហៅយានជំនិះលើទូរសព្ទដៃឈាន មុខគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានប្រកាសដាក់ឲ្យដំណើរការគំនិតផ្តួចផ្តើមចំនួនពីរក្នុងប្រទេសកម្ពុជាក្រោម កម្មវិធីទំនួលខុសត្រូវសង្គមឈ្មោះថា "Grab for Good" ដែលជាការប្តេជ្ញាចិត្តដ៏ធំសម្បើមមួយដើម្បីផ្តល់ផលវិជ្ជមានដល់សង្គម និងសេដ្ឋកិច្ចតាមរយៈបច្ចេកវិទ្យា។ ពិធីប្រកាសនេះធ្វើឡើងក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឯកឧត្តម អ៊ឹង សម្បត្តិ អគ្គលេខាធិការរងនៃក្រុមប្រឹក្សាសកម្មភាពជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លោកជំទាវ តិមា វិច្ឆិកាល អនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា លោក Russel Cohen ប្រធានផ្នែកប្រតិបត្តិការប្រចាំតំបន់Grab លោក Nick Beresford អ្នកតំណាងប្រចាំប្រទេសកម្ពុជានៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP។

លោក Hashim Alkaff នាយកក្រុមហ៊ុន Grab ប្រចាំកម្ពុជាបានមានប្រសាសន៍ថា៖ « ក្រុមហ៊ុន Grab (ហ្គ្រេប) ប្តេជ្ញាលើកកម្ពស់ការពង្រឹងប្រព័ន្ធឌីជីថលឲ្យមានភាពងាយស្រួល និងការទំនាក់ទំនងសម្រាប់ប្រជាពលរដ្ឋក្នុង តំបនអាស៊ីអាគ្នេយ៍ទាំងអស់។ ថ្ងៃនេះនៅក្នុងប្រទេសកម្ពុជា យើងដាក់ឲ្យដំណើរការគំនិតផ្តួចផ្តើមចំនួន

ពីរ ដោយប្រើប្រាស់ផលិតផល និងសេវាបច្ចេកវិទ្យារបស់យើង។ យើងចង់អោយមនុស្សគ្រប់គ្នា ដោយមិនគិតពីសាវតា ឬសមត្ថភាព ដើម្បីមានលទ្ធភាពទទួលបានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ និងមានសន្តិភាពផ្លូវចិត្តនៅពេលពួកគេប្រើ ប្រាស់ផលិតផល និងសេវារបស់យើង»។

កម្មវិធី បញ្ចប់ភាពស្ងៀមស្ងាត់ ៖ ការផ្តល់សិទ្ធិអំណាចដល់ក្រុមមនុស្សថ្លង់ កម្មវិធីបញ្ចប់ភាពស្ងៀមស្ងាត់របស់ Grab គឺជាគំនិតផ្តួចផ្តើមមួយដែលនឹងធ្វើឱ្យកម្មវិធី Grab កាន់តែងាយស្រួលស្វែងរក និងពង្រីកឱកាស ដើម្បីផ្តល់ឱកាសរកប្រាក់ចំណូលឲ្យបានកាន់ច្រើន សម្រាប់ក្រុមមនុស្សថ្លង់។ Grab ក្នុងប្រទេសកម្ពុជា នឹងធ្វើការជាមួយអង្គការកម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ (DDP) និង កម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ (UNDP) នៅកម្ពុជា ដើម្បីស្វែងយល់បន្ថែម អនុវត្ត និងតស៊ូមតិ ដើម្បីអនុវត្តឲ្យកាន់តែប្រសើរ ដើម្បីគាំទ្រដល់ក្រុមជនពិការ។ កម្មវិធីទាំងនេះរួមបញ្ចូលទាំងការផ្ញើសារភ្លាមៗ ដើម្បីប្រាប់អ្នកដំណើរថាដៃគូបើកបររបស់គាត់គឺជា មនុស្សថ្លង់ ហើយណែនាំពួកគេឱ្យប្រើប្រាស់កម្មវិធី GrabChat និងសន្លឹកកាតទំនាក់ទំនងដែលមានស្រាប់ក្នុងយានយន្ត។ Grab ក៏នឹងចាប់ផ្តើមយុទ្ធនាការអប់រំសាធារណៈ និងកម្មវិធីការបណ្តុះបណ្តាលបន្ថែម និងផ្តល់សម្ភារៈសម្រាប់ ដៃគូបើកបរដែលជាមនុស្សថ្លង់។ ការកែលម្អបន្ថែមទៀតលើកម្មវិធីនេះនឹងត្រូវប្រកាសនៅចុងឆ្នាំនេះ។

លោក គង់ សុវណ្ណឡឺ ដៃគូបើកបរ Grab ដែលជាមនុស្សថ្លង់បានបញ្ជាក់ថា៖ «ដំបូងខ្ញុំមានការព្រួយបារម្ភក្នុងការធ្វើជាដៃគូបើកបរ Grab ពីព្រោះរ៉ឺម៉កកង់បីថ្លៃណាស់ ហើយខ្ញុំមិនប្រាកដថាខ្ញុំអាចមានលទ្ធភាពបង់រំលស់ប្រចាំខែបានទេ។ តែទោះយ៉ាងណាដ៏ដោយ ខ្ញុំទទួលបានការលើកទឹកចិត្តពីក្រុមគ្រួសារ និងមិត្តភក្តិឱ្យចុះឈ្មោះ ធ្វើជាដៃគូបើករ៉ឺម៉កកង់បីជាមួយ Grab ។ ឥឡូវនេះ ខ្ញុំសប្បាយចិត្តនឹងប្រាក់ចំណូលដែលខ្ញុំយកមកផ្ទះ ហើយក៏ អាចឲ្យខ្ញុំរ៉ាប់រងបង់ថ្លៃរ៉ឺម៉កប្រចាំខែរបស់ខ្ញុំបានផងដែរ»។ កម្មវិធីប្រឆាំងការជួញដូរមនុស្ស៖ ប្រយុទ្ធប្រឆាំងអំពើហឹង្សានៅកម្ពុជា គំនិតផ្តួចផ្តើមធំទី ២ ប្រកាសដោយក្រុមហ៊ុន Grab កម្ពុជា គឺកម្មវិធីបណ្តុះបណ្តាលសម្រាប់ដៃគូបើកបរដើម្បីលើកកម្ពស់ការយល់ដឹងអំពីការជួញដូរមនុស្ស។ ក្នុងភាពជាដៃគូជាមួយអង្គការប្រឆាំងការជួញដូរមនុស្ស ដូចជា អង្គការ Liberty Shared Cambodia និង អង្គការបណ្តាញទូរស័ព្ទជំនួយកុមារនៅកម្ពុជា Grab នឹងធ្វើការបណ្តុះបណ្តាលតាមអ៊ីនធឺណិត តាមរយៈកម្មវិធីក្នុងទូរស័ព្ទចល័ត និងការបណ្តុះបណ្តាលផ្ទាល់ក្នុង ថ្នាក់រៀន ដល់ដៃគូបើកបរចំនួន ១០ ០០០ នាក់ក្នុង ខែមិថុនា ឆ្នាំ ២០២០ ។

លោក ស៊ាន សុខផៃ នាយកប្រតិបត្តិបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាបានមានប្រសាសន៍ថា៖ «ខ្ញុំពិតជាចាប់អារម្មណ៍ខ្លាំងចំពោះយុទ្ធសាស្ត្រការងារដែលក្រុមហ៊ុន Grab ដាក់ចេញ ដើម្បីបណ្តុះបណ្តាល និងលើកទឹកចិត្តដល់ដៃគូបើកបររបស់ខ្លួនឲ្យរាយការណ៍អំពីសញ្ញាណាមួយអំពី ការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភបំពាន។ ក្រុមការងារអង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាទន្ទឹងរងចាំសហការជាមួយក្រុមហ៊ុន Grab ហើយក៏បានដាក់ឲ្យដំណើរការបណ្តាញទូរស័ព្ទឥតគិតថ្លៃជាប្រចាំ (២៤/២៤ម៉ោង) យើងអាចចូលរួម ការហៅទូរស័ព្ទ ឬទទួលរបាយការណ៍ពីដៃគូអ្នកបើកបរផងដែរ។ ទន្ទឹមនឹងនេះ យើងនឹងចំណាយពេលវេលា និងការខិតខំបន្ថែមទៀត ដើម្បីធានាថាដៃគូបើកបរទាំងអស់ទទួលបានការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ ដើម្បីចេះវាយតម្លៃ និងរាយការណ៍ពីសកម្មភាពគួរឱ្យសង្ស័យណាមួយ»។

លោក Hashim Alkaff នាយកក្រុមហ៊ុន Grab ប្រចាំកម្ពុជាបានមានប្រសាសន៍នៅក្នុងកម្មវិធី និងបានកត់សំគាល់ថា សុវត្ថិភាព និងសន្តិសុខគ្រប់ទម្រង់ទាំងអស់ត្រូវបាន "ផ្សារភ្ជាប់ទៅក្នុង DNA (ឌីអិនអេ) របស់ក្រុម Grab" ។ លោកបានបន្ថែមទៀតថា ៖ «ដោយសារតែយើងពង្រីកបណ្តាញរបស់យើងពាសពេញ ក្នុងតំបន់ រួមទាំងក្នុងប្រទេសកម្ពុជាផងដែរ យើងដឹងច្បាស់ថាដៃគូបើកបររបស់យើងអាចមិនដឹងអំពីការទាក់ទង រវាងអ្នកជួញដូរ និងជនរងគ្រោះ នៅតាមព្រលានយន្តហោះ ស្ថានីយរថភ្លើង ឬស្ថានីយឡានក្រុងនោះទេ។ នេះជាមូលហេតុដែលយើង

មានការប្តេជ្ញាយ៉ាងរឹងមាំក្នុងភាពជាដៃគូដ៏សកម្មជាមួយ អង្គការ Liberty Shared និងអង្គការបណ្តាញទូរស័ព្ទជំនួយកុមារ ដើម្បីស្វែងរកដោះស្រាយ និងបង្វឹកដៃគូបើកបរឱ្យចេះវាយតម្លៃសកម្មភាព សង្ស័យ និងឆ្លើយតបឱ្យបានត្រឹមត្រូវ»។

ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបាន ស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមនានាពីក្រុមហ៊ុន Grab និងបានអំពាវនាវ ឲ្យក្រុមហ៊ុនជាច្រើនផ្សេងទៀតអនុវត្តតាមការដឹកនាំរបស់ក្រុមហ៊ុន Grab ផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាតែងតែកោតសរសើរ និងលើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋ ហើយ ក្រុមហ៊ុន Grab បានខិតខំប្រឹងប្រែងអនុវត្តកម្មវិធីទំនួលខុសត្រូវសង្គម តាមរយៈការដាក់ឲ្យដំណើរការកម្មវិធីនាថ្ងៃនេះជាលើកដំបូងនៅកម្ពុជា ហើយក៏ជាកម្មវិធីដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជាក្នុងចំណោមទីផ្សារផ្សេងទៀត (១) កម្មវិធីបញ្ឈប់ភាព ស្ងៀម ស្ងាត់ – ដែលជាកម្មវិធីរបស់ Grab សម្រាប់អ្នកគថ្លង់ ដើម្បីស្វែងរកប្រាក់ចំណូល និង (២) កម្មវិធីប្រឆាំងការជួញ ដូរមនុស្ស។ ក្រសួងសាធារណការ និងដឹកជញ្ជូនមានភាពជាដៃគូដ៏រឹងមាំជាមួយក្រុមហ៊ុន Grab តាមរយៈគម្រោង SUMAI ដែលមានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ជាសហដៃគូ និងក៏ទន្ទឹងរង់ចាំសហការលើកម្មវិធីផ្សេងៗ ទៀតដែលផ្តល់អត្ថន័យដល់សង្គមកាន់តែច្រើនពីក្រុមហ៊ុន Grab នាពេលអនាគត។

លោក Nick Beresford អ្នកតំណាង UNDP បានមានប្រសាសន៍ថា៖ « អង្គការ UNDP មានមោទកភាពក្នុង ការធ្វើការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រុមហ៊ុន Grab ក្នុងគម្រោង SUMAI (សម័យ) របស់យើង ក្នុងគោលបំណងធ្វើឱ្យប្រព័ន្ធដឹកជញ្ជូនឲ្យកាន់តែមានសុវត្ថិភាព និងកាន់តែបៃតងសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់។ ជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា យើងកំពុងតែពិនិត្យមើលប្រព័ន្ធទិន្នន័យ គ្រោះថ្នាក់ចរាចរណ៍។ ដោយទទួលបានការយល់ដឹងអំពីបញ្ហាកាន់តែប្រសើរឡើង ដែលយើងអាចរៀបចំគោលនយោបាយ និងកម្មវិធីដែលមានប្រសិទ្ធិភាពបន្ថែមទៀតក្នុងការសង្គ្រោះជីវិត និងការពារអ្នកប្រើប្រាស់ផ្លូវគោកឲ្យល្អប្រសើរជាងមុន។ យើងចង់ឃើញប្រព័ន្ធដឹកជញ្ជូនផ្តល់សុវត្ថិភាពសម្រាប់មនុស្សគ្រប់គ្នា ហើយត្រៀមខ្លួនរួចរាល់ដើម្បី បង្ហាញដំណោះស្រាយការងារល្អៗ សម្រាប់ទាំងអ្នកដំណើរ និងអ្នកបើកបរជាជនពិការផងដែរ»៕

## បុរសជនជាតិចិនម្នាក់ ចាប់នារីខ្មែរចងដៃរុំក្រណាត់ជុំវិញខ្លួន លើកដាក់គូទរថយន្តបើករត់ តែសមត្ថកិច្ចចាប់ជាប់

http://www.freshnewsasia.com/ 2020-01-17

**(ភ្នំពេញ)៖** បុរសជនជាតិចិនម្នាក់ បានចាប់នារីខ្មែរចងដៃរុំក្រណាត់ដាក់គូទរថយន្ត បើករត់តែសំណាងល្អសមត្ថកិច្ចឃាត់ទាន់ ដែលហេតុការណ៍នេះ បានកើតឡើងនៅវេលាម៉ោងជាង៩យប់ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ នៅចំណុចផ្ទះសំណាក់មួយកន្លែង តាមបណ្តោយផ្លូវជាតិលេខ៦A ស្ថិតក្នុងសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ប្រភពព័ត៌មានពីកន្លែងកើតហេតុបានប្រាប់ឲ្យដឹងថា នៅមុនពេលកើតហេតុគេបានឃើញជនជាតិចិនម្នាក់ បានចាប់បីនារីជនជាតិខ្មែរម្នាក់ ដោយមានសភាពដៃជាប់ចំណង និងរុំក្រណាត់ជុំខ្លួនលើកយ៉ាងប្រញាប់ប្រញាល់ ដាក់ក្នុងគូទរថយន្តមួយគ្រឿងម៉ាក TOYOTA CAMRY 2007 ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AV-8491 ដោយបើកចេញពីផ្ទះសំណាក់មួយកន្លែង ដែលមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦A ដែលស្ថិតក្នុងសង្កាត់ព្រែកលៀប។ ភ្លាមៗនោះអ្នកឃើញហេតុការណ៍ បានទូរស័ព្ទទៅសមត្ថកិច្ចជំនាញ ដើម្បីឲ្យចេញអន្តរាគមន៍ តាមចាប់រថយន្តខាងលើ។ មិនយូរប៉ុន្មានកម្លាំងអធិការខណ្ឌជ្រោយចង្វារ បានចេញគ្រប់គោលដៅតាមចាប់រថយន្តខាងលើ បាននៅម្តុំផ្លូវមាត់ទន្លេរួចកម្លាំងអន្តរាគមន៍ បានបើករថយន្តខាងលើ ក៏ប្រទះឃើញនារីរងគ្រោះ ក្នុងគូទរថយន្ត

រួចធ្វើការទាក់ទងទៅរថយន្តសង្គ្រោះបន្ទាន់ ដឹកបញ្ជូនទៅសង្គ្រោះភ្លាមៗ នៅឯមន្ទីរពេទ្យកាល់ម៉ែត្រផងដែរ។ ក្រោយពេលកើតហេតុសមត្ថកិច្ច បានដឹកជនសង្ស័យខាងលើទៅអធិការខណ្ឌជ្រោយចង្វារ ដើម្បីសាកសួរ និងចាត់វិធានការទៅតាមផ្លូវច្បាប់៕

## ពលករខ្មែរ៦នាក់ ត្រូវតម្រួតថៃឃាត់ខ្លួន នៅខេត្តប៉ាក់យ៉ង ពីបទប្រើប្រាស់គ្រឿងញៀន

http://kampucheathmey.com/ 17/1/2020 9:54 Am

ប្រទេសថៃ ៖ ក្រុមយុវវ័យដែលជាពលករខ្មែរចំនួន ៦ នាក់ ដែលបម្រើការងារនៅក្នុងខេត្ត ប៉ាក់យ៉ង ប្រទេសថៃ ត្រូវបានក្រុមតម្រួតថៃចាប់ខ្លួន រួមជាមួយនឹងវត្ថុតាងមួយចំនួនផងដែរ បន្ទាប់ពីសមត្ថកិច្ចថៃបានរកឃើញថា ជនសង្ស័យទាំង ៦ នាក់នេះ កំពុងប្រើប្រាស់គ្រឿងញៀន ព្រមទាំងមានផ្ទុកនូវសារជាតុញៀនក្នុងខ្លួន ទាំងអស់គ្នាថែមទៀតផង។

យោងតាមប្រភពព័ត៌មានពីគេហទំព័រ pathumthaninews បានបញ្ជាក់ថា កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២០ សមត្ថកិច្ចថៃ ប្រចាំខេត្តប៉ាក់យ៉ង បានធ្វើការឃាត់ខ្លួនយុវជនខ្មែរចំនួន០៦នាក់ នៅចំណុច ភូមិ១សង្កាត់តាសិត ស្រុកប៉ុកដែង ខេត្តប៉ាក់យ៉ង ប្រទេសថៃ ដែលពាក់ព័ន្ធនឹងបទល្មើសលួចប្រមូលផ្តុំគ្នា ប្រើប្រាស់គ្រឿងញៀនខុសច្បាប់។ ប្រភពព័ត៌មានដដែលបានបន្តថា ជនសង្ស័យដែលត្រូវសមត្ថកិច្ចថៃឃាត់ខ្លួននោះរួមមាន ១.ឈ្មោះ អៀ កាន ភេទប្រុស អាយុ ២៦ឆ្នាំ ២.ឈ្មោះ ហួត អៀ ភេទប្រុស អាយុ ២៧ឆ្នាំ ៣.ឈ្មោះ អៀង តុលា ភេទប្រុស អាយុ ៣០ឆ្នាំ ៤.ឈ្មោះ សៃ យ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ៥.ឈ្មោះ ម៉ៅ តន ភេទប្រុស អាយុ ២៤ឆ្នាំ និង ៦.ឈ្មោះ ហឿង ដុម ភេទប្រុស អាយុ ២៨ឆ្នាំ ទាំងអស់គ្នាស្នាក់នៅក្នុងភូមិ សង្កាត់ ខាងលើ។

តាមការបញ្ជាក់របស់សមត្ថកិច្ចថៃ បានឲ្យដឹងថា នៅក្នុងកិច្ចប្រតិបត្តិការនោះ សមត្ថកិច្ច បានរឹបអូសវត្ថុតាងមានម៉ូតូម៉ាកហុងដាង ចំនួន០៦គ្រឿង និង ថ្នាំញៀនប្រភេទវីនមីន ចំនួន ០៤បន្ទះ រួមជាមួយនឹង លិខិតបញ្ជាក់លទ្ធផល នៃសារជាតុញៀនក្នុងរាងកាយដែលចេញដោយវេជ្ជបណ្ឌិត នៃមន្ទីរពេទ្យប៉ុកដែង ខេត្តប៉ាក់យ៉ង ផងដែរ។ បច្ចុប្បន្នគេនៅមិនទាន់ដឹងថា តើពួកគេទាំងអស់នោះ ត្រូវបានសមត្ថកិច្ច ខេត្តប៉ាក់យ៉ង ឃុំខ្លួន ឬក៏ត្រូវអប់រំ និងធ្វើកិច្ចសន្យាបញ្ជូនទៅកាន់មណ្ឌលកែប្រែនោះទេ៕ **សោ និយមរ័ត្ន**

## ឃាត់ខ្លួនពលរដ្ឋខ្មែរចំណាក់ស្រុកខុសច្បាប់ ០២នាក់ ក្នុងខេត្តអយុធ្យា

https://www.facebook.com/LabourOfficial/ 16/01/20

ប្រភពពីខេត្តអយុធ្យាប្រទេសថៃកាលពីថ្ងៃពុធ ទី១៥ ខែមករា ឆ្នាំ២០២០ ម្សិលមិញនេះបានអោយថា កម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ខេត្តអយុធ្យា បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ ចំនួន ០២នាក់ នៅត្រង់ចំណុចភូមិប៉ាម៉ាកផ្លាវ សង្កាត់ហួរ៉ ស្រុកអយុធ្យា ខេត្តអយុធ្យា ប្រទេសថៃ ។ ពលរដ្ឋខ្មែរខុសច្បាប់ដែលត្រូវកម្លាំងសមត្ថកិច្ចថៃឃាត់ខ្លួនមានដូចតទៅ៖

១.ឈ្មោះ ធឹង ឡា ភេទប្រុស អាយុ ៥១ឆ្នាំ គ្មានលិខិតឆ្លងដែន

២.ឈ្មោះ ធឹង ឡឹង ភេទស្រី អាយុ ៤១ឆ្នាំ គ្មានលិខិតឆ្លងដែន

បច្ចុប្បន្នពលរដ្ឋខ្មែរខុសច្បាប់ទាំង០២នាក់ ត្រូវសមត្ថកិច្ចអន្តោប្រវេសន៍ថៃកសាងសំណុំរឿងដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## មានករណីបុរសពលករខ្មែរម្នាក់ចងកសម្លាប់ខ្លួននឹងដើមស្ពៅនៅខេត្តនុនថាក់បុរី

https://www.facebook.com/LabourOfficial/ 16/01/20

ប្រភពពីខេត្តនុនថាក់បុរី ប្រទេសថៃបានអោយថាមានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ ជឿប ភេទប្រុស អាយុ ២៥ឆ្នាំ មុខរបរជាកម្មករសំណង់ធ្វើការនៅក្នុងខេត្តនុនថាក់បុរី បានចងកសម្លាប់ខ្លួននៅនឹងដើមស្ពៅក្បែរព្រៃវាលស្រែមួយកន្លែង ស្ថិតនៅក្នុងភូមិ២ សង្កាត់បាងផ្លាប ស្រុកប៉ាក្រេត ខេត្តនុនថាក់បុរី ប្រទេសថៃ ។ ប្រភពពីបងប្រុសជនរងគ្រោះបានប្រាប់ថាជនរងគ្រោះប្រហែលជាតូចចិត្ត និងប្រពន្ធនៅឯប្រទេសកម្ពុជា ពីព្រោះជនរងគ្រោះបានទៅទូរស័ព្ទទៅផ្ទះប៉ុន្តែប្រពន្ធមិនលើកដោយកំពុងជាប់រវលចូលរួមក្នុងពីធីជប់លៀងគេអានធ្វើឲ្យជនតូចចិត្ត។

បច្ចុប្បន្នសាកសពជនរងគ្រោះ ត្រូវបានសមត្ថកិច្ចបញ្ជូនយកទៅធ្វើកោសល្យវិច័យនៅមន្ទីរពេទ្យថាមសាតមុនប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។

# ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២០

## អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរ២នាក់រួចផុតទោស ឲ្យមកស្រុកខ្មែរ វិញ

http://nokorwatnews.com/ 19-01-2020

ខេត្តឧត្តរមានជ័យ ៖ ប្រជាពលរដ្ឋខ្មែរចំនួន២នាក់ត្រូវបានអាជ្ញាធរប្រទេសថៃបានបញ្ជូនមកឱ្យភាគីកម្ពុជាវិញបន្ទាប់ពីបុរសទាំង២នាក់ ត្រូវបានដោះលែងពីពន្ធនាគារខេត្តស៊ីសាកេតប្រទេសថៃពីបទឆ្លងដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃរួចមក ។ ពិធីប្រគល់ និងទទួលប្រជាពលរដ្ឋខ្មែរនេះបានធ្វើឡើងកាលពីវេលាម៉ោង ១៦ និង១៥នាទីថ្ងៃទី១៨ខែមករាឆ្នាំ២០២០ស្ថិតនៅច្រកអន្តរជាតិជាំស្រងាំក្នុងទឹកដីស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ ។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំបាននិយាយថា ប្រជាពលរដ្ឋខ្មែរចំនួន២នាក់ដែលត្រូវបានអាជ្ញាធរថៃបញ្ជូនមកស្រុកកំណើតវិញនោះគឺមានឈ្មោះ សៀង ស្រស់ ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅភូមិសម្បួយឃុំព្រៃគុយស្រុកកំពុងស្វាយខេត្តកំពង់ធំ ។ ម្នាក់ទៀតឈ្មោះនួនសុភ័ក្រភេទប្រុសអាយុ៣១ឆ្នាំរស់នៅភូមិអូរឃុំសង្វើយស្រុកជីក្រែងខេត្តសៀមរាប ។ អ្នកទាំង២ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៦ខែមករាឆ្នាំ២០១៨ កន្លងមកនេះ ពីបទដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃដោយចូលតាមច្រកភ្នំខ្មោច ។

ក្រោយពីចាប់ខ្លួនអ្នកទាំង២ត្រូវបែនយកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតចាប់តាំងពីពេលនោះរហូតមកដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ទើបដោះលែងហើយបញ្ជូនមកស្រុកកំណើតវិញ ៕ ប៉ែន នួន

## សូមចូលរួមរំលែកទុក្ខផងពលករម្នាក់ទៀតហើយ បានស្លាប់បាត់បង់ជីវិតដោយសារតែ

http://khosja.com/ January 18, 2020

មនុស្សម្នាក់ៗគ្មាននរណាចង់ចាកឆ្ងាយពីគ្រួសារខ្លួនឯងនោះទេ តែមកពីជីវភាពក្នុងគ្រួសារមានការខ្វះខាតគ្មានជម្រើស ទើបត្រូវសំរេចចិត្តបែបនេះ ចាកឆ្ងាយពីប្រទេសកំណើតខ្លួន ហើយទៅនៅប្រទេសដទៃដែលខ្លួនមិនស្គាល់សោះដើម្បីរកលុយ ទាំងដែលត្រូវជួបនូវបញ្ហាលំបាក ការប្រមាថជា ន់ឈ្លីជាដើមនោះ។

សូមកុំគិតថា អ្នកដែលបានមកធ្វើការនៅប្រទេសជប៉ុន គឺជាមនុស្សដែលមានសំណាងអោយសោះ ការងារជាកម្មករគេ គឺមិនមែនមកកើបលុយ ហើយក៏មិនមែនដេកយកតែលុយដែរ មុននិងបានលុយផ្ញើរទៅអោយអ្នកផ្ទះ ២០០ដុល្លារ ទៅដល់ ១០០០ដុល្លារ សម្រាប់ចាយនោះ គឺគេបានយកជី វិតដែលប្រថុ យប្រថា នទៅប្តូរវាមក។ ក្រៅពីការងារអ្នកដែលធ្វើការងារនៅជប៉ុន ត្រូវប្រឈម និងបញ្ហាមួយចំនួនដូចជា ការហូបចុក កត្តាអាកាសធាតុ (រ

ដូវក្តៅ និងរដូវធ្លាក់ព្រិល) គ្រោះថ្នាក់ក្នុងម៉ោងការងារដោយយថាហេតុណាមួយ ដែលទាំងអស់នេះហើយ គឺជាមូលហេតុយ៉ាងចំបង ដែលសុទ្ធសឹងតែធ្វើអោយបាត់ ប ង់ ជី វិត បានគ្រប់ពេលវេលាតែម្តង។

យ៉ាងណាមិញពលករជប៉ុនម្នាក់ទៀតហើយបានស្លាប់បាត់បង់ជីវិត យ៉ាងអាណោចអាធ័មដោយសារតែជំងឺទឹកក្នុងខួរ នេះបើយោងតាមរយៈគណនីហ្វេសប៊ុកឈ្មោះ Khen Chanthou បានមានការរៀបរាប់ឲ្យដឹងថា៖«យ៉ាហែងសន្យាមួយអញម៉េចខ្លះហា មិចបានហែងភ្លេចចឹង ហែងថាចាំហែងមកវិញចាំអោយគ្នាការប្តី អញនៅចាំហែងមកវិញហើយថាហែងនិងមកវិញ ចុះលូវម៉េចបានហែងទៅចោលគ្នាចឹងមិត្តភ័ក្រ អញនឹកស្មានមិនដល់សោះថាហែងជួបរឿងបែបនេះ ម៉េចបានហែងចិត្តដាច់ម៉េសទៅគ្មានប្រាប់អញអីមួយម៉ាត់បើមានជាតិក្រោយមែនពិតសូមកុំអោយហែងជួបរឿងបែបហ្នឹងទៀតណាមិត្តភ័ក្រ អញយាយអត់ចេញទេគិតថាវាមិនគួរមិនគួណាជាហែងសោះវាថ្មីៗពេក កាងារស្រុកគេហែងចង់ធ្វើណាស់ ចុះឥលូវនេះមែនលទ្ធផលដែលហែងទទួលបាន»។

## ពលករខ្មែរម្នាក់ធ្លាក់ពីលើអាគារសំណង់កម្ពស់៥ជាន់បណ្តាលស្លាប់ភ្លាមៗនិងកន្លែងកើតហេតុ

https://www.facebook.com/LabourOfficial/ 19/01/20

ប្រភពពីសាច់ញាតិជនរងគ្រោះបានអោយថាបុរសពលករខ្មែរម្នាក់ឈ្មោះ នី ភេទប្រុស អាយុ ២៦ឆ្នាំ ស្រុកកំណើតរស់នៅភូមិស្រម៉ ឃុំព្រៃញ្ជៅ ស្រុកពារាំង ខេត្តព្រៃវែង មុខរបរជាពលករធ្វើការសំណង់នៅក្នុងប្រទេសថៃ បានរងគ្រោះថ្នាក់ធ្លាក់ពីលើអាគារសំណង់កំពុងសាងសង់មួយកន្លែង ស្ថិតក្នុងតំបន់ចែងវ៉ាត់ណាក់ ខេត្តនុនថាក់បុរី ប្រទេសថៃ កាលពីម៉ោង០១:១៥នាទី កាលថ្ងៃសៅរ៍ ទី១៨ ខែមករា ឆ្នាំ២០២០ ម្សិលមិញនេះ ក្នុងហេតុការណ៍គ្រោះថ្នាក់នេះបណ្តាលឲ្យជនរងគ្រោះស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ ក្រោយពេលកេីតហេតុកម្លាំងសមត្ថកិច្ចថៃបានចុះអន្តរាគមន៍ដល់កន្លែងកើតហេតុភ្លាមៗផងដែរ។

## ឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ បានចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម ចាទុមង្គល សោណាគុន រដ្ឋមន្ត្រីក្រសួងការងារថៃ

https://www.facebook.com/LabourOfficial/ 17/01/20

ឯកឧត្តម អ៊ូក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ អមដោយមន្ត្រីការទូតកម្ពុជា បានចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម ចាទុមង្គល សោណាគុន រដ្ឋមន្ត្រីក្រសួងការងារថៃ នៅទីស្តីការក្រសួងការងារថៃ។

-ស្នើសុំបញ្ចុះតម្លៃទិដ្ឋាការស្នាក់នៅពី ១៩០០បាត ទៅ ៥០០បាត ចំពោះពលករដែលត្រូវបន្តសុពលភាពស្នាក់នៅ និងធ្វើការរបស់ពលករកម្ពុជា មុនថ្ងៃ៣១ ខែមីនា ឆ្នាំ២០២០។

-លើកលែងទិដ្ឋាការចេញចូលក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនៅខែមេសា ឆ្នាំ២០២០ខាងមុខនេះ

-សម្របសម្រួលបង្កើតមជ្ឈមណ្ឌលគាំពារពលករកម្ពុជានៅតាមបណ្តាខេត្ត នៅក្នុងប្រទេសថៃ។

-បន្តពង្រឹងកិច្ចសហការ ដើម្បីឱ្យការបន្តសុពលភាពស្នាក់នៅ និងធ្វើការរបស់បងប្អូនពលករកម្ពុជាទាំងអស់ទទួលបានជោគជ័យ ដោយបងប្អូនពលករកម្ពុជាទាំងអស់ទទួលបានឯកសារស្របច្បាប់ធ្វើការនៅក្នុងប្រទេសថៃ។

## ពលករខ្មែរគ្រោះថ្នាក់ធ្លាក់ពីលើដំបូលអគារកំពុងសាងសង់កម្ពស់៥ម៉ែត្រ

https://www.facebook.com/LabourOfficial/ 17/01/20

ករណីគ្រោះថ្នាក់ធ្លាក់ពីលើដំបូលអគារកំពុងសាងសង់កម្ពស់៥ម៉ែត្រ កាលពីម៉ោង០៥:៣០នាទី នាល្ងាចថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០២០ នៅខេត្តត្រាត ប្រទេសថៃ ជនរងគ្រោះត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យខេត្តត្រាត ។ សូមបងប្អូនពលករខ្មែរដែលធ្វើការការងារសំណង់សូមមេត្តាប្រុងប្រយ័ត្ននៅពេលបំពេញការងារ កុំភ្លេចធ្វើជានារ៉ាប់រងសង្គមអោយបានគ្រប់គ្នា។

## ស្ថានឯកអគ្គរាជទូត បានជួយដោះស្រាយបញ្ហាប្រាក់ខែ និងលក្ខខណ្ឌការងារដល់កម្មសិក្សាការីផ្នែកកាត់ដេរចំនួន15រូប ដោយជោគជ័យ

https://www.facebook.com/ Labour Counsellor in Japan **January 18 at 7:27 AM** ·

នៅថ្ងៃទី17 ខែមករា ឆ្នាំ2020 ស្ថានឯកអគ្គរាជទូត បានជួយដោះស្រាយបញ្ហាប្រាក់ខែ និងលក្ខខណ្ឌការងារដល់កម្មសិក្សាការីផ្នែកកាត់ដេរចំនួន15រូប ដោយជោគជ័យ។ ស្ថានទូតសូមអំពាវនាវដល់ ប្អូនៗកម្មសិក្សាការី ក៏ដូចជាពលករជំនាញ ប្រសិនបើជួបប្រទះបញ្ហានៅកន្លែងធ្វើការ ឬមានចម្ងល់ពាក់ព័ន្ធនឹងការងារ សូមទាក់ទងមកស្ថានទូត ដើម្បីប្រឹក្សាយោបល់ និងស្វែងរកដំណោះស្រាយ។

# ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២០

## អភិបាលខេត្តកំពង់ធំ អំពាវនាវស្ថាប័នពាក់ព័ន្ធទាំងអស់ ជួយផ្សព្វផ្សាយអំពីកលល្បិចជនល្មើស លួងលោម បោកបញ្ឆោត ការជួញដូរមនុស្ស ឲ្យបានទូលំទូលាយទៅដល់មូលដ្ឋាន និងសាលារៀន

http://www.freshnewsasia.com/ 2020-01-20

**(កំពង់ធំ)៖** លោក សុខ លូ អភិបាលខេត្តកំពង់ធំ អំពាវនាវដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ ជួយផ្សព្វផ្សាយអំពីកលល្បិចជនល្មើស លួងលោមបោកបញ្ឆោតការជួញដូរមនុស្ស ឲ្យបានទូលំទូលាយទៅដល់មូលដ្ឋាននិងសាលារៀន។ លោកបានថ្លែងយ៉ាងដូច្នេះ នៅក្នុងពិធីអបអរសាទរទិវាជាតិលើកទី១៣ ប្រយុទ្ធទាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៩ នាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ នៅសាលាខេត្តកំពង់ធំ ដោយមានការអញ្ជើញចូលរួមពីប្រធានអង្គភាពមន្ទីរជុំវិញខេត្ត មន្ត្រីរាជការនិងសិស្សានុសិស្សជិត ៥០០នាក់។ លោក សុខ លូ ក្នុងនាមជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ បានលើកឡើងថា អំពើជួញដូរមនុស្ស គឺជាបទឧក្រិដ្ឋ ដែលជនល្មើសធ្វើការជួញដូរមនុស្ស ដោយប្រើប្រាស់គ្រប់កលល្បិច គ្រប់រូបភាព ដើម្បីកេងប្រវ័ញ្ច រំលោភបំពានលើមនុស្ស ដោយមិនខ្វាយខ្វល់ពីទុក្ខវេទនា និងអាយុជីវិតរបស់មនុស្ស ដែលបង្កើតជាក្ដីកង្វល់ដល់រាជរដ្ឋាភិបាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់ទីកន្លែង។ លោកបន្ថែមទៀតថា រាជរដ្ឋាភិបាលកម្ពុជានៅតែចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយ ក្នុងចំណោមអាទិភាពជាច្រើន សម្រាប់ការលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម ក៏ដូចជាលើកកម្ពស់ការគោរពសិទ្ធិ និងសេចក្ដីថ្លៃថ្នូរបស់មនុស្ស។ រូបភាពនៃអំពើជួញដូរ

មនុស្ស មិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ ថែមទាំងមានការជួញដូរសរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន។

លោកថា «យើងមិនត្រូវអត់ឱនឲ្យពួកនេះបានឡើយ យើងត្រូវខិតខំតាមដានស្វែងរកមុខសញ្ញា ដើម្បីយកមកអនុវត្តនីតិវិធីផ្តន្ទាទោសតាមច្បាប់ ត្រូវចាត់ទុករឿងការជួយញដូរមនុស្សជារឿងយើង ទាំងអស់គ្នា ជាពិសេសឪពុកម្តាយត្រូវធ្វើការអប់រំសីលធម៌ ចរិយាធម៌ឲ្យដល់កូនចៅរបស់ខ្លួន»។ ទន្ទឹមនឹងនោះលោក សុខ លូ បានថ្លែងអំណរគុណដល់កងកម្លាំងសមត្ថកិច្ច និងមន្ត្រីជំនាញពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមគ្នា ដោះស្រាយបញ្ហាចំពោះមុខ ដោយមិនខ្លាចនឿយហត់ ពុះពារប្រឆាំងដាច់ខាតទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជន ស្របទៅតាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបុព្វហេតុសន្តិសុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិ។

**ជាមួយគ្នានេះដែរលោកស្រី លំ គន្ធារី ប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ បានធ្វើរបាយការណ៍សង្ខេបពីបទល្មើសកើតឡើង ២៦ ករណី ក្នុងនោះរួមមាន៖**

*រំលោភសេពសន្ថវៈ ៨ករណី
*អំពើហិង្សាក្នុងគ្រួសារ ៤ករណី
*ករណីប្រទូស្តកេរ្តិ៍ ២ករណី
*អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធឬអនីតិសង្វាសជន ៦ករណី
*ករណីកេងប្រវ័ញ្ចពលកម្មនៅប្រទេសម៉ាឡេស៊ីចំនួន២ ករណី
*ករណីរួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ឆ្នាំ ៣ករណី
*ករណីប៉ុនប៉ងរំលោភសេពសន្ថវៈ ១ករណី៕

## ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២០

## អ្នករត់រ៉ឺម៉កម៉ូតូកង់បីនៅកម្ពុជាទទួលការបណ្តុះបណ្តាលប្រឆាំងការជួញដូរមនុស្ស

https://khmer.voanews.com/ 22 មករា 2020

- ប្រជាជនជាង២៦ម៉ឺននាក់ ក្នុងចំណោមប្រជាជន១៦លាននាក់ នៅកម្ពុជាបានជាប់ក្នុងទាសភាពសម័យទំនើប។ នេះបើយោងតាមសន្ទស្សន៍ទាសភាពពិភពលោក Global Slavery Index របស់មូលនិធិ Walk Free Foundation។

ឡុងដ៍៖ អ្នករត់រ៉ឺម៉កម៉ូតូកង់បីរាប់ពាន់នាក់នៅកម្ពុជានឹងបានចូលរួមប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សក្រោមផែនការមួយ ដោយប្រើកម្មវិធីរបស់ក្រុមហ៊ុន Grab ដែលតាមដានការជួញដូរមនុស្ស ដោយបណ្តុះបណ្តាលអ្នកបើកបររ៉ឺម៉កម៉ូតូកង់បីឱ្យមើល និងរាយការណ៍អំពីសញ្ញានៃការកេងប្រវ័ញ្ច។ ក្រុមហ៊ុន Grab បាននិយាយកាលពីថ្ងៃសុក្រថា ខ្លួននឹងផ្តល់ការបណ្តុះបណ្តាលដល់អ្នកបើកបររ៉ឺម៉កម៉ូតូកង់បីចំនួន១ម៉ឺននាក់នៅក្នុងរាជធានីភ្នំពេញក្នុងខែនេះនៅពេលដែលក្រុមហ៊ុនចាប់ផ្តើមកម្មវិធីដែលត្រូវបានគ្រោងថា នឹងពង្រីកដល់អ្នកបើកបររ៉ឺម៉កម៉ូតូកង់បីរាប់លាននាក់នៅអាស៊ី។ លោក Hashim Alkaff ប្រធានក្រុមហ៊ុន Grab Cambodia បាននិយាយថា"យើងទទួលស្គាល់ថាឡានតាក់ស៊ី និងរ៉ឺម៉កកង់បីអាចជាចំណុចទីមួយនៃទំនាក់ទំនងរវាងអ្នកជួញដូរ និងជនរងគ្រោះ ជាពិសេសនៅអាកាសយានដ្ឋាន ស្ថានីយឡានក្រុង ឬស្ថានីយរថភ្លើង»។

លោកបានប្រាប់ទីភ្នាក់ងារព័ត៌មាន Reuters ថា៖ «តាមរយៈបណ្តាញអ្នកបើកបរដែលជាដៃគូសហការយ៉ាងទូលំទូលាយរបស់ក្រុមហ៊ុន Grab ក្នុងរាជធានីភ្នំពេញ យើងចង់ឲ្យអ្នកបើកបររបស់យើងក្លាយជាភ្នែក និង

ត្រចៀកបន្ថែមទៀត»។ ប្រជាជនជាង២៦ម៉ឺននាក់ ក្នុងចំណោមប្រជាជន១៦លាននាក់ នៅកម្ពុជាបានជាប់ក្នុងទាសភាពសម័យទំនើប។ នេះបើយោងតាមសន្ទស្សន៍ទាសភាពពិភពលោក Global Slavery Index របស់មូលនិធិ Walk Free Foundation។ ជារឿយៗពួកគេក្លាយជាជនរងគ្រោះនៅក្នុងកសិដ្ឋាន ឧស្សាហកម្មនេសាទ និងសំណង់ ហើយពួកគេជាច្រើនគឺជាកុមារ។ មនុស្សរាប់ពាន់នាក់ទៀតត្រូវបានគេជួញដូរឆ្លងប្រទេសរួមទាំងស្ត្រីកម្ពុជាដែលត្រូវបានបង្ខំឱ្យរៀបការជាមួយបុរសនៅប្រទេសចិន។

កាលពីឆ្នាំមុនក្រសួងការបរទេសសហរដ្ឋអាមេរិកបានទម្លាក់ចំណាត់ថ្នាក់ប្រទេសនៅក្នុងរបាយការណ៍របស់ខ្លួនស្តីពីការជួញដូរមនុស្ស មានន័យថា ប្រទេសកម្ពុជាត្រូវតែធ្វើការកែលម្អ បើមុនដូច្នេះទេត្រូវប្រឈមនឹងការដាក់ទណ្ឌកម្មសេដ្ឋកិច្ច។

ទីភ្នាក់ងាររដ្ឋាភិបាលប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសកម្ពុជា ដែលកំពុងធ្វើការជាមួយក្រុមហ៊ុន Grab ក្នុងគំនិតផ្តួចផ្តើមបណ្តុះបណ្តាលអ្នករត់ម៉ូតូកង់បីនេះ បាននិយាយថា ការជួញដូរមនុស្សកំពុងកើនឡើង បើទោះបីជាមានការខិតខំប្រឹងប្រែងរបស់ប៉ូលិស ហើយអ្នកបើករ៉ឺម៉កកង់បីគឺជាប្រភពព័ត៌មានក៏ដោយ។ អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស មានប្រសាសន៍ថា គ្រប់ផ្នែកទាំងអស់នៃសង្គមត្រូវធ្វើការរួមគ្នាដើម្បីកម្ចាត់ការជួញដូរមនុស្ស។

លោក ស៊ាន សុខផៃ នាយកប្រតិបត្តិនៃអង្គការ Child Helpline មានន័យថាបណ្តាញទូរស័ព្ទជំនួយកុមារ បាននិយាយថា អ្នកបើកបរត្រូវបានបំពាក់ឧបករណ៍ដើម្បីកំណត់សកម្មភាពគួរឱ្យសង្ស័យនៅក្នុងយានយន្តរបស់ពួកគេ ហើយឧបករណ៍នេះក៏ត្រូវបំពាក់នៅតាមផ្លូវក្នុងទីក្រុង នៅការដ្ឋានសំណង់ និងកន្លែងកម្សាន្តពេលរាត្រីផងដែរ។ លោកបានមានប្រសាសន៍ថា៖ «ការជួញដូរមាននៅគ្រប់ទីកន្លែង ដូចជាការរំលោភបំពានពលកម្ម ការកេងប្រវ័ញ្ចលើកុមារការរំលោភបំពានផ្លូវភេទ។ យើងចង់លុបបំបាត់របាំងដែលរារាំងមិនឱ្យពលរដ្ឋមានលទ្ធភាពរាយការណ៍អំពីរឿងនេះ»។

ក្រុមហ៊ុនផ្តល់សេវានៅទូទាំងពិភពលោកកំពុងរងសម្ពាធកាន់តែខ្លាំងឡើង ឲ្យចូលរួមចំណែកប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងទាសភាពសម័យទំនើបដែលបានធ្វើឲ្យប្រជាជន៤០ លាននាក់រងគ្រោះនៃការជួញដូរដែលរកប្រាក់បានប្រមាណ១៥០ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។ ក្រុមហ៊ុន Uber ដែលបានលក់អាជីវកម្មរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ឲ្យក្រុមហ៊ុន Grab នៅឆ្នាំ២០១៨ បានធ្វើគំនិតផ្តួចផ្តើមស្រដៀងគ្នានៅឆ្នាំនោះ៕

## ស្ត្រីជនជាតិខ្មែរឥស្លាមម្នាក់ ទៅរស់នៅប្រទេសម៉ាឡេស៊ី ត្រូវស្វាមីវាយធ្វើបាប ក៏សម្រេចចិត្តមកប្រទេសកម្ពុជាវិញ

http://www.cen.com.kh/archives/ January 23, 2020

កោះកុង ៖ ស្នងការដ្ឋាននគរបាលខេត្តកោះកុង នៅថ្ងៃទី ២២ មករា ២០២០ បានឲ្យតដឹងថា យោងលិខិតលេខ ០១៦ របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ស្នើរអោយកម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តកោះកុងជួយស៊ើបអង្កេតស្រាវជ្រាវរកកុមារពីរនាក់ ដែលសង្ស័យថា ត្រូវម្តាយយកពីប្រទេសម៉ាឡេស៊ី មកកម្ពុជា កំពុងស្នាក់នៅក្នុងខេត្តកោះកុង ។

ក្រោយពីបានទទួលសារលិខិត ឯកឧត្តម ឧត្តមសេនីយ៍ទោ សំឃិត វៀន ស្នងការនគរបាលខេត្ត បានកម្លាំងជំនាញការិយាល័យប្រឆាំកការជួញដូរមនុស្ស និងការពារអនីតិជន ចុះស្រាវជ្រាវ ក៏បានជួបម្តាយឈ្មោះ Saliha Binti Salleh និងកុមារទាំងពីរ ៖ ១.ឈ្មោះ Muhammad Paqih Fidin Bin Mahama Amza អាយុ ៣ ឆ្នាំ ។ ២. ឈ្មោះ Muhammad Umer Alhaliz Bin Mahamad Amzar អាយុ ៤ ឆ្នាំ ។ ត្រូវបានម្តាយយកមក ស្នាក់នៅផ្ទះជីដូនជីតា របស់ពួកគេក្នុងភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

នៅពេលកម្លាំងសមត្ថកិច្ចជំនាញយើង ហៅមកសាកសួរ ម្តាយក្មេងប្រុសទាំងពីរបានបំភ្លឺប្រាប់ថា ៖ ខ្លួនជាជនជាតិខ្មែរឥស្លាម បានទៅរស់នៅប្រទេសម៉ាឡេស៊ី ជាមួយឪពុកម្តាយបង្កើត តាំងពីអាយុ ៤ឆ្នាំ មកម្លេះ ពីព្រោះពួកគាត់ទៅរកស៊ីនៅទីនោះ រហូតដល់ឆ្នាំ ២០១៥ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសជនជាតិម៉ាឡេស៊ីម្នាក់ឈ្មោះ អាំ ហ្សិត អាយុ ២៨ ឆ្នាំ មានទីលំនៅ ខេត្ត ប៉ាហាំង ប្រទេសម៉ាឡេស៊ី រស់នៅជាមួយគ្នាអស់រយៈពេល ៥ ឆ្នាំ មានកូនចំនួន ៣នាក់ ស្រី ១នាក់ ប្តីរបស់ខ្លួនបានជួលផ្ទះសំណាក់ និងសណ្ឋាគារដើម្បីស្នាក់នៅហើយចេញទៅបាត់ៗ លុះត្រឡប់មកវិញរករឿងឈ្លោះវាយខ្លួន និងកូននឹងបានដកដាវក្នុងគំរាមសម្លាប់ ស្ទើររាល់ថ្ងៃ ដោយហាមមិនអោយខ្លួន និងកូនចេញទៅក្រៅបន្ទប់ និងមិនអោយខ្លួនជួបនឹងឪពុកម្តាយរបស់ខ្លួនទៀត ពេលឈ្លោះគ្នាម្តងៗ ខ្លួនបានទៅប្តឹងសមត្ថកិច្ចម៉ាឡេស៊ីដែរ តែគេមិនបានដោះស្រាយអោយខ្លួនទេ ពីព្រោះខ្លួនជាជនអន្តោប្រវេសន៍ ។

ដោយអត់ទ្រាំនឹងទង្វើបែបនេះពុំបាន ខ្លួនក៏នាំកូនប្រុស ពីរនាក់យកស្រុកខ្មែរ ដោយបានធ្វើការសំណូមពរដល់សមត្ថកិច្ចយើងថា ខ្លួននឹងកូនមិនត្រឡប់ទៅប្រទេសម៉ាឡេស៊ីវិញទេ សុខចិត្តរស់នៅស្រុកខ្មែរវិញ និងមិនប្តឹងផ្តល់អ្វីទាំងអស់ បច្ចុប្បន្ននារីកំពុងពពោះទារកអាយុ ៩ ខែ ៕ ដោយៈកូឡាប

## ជនជាតិអូស្ត្រាលីម្នាក់បានសារភាពពីបទល្មើសរំលោភសេពសន្ថវៈនៅលើកុមារកម្ពុជា

http://www.cen.com.kh/archives/ January 23, 2020

ភ្នំពេញ៖អង្គការ CPU បានចេញផ្សាយព័ត៌មាននៅថ្ងៃទី២២ មករានេះថា ឥឡូវនេះយើងអាចបញ្ចេញអត្តសញ្ញាណរបស់បុរសជនជាតិអូស្ត្រាលីម្នាក់ ដែលមានមុខរបរជាអ្នកជំនួញ និងជាឪពុកម្នាក់នៅក្នុងទីក្រុង Adelaide ប្រទេសអូស្ត្រាលី។ លោក Geoffrey Moyle មានអាយុ ៤៦ឆ្នាំ បានប្រព្រឹត្តបទល្មើសមួយចំនួនទៅលើកុមារកម្ពុជារវាងឆ្នាំ ២០០២ ដល់២០០៦។ តុលាការរដ្ឋ South Australia បានបញ្ចេញអត្តសញ្ញាណរបស់បុគ្គលម្នាក់នេះ ដែលធ្លាប់មានអាជីពក្នុងអង្គការក្រៅរដ្ឋាភិបាលមួយចំនួននៅក្នុងប្រទេសកម្ពុជា ថែមទាំង AusAid កាលពីឆ្នាំ ២០០២។ អត្តសញ្ញាណរបស់បុគ្គលម្នាក់នេះ ដែលពីមុនមកត្រូវបានលាក់ទុកជាអាថ៌កំបាំងតាមផ្លូវច្បាប់ ត្រូវបានផ្តន្ទាទោសកាលពីឆ្នាំ២០១៩។

សេចក្តីថ្លែងការរបស់នគរបាលសហព័ន្ធប្រទេសអូស្ត្រាលីបានស្តីថាៈ "បុរសអាយុ៤៦ឆ្នាំម្នាក់ មកពីទីក្រុង Adelaide ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើសមួយចំនួន ពាក់ព័ន្ធនឹងការជួញដូរកុមារ បន្ទាប់ពីការស៊ើបអង្កេតដោយក្រុមការងារចម្រុះប្រឆាំងការជួញដូរកុមាររបស់រដ្ឋអូស្ត្រាលីខាងត្បូង (SA-JACET), ដែលនៅក្នុងក្រុមនោះមានសមាជិករបស់នគរបាលសហព័ន្ធប្រទេសអូស្ត្រាលី និងនគរបាលរដ្ឋអូស្ត្រាលីខាងត្បូង។

ខាលពីខែកុម្ភៈ ឆ្នាំ២០១៩, SA-JACET បានទទួលព័ត៌មានបញ្ជូនពីនគរបាលរដ្ឋ Queensland ដែលបានកំណត់លេខសម្គាល់តាមអ៊ីនធឺណិតរបស់អ្នកប្រើដែលមានទីតាំងនៅក្នុងទីក្រុង Adelaide ដែលបានបង្ហោះរូបភាពអាសអាភាសទៅលើកុមារនៅក្នុងគេហទំព័រមួយ។ SA-JACET បានចាប់ផ្តើមការស៊ើបអង្កេតទៅលើរឿងនេះ ហើយនៅក្នុងខែឧសភា ឆ្នាំ២០១៩ បានចេញដីកាឆែកឆេរទីលំនៅរបស់ជនសង្ស័យដែលស្ថិតនៅក្នុងដំបន់Westbourne Park ទីក្រុង Adelaide។ ការអនុវត្តដីកាឆែកឆេរនៅទីក្រុង Adelaide កាលពីថ្ងៃនេះនាំមកបុគ្គលនេះ ដែលកំពុងនៅក្រៅការឃុំឃាំង, ទទួលការចោទប្រកាន់ពីបទល្មើសផ្សេងៗទៀត។ ក្រុមការងារចម្រុះបានដកយកឧបករណ៍អេឡិចត្រូនិចមួយចំនួនដែលអាចផ្ទុកនូវភស្តុតាងសំខាន់ៗ។ ការត្រួតពិនិត្យទៅលើព័ត៌មានដែលបានទទួលពីដៃគូរនគរបាលនៅក្រៅប្រទេសបានបង្ហាញពីបទល្មើមួយចំនួនរវាងឆ្នាំ២០០២ ដល់២០០៦ ពេលដែលបុគ្គលនេះកំពុងរស់នៅក្នុងប្រទេសកម្ពុជា។

CPU ក៏បានដឹងពីការស៊ើបអង្កេតនេះ ហើយនាយកប្រតិបត្តិការអង្គភាពការពារកុមារ លោក James McCABE បានស្តីថា "យើងសូមផ្តល់កិត្តិយសដល់នគរបាលរដ្ឋ Queensland, នគរបាលរដ្ឋ South Australia, នគរបាលសហព័ន្ធអូស្ត្រាលី, និងក្រុមការងារចម្រុះ SA-JACET ដែលបានធ្វើការស៊ើបអង្កេតទៅលើបទល្មើសប្រព្រឹត្តដោយបុរសម្នាក់នេះ ពេលដែលស្នាក់នៅក្នុងប្រទេសកម្ពុជា។ ខ្ញុំបានដឹងថា ការស៊ើបអង្កេតនេះបានធ្វើឡើងទាក់ទងទៅនឹងសកម្មភាពរបស់បុគ្គលនេះចាប់ផ្តើមពីឆ្នាំ២០០២ រហូតដល់ឆ្នាំ២០១៨។ នគរបាលជាតិកម្ពុជាក៏បានចូលរួមក្នុងការស៊ើបអង្កេតទៅលើបុគ្គលម្នាក់នេះដែរ។ លទ្ធផលនេះបង្ហាញពីការប្តេជ្ញារបស់គ្រប់ទីភ្នាក់ងារថែមទាំងរាជរដ្ឋាភិបាលកម្ពុជាចំពោះការប្រឆាំង និងផ្តន្ទាទោសគ្រប់ជនល្មើសដែលប្រព្រឹត្តបទល្មើសទៅលើកុមារមិនថាជននោះមានទីលំនៅទីណាក៏ដោយ៕ ដោយៈកូឡាប

## ជនជាតិណាខ្លះ ដែលប្រព្រឹត្តបទល្មើសនៅកម្ពុជា ច្រើនជាងគេ?

http://kleykley.sabay.com.kh/ អង្គារ, 21 មករា 2020 14:01

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០១៩ របស់ក្រុមព័ត៌មានទាន់ហេតុការណ៍ (HOTLINE) ជាមួយជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានឱ្យដឹងថា ជនបរទេសប្រព្រឹត្តបទល្មើសនៅកម្ពុជា គិតពីថ្ងៃទី១៩ ធ្នូ ២០១៨ ដល់ ២០ វិច្ឆិកា ២០១៩ មានចំនួនសរុប ៣២៤ករណី (កើនឡើង៤៩ករណី) ឃាត់ខ្លួន ១៤៣នាក់ មាន ៤០សញ្ជាតិ។ ការប្រព្រឹត្តបទល្មើសមាន ២៣ប្រភេទ កើតឡើងនៅ ២២រាជធានី-ខេត្ត។ ក្នុងនោះសញ្ជាតិដែលប្រព្រឹត្តបទល្មើសភាគច្រើនគឺ ចិន វៀតណាម ថៃ ឥណ្ឌា កូរ៉េខាងត្បូង ហើយភូមិសាស្ត្រដែលកើតមានភាគច្រើនគឺនៅខេត្តព្រះសីហនុ រាជធានីភ្នំពេញ និងខេត្តសៀមរាប។

បទល្មើសដែលជនបរទេសបានប្រព្រឹត្តរួមមាន៖ បង្កគ្រោះថ្នាក់ចរាចរណ៍, ជួញដូរផ្លូវភេទ, រក្សាទុកប្រើប្រាស់-ជួញដូរគ្រឿងញៀន, រំលោភសេពសន្ថវៈ, បទល្មើសអន្តោប្រវេសន៍, បង្ខាំងមនុស្សជំរិតទារប្រាក់, ប្រព្រឹត្តហិង្សាដោយចេតនា, បទល្មើសឆបោក, លួច-ឆក់-ប្លន់, កាន់កាប់ប្រើប្រាស់គ្រឿងផ្ទុះខុសច្បាប់, បៀតបៀនផ្លូវភេទ, អុកឡុកលំនៅឋានអ្នកដទៃ, ប៉ុនប៉ងប្រព្រឹត្តមនុស្សឃាត, បង្ហោះដ្រូនគ្មានការអនុញ្ញាត, លក់ផលិតផលក្លែងក្លាយ, ប្រព្រឹត្តអំពើឃាតកម្ម, មនុស្សឃាតដោយអចេតនា, ប្រព្រឹត្តបទល្មើសសេដ្ឋកិច្ច, បើកគ្លីនិកពុំមានច្បាប់អនុញ្ញាត, បំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ, បទល្មើសពេស្យាចារ, សហការចាប់ខ្លួនតាមដីកាតុលាការប្រទេសចិន និងបើកល្បែងអនឡាញខុសច្បាប់៕ អត្ថបទ៖ សោភា

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial/ January 21 at 4:46 PM •

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១៥និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ លោកវរសេនីយ៍ឯក ង៉ុយ ជៀង នាយប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរនេះ មានឈ្មោះ ជុំ ឯម ភេទប្រុស អាយុ ៣៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិល្បើក ឃុំសម្បត្តិមានជ័យ ខេត្តស្វាយរៀង។ បច្ចុប្បន្នពលករខ្មែររូបនេះ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## សមត្ថកិច្ចនគរបាលខេត្តអានយ៉ាង សមត្ថកិច្ចនគរបាលខេត្តតាកែវ នៅតែបន្តជារួមគ្នាបង្ការ និងបង្ក្រាបបទល្មើសឆ្លងដែនឲ្យមានប្រសិទ្ធភាពខ្ពស់

http://kampucheathmey.com/ 22/1/2020 8:43 Am

តាកែវ ៖ កាលពីរសៀលថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ទោ សុខ សំណាង ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ លោកឧត្តមសេនីយ៍ វរសេនីយ៍ ជាស្នងការរង និងសហការីច្រើនរូប ចូលរួមប្រជុំបូកសរុបសភាពការណ៍ និងលទ្ធផលសហប្រតិបត្តិការ ធានាសន្តិសុខសណ្តាប់ធ្នាប់ រវាងស្នងការដ្ឋាន នគរបាលខេត្តអានយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយស្នងការដ្ឋាននគរបាលខេត្តតាកែវ រយៈពេល៦ខែចុងឆ្នាំ២០១៩ និងលើកទិសដៅ៦ខែ ដើមឆ្នាំ២០២០។ កិច្ចប្រជុំនេះ ធ្វើឡើងនៅស្នងការដ្ឋាននគរបាល ខេត្តអានយ៉ាង ប្រទេសវៀតណាម ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ត្រី ប៊ុយ ប៉ៃ ទី ស្នងការនគរបាល ខេត្តអានយ៉ាង ប្រធានអង្គប្រជុំ ,លោកឧត្តមសេនីយ៍ទោ សុខ សំណាង ស្នងការនគរបាលខេត្តតាកែវ និងលោកឧត្តមសេនីយ៍ទោ អ៊ាវ ចំរើន ស្នងការនគរបាលខេត្តកណ្តាល ដោយមានការចូលរួមពីលោកស្នងការរង និងសមាសភាពពាក់ព័ន្ធចំណុះឲ្យស្នងការដ្ឋាននគរបាលខេត្តទាំងបី។

ចុងបញ្ចប់នៃកិច្ចប្រជុំភាគីទាំង២ (កម្ពុជា-វៀតណាម) បានវាយតម្លៃខ្ពស់នូវលទ្ធផលសម្រេចបាន និងបញ្ហាដែលនៅសេសសល់មួយចំនួនក្នុងកិច្ចប្រតិបត្តិការ បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសរវាងភាគីទាំងពីរក្នុងរយៈពេល៦ខែ និងបានឯកភាពគ្នាលើកទិសដៅសហប្រតិបត្តិការចំណុចសំខាន់ៗ អនុវត្តបន្តនៅក្នុងរយៈ៦ខែ ដើមឆ្នាំ២០២០ខាងមុខ ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ដែលឆ្លងដែនចេញ-ចូល រវាងប្រទេសទាំង២ ខេត្តទាំង៣ ក្នុងគោលបំណងធានាបានសន្តិសុខសណ្តាប់ធ្នាប់ នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែន។ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំ ភាគីទាំង២ បានជូនវត្ថុអនុស្សាវរីយ៍ឲ្យគ្នាទៅវិញទៅមក ដើម្បីអបអរសាទរ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិវៀតណាមខាងមុខនេះ៕

# ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០២០

## សាលាដំបូងរាជធានី បន្តសវនាការសំណុំរឿងស្ត្រីស៊ីឈ្នួលពពោះ

https://www.postkhmer.com/ គឹម សារុំ | Publication date 23 January 2020 | 17:16 ICT

**ភ្នំពេញៈ** ស្ត្រីខ្មែរស៊ីឈ្នួលពពោះឲ្យបរទេសចំនួន ៧ នាក់ ក្នុងចំណោម ៣៣ នាក់ ដែលសមត្ថកិច្ចឃាត់ខ្លួនកាលពីខែមិថុនា ឆ្នាំ ២០១៨ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញបើកសវនាការជំនុំជម្រះបន្តកាលពីថ្ងៃ ២១ មករា ឆ្នាំនេះ បន្ទាប់មានស្ត្រីពពោះ ៤ នាក់ និងបុរសចិនម្នាក់ត្រូវបានតុលាការសួរដេញដោលកាលពីចុងឆ្នាំមុន។ សវនាការនេះបានធ្វើឡើងដោយមានសមាសភាពចៅក្រមចំនួន ៣ រូប ដែលមានលោកស្រីចៅក្រម ស៊ លីនណា ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងមានលោកស្រី កែវ សុគន្ធា ជាតំណាងអយ្យការ។

ឆ្លើយប្រាប់ចៅក្រមក្នុងបន្ទប់សវនាការស្ត្រីឈ្មោះ ផៃ សុផា អាយុ ៣៣ ឆ្នាំ ជាកម្មការិនីរោងចក្រកាត់ដេរបាននិយាយថា គាត់ត្រូវបានស្ត្រីម្នាក់ធ្វើការជាមួយគ្នាណែនាំថា មានគេត្រូវការស្ត្រីខ្មែរស៊ីឈ្នួលពពោះកូនឲ្យគេដោយឲ្យឈ្នួល ១ ម៉ឺនដុល្លារ។ បន្ទាប់មកគេបានឲ្យគាត់ទៅជួបស្ត្រីម្នាក់ដែលចង់ជួលនោះនៅបុរីវិមានភ្នំពេញក្នុងសង្កាត់ច្បាំងចំរេះ ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។ ស្ត្រី ផៃ សុផា បន្តថា ពេលគាត់ទៅដល់បានជួបស្ត្រីម្នាក់ឈ្មោះ ថៃ ផាន់ណា ត្រូវជាប្រពន្ធរបស់ថៅកែចិនម្នាក់ ហើយគេបានឲ្យគាត់ធ្វើកិច្ចសន្យាថាពីពេលពពោះដល់ឆ្លងទន្លេគឺគាត់ទទួលបានប្រាក់ ១ ម៉ឺនដុល្លារ។ ប៉ុន្តែត្រូវដក ១ ពាន់ដុល្លារ ឲ្យទៅអ្នកណែនាំ និងទទួលបានប្រាក់ក្នុង ១

ខែ ៣០០ ដុល្លារទៀត។ ក្រោយពីធ្វើកិច្ចសន្យារួចគាត់ត្រូវគេនាំទៅពិនិត្យសុខភាព ហើយគ្រូពេទ្យបានចាក់បញ្ចូលមេជីវិតក្នុងខ្លួនគាត់។ លុះចាក់មេជីវិតរួចគេតម្រូវឲ្យគាត់ស្នាក់នៅរួមគ្នាក្នុងបុរីមានភ្នំពេញនោះជាមួយស្ត្រី ៧-៨ នាក់ទៀតដែលជាអ្នកស៊ីឈ្នួលពពោះដូចគ្នា។ សុផា ប្រាប់ចៅក្រមបន្តថាពេលគាត់ពពោះបាន៨ខែ ក៏ត្រូវនគរបាលប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញឃាត់ខ្លួនរួមជាមួយស្ត្រីខ្មែរមួយចំនួនទៀតកាលពីខែមិថុនា ឆ្នាំ ២០១៨។ ប៉ុន្តែគាត់ត្រូវបានតុលាការឲ្យនៅក្រៅឃុំបណ្តោះអាសន្នរហូតកើតបានកូនប្រុសម្នាក់ដែលមកទល់ពេលនេះកូននោះមានអាយុជាង ១ ឆ្នាំហើយ។ សុផា បាននិយាយថា គាត់មានប្តី និងមានកូនប្រុស-ស្រី ២ នាក់។ ប៉ុន្តែគាត់បានលែងលះគ្នាជាមួយប្តីតាំងពីមុនពេលស៊ីឈ្នួលពពោះម្ល៉េះ ហើយថាមូលហេតុដែលគាត់ធ្វើបែបនេះមកពីក្រពេក។ នាង ផៃ សុផា បញ្ជាក់ប្រាប់ចៅក្រមថា៖ «ថ្វីដ្បិតកូនពពោះមិនមែនបានពីមេជីវិតប្តីខ្ញុំ តែខ្ញុំស្រឡាញ់កូនខ្ញុំខ្លាំងជាងកូនបង្កើតរបស់ខ្ញុំទៅទៀត។ បើគេទាមទារយកវិញខ្ញុំមិនឲ្យទេ»។

រីឯស្ត្រី ឈ្មោះ យន់ លីន អាយុ ៣៤ ឆ្នាំ បានឆ្លើយប្រាប់ចៅក្រមថា គាត់ជាកម្មការិនីរោងចក្រកាត់ដេរមិនធ្លាប់មានកូនទេ ហើយត្រូវបានគេណែនាំឲ្យជួបស្ត្រី ឈ្មោះ ថៃ ផាន់ណា នៅផ្ទះក្នុងបុរីមានភ្នំពេញដូចគ្នា។ ពេលទៅដល់ស្ត្រីឈ្មោះ ថៃ ផាន់ណា បានប្រាប់គាត់ថា ពេលគេចាក់បញ្ចូលមេជីវិតរួចបាន ៧ ថ្ងៃ គេឲ្យលុយ ៥០០ ដុល្លារ ទោះជាមេជីវិតនោះទំក្នុងពោះ ឬមិនទំក៏ដោយ។ ប៉ុន្តែ ៣ ថ្ងៃក្រោយមកក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន តែតុលាការបានអនុញ្ញាតឲ្យនៅក្រៅឃុំដែររហូតដល់ឆ្លងទន្លេបានកូនប្រុសដែលសព្វថ្ងៃមានអាយុ ១១ ខែហើយ។ ស្ត្រីរូបនេះថា ទោះជាគាត់នៅក្រៅឃុំក្តី ប៉ុន្តែពេលតុលាការឲ្យចូលខ្លួនគឺត្រូវគោរពតាម។

ស្រដៀងគ្នានេះដែរស្ត្រីម្នាក់ទៀត ឈ្មោះ រី អ៊ី បានប្រាប់ចៅក្រមដែរថា គាត់ក៏ត្រូវបានគេណែនាំឲ្យទៅទីតាំងបុរីមានភ្នំពេញដូចគ្នាដោយឲ្យទៅផ្ទះលេខ ២ ដើម្បីស៊ីឈ្នួលពពោះនេះ។ ស្ត្រីរូបនេះបានបញ្ជាក់ថា គាត់មានប្តីហើយ តែរឿងនេះមិនបានប្រាប់ប្តីឲ្យដឹងទេ ខណៈគាត់ក៏មានកូនស្រីម្នាក់ តែក្រោយមកទើបបានប្តីដឹង តែគាត់មិនបន្ទោសទេ។ ស្ត្រី រី អ៊ី បន្តថា ក្រោយមានផ្ទៃពោះប្រហែល ៧ ខែ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ប៉ុន្តែត្រូវបានតុលាការឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។ ក្រោយមកគាត់កើតបានកូនប្រុសម្នាក់ដែលសព្វថ្ងៃមានអាយុ ១ ឆ្នាំ ៥ ខែហើយ ហើយប្តីរបស់គាត់ស្រឡាញ់កូននោះខ្លាំងណាស់។ ស្ត្រីរូបនេះបញ្ជាក់ថា៖ «ខ្ញុំមិនដឹងថាមេជីវិតជាជនជាតិណាទេ ហើយក៏មិនដឹងថា ឪពុកម្តាយកូនប្រុសខ្ញុំជាជនជាតិអីដែរ។ ប៉ុន្តែខ្ញុំចង់រស់នៅជាមួយកូនខ្ញុំអស់ ១ ជីវិត»។

ដោយឡែក ស្ត្រីឈ្មោះ ផល ផល្លា និង ឈ្មោះ ហួន ដាណែត សុទ្ធតែមានកូនប្រុសម្នាក់ ១ ដូចគ្នា ខណៈពួកគេក៏មានប្តីមានកូនផ្ទាល់ខ្លួន។ អ្នកទាំង ២ បានឆ្លើយប្រាប់ចៅក្រមដែរថា ពួកនាងក៏ដូចជាស្ត្រីស៊ីឈ្នួលពពោះដែលត្រូវបានគេណែនាំឲ្យទៅផ្ទះខាងលើដូចគ្នា។ ប៉ុន្តែពេលពួកគាត់មានផ្ទៃពោះទើបតែ ៨ ខែក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

ពាក់ព័ន្ធនឹងតុលាការកោះហៅស្ត្រីពពោះទាំងនេះ ចៅក្រមក៏បានប្រកាសលើកទៅជំនុំជម្រះនៅថ្ងៃក្រោយទៀត ខណៈស្ត្រីទាំង ៣៣ នាក់ ត្រូវបានចៅក្រមស៊ើបសួរចោទបទអំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែនតាមមាត្រា ១៦ ច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

តាមកំណត់ហេតុនគរបាលប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញបង្ហាញថា ស្ត្រីស៊ីឈ្នួលពពោះទាំង ៣៣នាក់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១៨នៅផ្ទះលេខ ៩A និងផ្ទះលេខ ២A ក្នុងសង្កាត់ច្រាំងចំរេះ ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ក្នុងនោះសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យឈ្មោះ LIU QIANG ភេទប្រុសអាយុ ៤៩ ឆ្នាំ ជនជាតិចិន,ទី២- ឈ្មោះ ស្វាយ ស៊ីណុច អាយុ ៣៤ ឆ្នាំ, ទី៣- ឈ្មោះ លឹម សុភាព ភេទស្រី អាយុ ១៩ ឆ្នាំ, ទី៤- ឈ្មោះ ថៃ ភាព ភេទ ស្រី អាយុ ៤៣ ឆ្នាំ និងទី៥- ឈ្មោះ នឿនស្រី ឡាង

ភេទស្រី អាយុ ២៧ ឆ្នាំ។ ក្រៅពីនេះតុលាការបានចេញដីកាចាប់ខ្លួនឈ្មោះ CHEN HAO MING ភេទ ប្រុស ជនជាតិចិន, ទី២- ឈ្មោះ ថៃ ផាន់ណា ភេទស្រី និងឈ្មោះ អ៊ី យ៉េងគង់ ភេទប្រុស៕

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការចំនួន ១១អង្គការ

https://www.facebook.com/ អគ្គនាយកដ្ឋានបច្ចេកទេស-នៃក្រសួងសង្គមកិច្ច 24-01-2020

ទីស្ដីការក្រសួង៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការចំនួន ១១អង្គការ សម្រាប់ប្រើប្រាស់ក្នុងរយៈពេល៣ឆ្នាំ ដើម្បីជួយក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយផ្តោតសំខាន់ទៅលើវិស័យសុខុមាលភាពកុមារ សុខុមាលភាពសង្គម សុខុមាលភាពជនពិការ និងប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។

ពិធីចុះហត្ថលេខា នៃកិច្ចព្រមព្រៀង (MoU) នាពេលនេះ បានរៀបចំឡើងជាផ្លូវការ នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តម តូច ចាន់នី អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការចូលរួមពីថ្នាក់ដឹកនាំអង្គការទាំង១១ រួមនឹងមន្ត្រីរាជការពាក់ព័ន្ធរបស់ក្រសួង ស.អ.យជាច្រើនរូបទៀតផងដែរ។ អង្គការទាំង១៣នោះរួមមាន៖

១. អង្គការ សម្ព័ន្ធចាប់ដៃ
២. អង្គការ ក្ដីស្រឡាញ់គ្មានព្រំដែន
៣. អង្គការ ក្តីសង្ឃឹមនិងយុត្តិធម៌
៤. អង្គការ សកម្មភាពដើម្បីកុមារ
៥. អង្គការ សង្គ្រោះនិងថែទាំអន្តរជាតិស៊ីធីភញ
៦. អង្គការ តំណក់ទឹក
៧. អង្គការ បេសកកម្មជីវិតថ្មី
៨. អង្គការ Joy Fountain Foundation
៩. អង្គការ បុគ្គលសារវន្តកម្ពុជា
១០.អង្គការ សមាគមសហប្រតិបត្តិ

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នារសៀលថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ចំនួន ០៩នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងស្នាក់នៅខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 23-01-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នារសៀលថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ បានទទួលពលករខ្មែរចំនួន ០៩នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងស្នាក់នៅខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៩នាក់ ស្រី ០២នាក់ មកពីខេត្តបាត់ដំបង ០៥នាក់ ស្រី ០១នាក់, ខេត្តព្រៃវែង ០១នាក់, ខេត្តសៀមរាប ០២នាក់ ស្រី ០១នាក់ និងខេត្តព្រះវិហារ ០១នាក់៕

## តំណាងស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ សម្របសម្រួលក្នុងការទាមទារលិខិតឆ្លងដែនដល់ពលករខ្មែរចំនួន៦នាក់

https://www.facebook.com/LabourOfficial/ 23-01-2020

ថ្ងៃព្រហស្បតិ៍ ទី២៣ ខែមករា ឆ្នាំ២០២០ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ចុះមកអធិការដ្ឋាននគរបាលស្រុកផានថង និងការិយាល័យសុខមាលភាពនិងគាំពារពលករខេត្តឈុនបុរី សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្របសម្រួលក្នុងការទាមទារលិខិតឆ្លងដែនដល់ពលករខ្មែរចំនួន៦នាក់ ដែលត្រូវនិយោជកដកហូតទុកមកឱ្យពលករកាន់កាប់វិញ។

## មន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃចុះអន្តរាគមន៍ទាមទារឯកសារលិខិតឆ្លងដែនមកប្រគល់ជូនពលករខ្មែរកាន់កាប់វិញតាមសំណូមពររបស់ពលករ

https://www.facebook.com/LabourOfficial/ 24/01/20

ករណីពលករខ្មែរធ្វើការនៅក្នុងខេត្តឈុនបុរី ប្រទេសថៃ ត្រូវតំណាងរោងចក្រដកហូតលិខិតឆ្លងដែន មិនអោយកាន់កាប់ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០កន្លងទៅ បានដាក់ពាក្យបណ្តឹងទៅស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ អោយជួយអន្តរាគមន៍ជូនពួកគាត់។ ព្រឹកថ្ងៃស្រុក ទី២៤ ខែមករា ឆ្នាំ២០២០ លោក ជិន សំណាង មន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ បានចុះធ្វើការសហការជាមួយកម្លាំងអាជ្ញាធរពាក់ព័ន្ធ មាន មន្ទីរគាំពារសិទ្ធិ និងសុខមាលភាពពលករ,នាយកដ្ឋានគាំពារសិទ្ធិពលករនិងសុខភាពពលករ នៃក្រសួងការងារថៃ, អាជ្ញាធរតម្រួតភូមិភាគ២សហការជាមួយតម្រួតអធិការដ្ឋានផានថង,អាជ្ញាធរTATIP,អង្គការLPN ចុះអន្តរាគមន៍ទាមទារឯកសារលិខិតឆ្លងដែនមកប្រគល់ជូនពលករខ្មែរកាន់កាប់វិញតាមសំណូមពររបស់ពលករ។ ក្នុងនោះដែរ សមត្ថកិច្ចពាក់ព័ន្ធ បានធ្វើការណែនាំដល់អ្នកគ្រប់គ្រងរោងចក្រហាមដកហូតឯកសារស្គាល់ខ្លួនដូចជាលិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតកាងាររបស់ពលករជាដាច់ខាត និងស្នើអោយខាងរោងចក្រយកចិត្តទុកដាក់ចំពោះពលករខ្មែរ ដែលចូលមកធ្វើការតាមរយៈMOU អោយបានត្រឹមត្រូវតាមផ្លូវច្បាប់។

ដោយខាងភាគីក្រុមហ៊ុនបានទទួលសំណើរបស់សមត្ថកិច្ច ព្រមទាំងសន្យាកែទម្រង់បែបប្រព័ន្ធគ្រប់គ្រងពលករសាជាថ្មីដើម្បីកុំអោយកើតមានឡើងបញ្ហាដូចខាងលើនេះ និងរៀបចំប្រព័ន្ធទទួលពាក្យបណ្តឹងពីពលករផ្ទាល់នៅពេលជួបបញ្ហាអំឡុងពេលធ្វើការនៅក្នុងរោងចក្រ។

## ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២០

## គជបជ ប្រជុំ ពិភាក្សា ស្តីពី ការពង្រឹងកិច្ចសហការ ជាមួយ អង្គការដៃគូ ការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស

https://www.dap-news.com/national/ BySS107 Posted on January 27, 2020

ភ្នំពេញ៖គណៈកម្មាធិការ ជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជបជ) នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ នៅភោជនីយដ្ឋានទន្លេបាសាក់២ បានបើកកិច្ចប្រជុំ ពិភាក្សា ស្តីពី ការពង្រឹងកិច្ចសហការ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដៃគូក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងពិធីប្រគល់លិខិតថ្លែងអំណរគុណ ដែលប្រព្រឹត្តិឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ (គជបជ) ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ មាន ឧត្តមសេនីយ៍ឯក វេជ្ជ ប៉ុណ្ណ សំខាន់ ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន(គជបជ) និងអង្គការដៃគូ ក្នុងការប្រយុទ្ធប្រ ឆាំងអំពើជួញដូរមនុស្ស និងវិស័យឯកជន ជាច្រើនរូប៕

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការរៀបចំសិក្ខាសាលាជាមួយក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពនៃប្រទេសជប៉ុន

https://www.facebook.com/ General Department of Labour **January 25 at 9:26 AM •**

(ភ្នំពេញ)៖ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការរៀបចំសិក្ខាសាលាជាមួយក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពនៃប្រទេសជប៉ុន និងអង្គការបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស (OTIT) នៃប្រទេសជប៉ុន ដើម្បីផ្សព្វផ្សាយគោលការណ៍ថ្មីៗនៃការអនុវត្តគម្រោងបញ្ជូនកម្មសិក្សាការីជំនាញបច្ចេកទេស-ពលករជំនាញទៅប្រទេសជប៉ុន។

សិក្ខាសាលា ត្រូវបានរៀបចំក្រោមអធិបតីភាព ឯកឧត្តម សេង សក្ដា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងលោក ARIGA Yasuo អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រឹក្សាយោបល់សម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេសនៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពនៃប្រទេសជប៉ុន និងមានការចូលរួមពី ថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកនៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម មន្ត្រីទទួលបន្ទុកនៃអង្គការ OTIT តំណាងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា សមាគមបញ្ជូនពលករទៅក្រៅប្រទេស និងតំណាងទីភ្នាក់ជ្រើសរើសឯកជនកម្ពុជា ដែលមានអ្នកចូលរួមសរុបប្រមាណ ១២០ នាក់។

នៅក្នុងកម្មវិធីសិក្ខាសាលានេះ តំណាងរដ្ឋាភិបាលនៃប្រទេសជប៉ុន បានផ្សព្វផ្សាយ និងណែនាំទៅដល់ក្រុមហ៊ុនបញ្ជូននូវគោលការណ៍ច្បាប់ និងបទប្បញ្ញត្តិថ្មីៗពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មសិក្សាការី-ពលករជំនាញ ដើម្បីធានាបាននូវសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗ របស់កម្មសិក្សាការី-ពលករជំនាញ នៅអំឡុងពេលបំពេញការងារ ទៅដល់ទីភ្នាក់ងារជ្រើសឯកជនកម្ពុជា។ ជាមួយគ្នានេះដែរ តំណាងរដ្ឋាភិបាលនៃប្រទេសជប៉ុន បានអរគុណនូវការខិតខំប្រឹងប្រែងដោយមានកិច្ចសហការខ្ពស់ក្នុងការអនុវត្តគម្រោងពីគ្រប់ភាគីទាំងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សមាគមពលករកម្ពុជា ទីភ្នាក់ងារជ្រើសរើសកម្ពុជា សមាគម ឬស្ថាប័នទទួលនៃប្រទេសជប៉ុន និងកម្មសិក្សាការី-ពលករជំនាញជាដើម ដែលធ្វើឱ្យគម្រោងកម្មសិក្សាការី-ពលករជំនាញពីប្រទេសកម្ពុជា មានដំណើរល្អ និងកាន់តែកើនឡើងខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ។

ថ្លែងបិទកម្មវិធីសិក្ខាសាលានេះ ឯកឧត្តមប្រធានអង្គសិក្ខាសាលា បានថ្លែងអំណរគុណដល់តំណាងភាគីក្រសួងនៃប្រទេសជប៉ុន ដែលបានរៀបចំសិក្ខាសាលាដ៏មានសារៈសំខាន់នេះឡើង និងស្នើសុំឱ្យមានការសហការពីអ្នកចូលរួមទាំងអស់ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ពេលអនុវត្តគម្រោងបញ្ជូនកម្មសិក្សាការី និងពលករជំនាញ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងកម្មសិក្សាការី-ពលករជំនាញ ឱ្យបានកាន់ល្អប្រសើរថែមទៀត។

## ស្ថានទូតខ្មែរនៅថៃ៖ រាល់សេវាកម្មផ្ដល់ឯកសារ ពាក់ព័ន្ធពលករដែលស្លាប់នៅថៃ មិនមានគិតថ្លៃនោះឡើយ

http://www.freshnewsasia.com/ 2020-01-26

**(ភ្នំពេញ)៖** ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ បានចេញមកបញ្ជាក់ថា ការដាក់លិខិតយកសព ឬឯកសារទាមទារប្រាក់សំណង និងអត្ថប្រយោជន៍ផ្សេង សម្រាប់ពលករខ្មែរនៅថៃ ពេលមានគ្រោះថ្នាក់ការងារជាដើមនោះ មិនត្រូវបានគិតថ្លៃសេវាកម្មនោះឡើយ។ ការចេញមកបញ្ជាក់របស់ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ បានធ្វើឡើងបន្ទាប់ពីមានការផ្សព្វផ្សាយ និងពាក្យចចាមអារ៉ាមមួយចំនួននៅលើបណ្ដាញសង្គមហ្វេសប៊ុក និងសារព័ត៌មានមួយចំនួនថា ការផ្ដល់សេវាកម្មរបស់ស្ថានទូត បានយកថ្លៃសេវាកម្មលើឯកសារ ក្នុងការទាមទារប្រាក់សំណងពីសាច់ញាតិពលករ នៅពេលមានករណីពលករស្លាប់ និងគ្រោះថ្នាក់ការងារ។ ក្នុងសេចក្ដីប្រកាសព័ត៌មាននាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០កន្លងទៅនេះ ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ បានប្រានចោលការលើកឡើងទាំងនេះ និងចាត់ទុកជាការលើកឡើងផ្ទុយពីការពិត គ្មានមូលដ្ឋាន និងប្រឌិតកុហកបោកប្រាស់ទាំងស្រុង។

ស្ថានទូតបានអះអាងថា ការដាក់ពាក្យស្នើសុំលិខិតនាំយកសពទៅបូជា និងពាក្យស្នើសុំឯកសារផ្សេងៗ ដើម្បីទាមទារប្រាក់សំណង ឬអត្ថប្រយោជន៍ពេលមានគ្រោះថ្នាក់ការងារ ពីស្ថានទូតមិនមានគិតថ្លៃសេវាកម្មនោះឡើយ។ ក្នុងសេចក្ដីប្រកាសព័ត៌មាននេះ ស្ថានទូត ក៏បានបង្ហាញមុខ និងអត្តសញ្ញាណមន្ត្រីស្ថានទូតចំនួន១៦រូបផងដែរ ដើម្បីឱ្យពលករខ្មែរទាក់ទងទទួលសេវាកម្មផ្សេងៗ។ ស្ថានទូតបញ្ជាក់ទៀតថា បើជនណាទៅអះអាងផ្ដល់សេវាកម្មខុសពីមន្ត្រីទាំង១៦រូប ដែលបានបង្ហាញ គឺជាជនឆបោកហើយ។ នៅពេលមានអ្នកអះអាងជាមន្ត្រីស្ថានទូត ខុសពីមន្ត្រីដែលបានបង្ហាញអត្តសញ្ញាណទាំង១៦រូបនេះ ស្ថានទូតស្នើឱ្យពលករប្រញាប់ទាក់ទងរាយការណ៍

ជាបន្ទាន់ទៅកាន់ស្ថានទូត តាមរយៈលេខទូរស័ព្ទ ០៩៤ ០៩២ ៥៩០៥ និង ០៩២ ៨០៥០៥៦១ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់៕

## ពលករខ្មែរម្នាក់លង់ទឹកស្លាប់យ៉ាងអាណោចអាធ័ម

https://www.facebook.com/LabourOfficial/ 27-01-2020

ប្រភពពីខេត្តរ៉ាក់យ៉ង ប្រទេសថៃកាលពីថ្ងៃអាទិត្យ ទី២៦ ខែមករា ឆ្នាំ២០២០ម្សិលមិញនេះ បានអោយដឹងថាមានករណីបុរសពលករខ្មែរ ម្នាក់ ឈ្មោះ ភាន់ គេទប្រុស ២៧ឆ្នាំ បានលង់ទឹកស្លាប់បាត់បង់ជីវិត ដោយសារជនរងគ្រោះហែលទឹកទៅដាក់ម៉ងនៅក្នុងបឹងណងប៉ាឡែ ស្ថិតនៅក្នុងភូមិ៣ សង្កាត់ប៉ុកដែង ស្រុកប៉ុកដែង ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ហេតុការណ៍ខាងលើនេះកើតឡើងកាលពីវេលាម៉ោង ០៤ល្ងាច ថ្ងៃសៅរ៍ ទី២៥ ខែមករា ឆ្នាំ២០២០ ប៉ុន្តែសាកសពជនរងគ្រោះត្រូវបានសមត្ថកិច្ចជំនាញជើងទឹកថៃរាវរកឃើញនៅថ្ងៃអាទិត្យ ទី២៦ ខែមករា ឆ្នាំ២០២០។ បច្ចុប្បន្នសាកសពជនរងគ្រោះត្រូវបានសមត្ថកិច្ចបញ្ជូនយកទៅធ្វើកោសល្យវិច័យនៅមន្ទីរពេទ្យប៉ុកដែងរ៉ាក់យ៉ង មុនប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។

## ពលករខ្មែរចំណាកស្រុកមកពីខេត្តកំពង់ចាមជិត២០នាក់ ត្រូវថៅកែថៃមិនបើកប្រាក់ឈ្នួលឲ្យ

https://www.facebook.com/LabourOfficial/ 26-01-2020

ប្រភពពីខេត្តឈុនបុរី ប្រទេសថៃ នៅថ្ងៃអាទិត្យ ទី២៦ ខែមករា ឆ្នាំ២០២០នេះ បានអោយដឹងថា ពលករខ្មែរប្រុសស្រី ជិត២០នាក់ ធ្វើការសំណង់នៅក្នុងតំបន់ប៉ាតាយ៉ា ស្ថិតក្នុងស្រុកបាងឡាមុង ខេត្តឈុនបុរី ប្រទេសថៃ ត្រូវថៅកែម៉ៅការសំណង់ជាជនជាតិថៃ មិនព្រមបើកប្រាក់ឈ្នួលជូនពួកគាត់អស់រយៈពេលជាង ៣ខែមកហើយ ។ តាមការកញ្ជាក់ពីស្ត្រី ពលករខ្មែរម្នាក់ឈ្មោះ ជ័យ ស្រួយ អាយុ ៥៣ឆ្នាំ ស្រុកកំណើតរស់នៅ ភូមិអណ្តូងពេជ្យ ឃុំព្រៃកកក ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានរៀបរាប់អោយដឹងថា គាត់បានចំណាកស្រុកមកធ្វើការជាមួយថៅកែម៉ៅការសំណង់ខាងលើអស់រយៈពេលជាង ២ឆ្នាំមកហើយ ដោយទទួលបានប្រាក់ឈ្នួលធ្វើការ ជាង៣០០បាត ក្នុងមួយថ្ងៃ ។ ចាប់តាំងពីចុងឆ្នាំ២០១៩ មកថៅកែគាត់មិនបានបើកប្រាក់ឈ្នួលធ្វើការអោយគាត់នៅទេ ថៅកែបើកត្រឹមប្រាក់ខ្ចីសម្រាប់ទិញអាហារហូបចុកបណ្តោះអាសន្នប៉ុណ្ណោះ។

បច្ចុប្បន្នថៅកែម៉ៅការខាងលើបានប្តូរទីតាំងទៅធ្វើការនៅកន្លែងផ្សេង ដោយទុកគាត់អោយដេករងចាំនៅទីនេះទាំងស៊ីអត់ស៊ីឃ្លាន។ គាត់បានបន្ថែមទៀតថា ថៅកែនោះបានប្រាប់គាត់ថាគេមិនបានបោកពួកគាត់ទេ ប៉ុន្តែមិនដឹងបើកប្រាក់ឈ្នួលអោយនៅពេលណា គាត់ប្រាប់ថា ចាំថៅកែរកប្រាក់បានសិននឹងយកមកបើកជូន។ បច្ចុប្បន្នពលករខ្មែរដែលមិនបានទទួលប្រាក់ឈ្នួលទាំងអស់ បាននាំគ្នាវិលត្រឡប់ទៅស្រុកកំណើតវិញអស់មួយចំនួនធំហើយ នៅសល់តែគាត់ប្រមាណ ៧,៨នាក់ប៉ុណ្ណោះ។ ចំពោះរឿងប្តឹងផ្តល់ទាមទារអោយថៅកែបើកប្រាក់ឈ្នួលជូនគាត់ ធ្លាប់គិតថាទៅប្តឹងសមត្ថកិច្ចថៃដែរតែមិនហ៊ានប្រឈមនឹងថៅកែណាមួយអ្នករងគ្រោះផ្សេងទៀតមិនចូលរួមសហការប្តឹងថៅកែនេះ ដូច្នេះហើយទើបបណ្តោយឲ្យថៅកែនោះរត់គេចទៅធ្វើការកន្លែងផ្សេងទៀតបាត់ទៅ។

ក្នុងករណីនេះដែរបណ្តាញពលករខ្មែរនៅប្រទេសថៃ បានណែនាំនីតិវិធីច្បាប់ជម្រុញអោយពួកគាត់រួមសហការគ្នាដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចថៃ ដើម្បីទាមទារប្រាក់ឈ្នួលដែលគាត់ធ្វើការតាមចំនួន ប៉ុន្តែពួកគាត់មួយចំនួនមិនហ៊ានប្រឈម ដូច្នេះហើយក្រុមការងារបានផ្តល់លេខទូរស័ព្ទសម្រាប់គាត់ទំនាក់ទំនង នៅពេលណាមួយដែលគាត់ត្រូវការអោយក្រុមការងារជួយអន្តរាគមន៍ក្នុងការនាំទៅប្តឹងទាមទារប្រាក់ឈ្នួលតាមផ្លូវច្បាប់។ ក្រុមការងារបណ្តាញពលករខ្មែរនៅប្រទេសថៃ 26.01.2020

## ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២០

## ការដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា, ធានាបានការធ្វើទេសន្តរប្រវេសន៍ការងារ ការការពារសិទ្ធិ និងគាំទ្រដល់ពលករ

http://www.mlvt.gov.kh/ 29-01-2020

(ភ្នំពេញ)៖ ការដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាពិតជាមានសារៈសំខាន់ណាស់ដើម្បីធានាការធ្វើទេសន្តរប្រវេសន៍ការងាររបស់ពលករ ទទួលបានលទ្ធផលជោគជ័យ និងបទពិសោធន៍ជាវិជ្ជមាន ក៏ដូចជាទទួលបាននូវការការពារសិទ្ធិ និងគាំទ្រដល់ពួកគេក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន សម្រាប់ពលករផ្ទាល់ខ្លួន សមាជិកគ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល។ នេះជាប្រសាសន៍លើកឡើង របស់ឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងពិធីផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ដោយមានការគាំទ្រជំនួយបច្ចេកទេស និងកិច្ចសហប្រតិបត្តិការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងការងារ (ILO) សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) បានបោះពុម្ពក្រមសីលធម៌នេះឡើងដើម្បីផ្សព្វផ្សាយ និងបង្កើនការយល់ដឹង ស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត នាព្រឹកថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០ នៅសណ្ឋាគារ ភ្នំពេញ។

ឯកឧត្តម បណ្ឌិត អ៊ិត សំហេង ក៏បានលើកឡើងពីគោលនយោបាយរបស់ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លៀវឆ្លាសរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបាននាំកម្ពុជាទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សម្រេចបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងមួយឆ្នាំ កំណើនវិនិយោគិនទុន និងពាណិជ្ជកម្ម បានបង្កើតនូវការងារក្នុងស្រុកជូនប្រជាពលរដ្ឋប្រមាណជិត១០លាននាក់ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលក៏បានខិតខំបើកច្រកទីផ្សារការងារនៅបរទេសជូនបងប្អូនប្រជាពលរដ្ឋ ដើម្បីផ្តល់ឱកាសក៏ដូចជាជម្រើសជូនពួកគាត់ស្វែងរកការងារដែលពួកគាត់ពេញចិត្ត និងទទួលបានប្រាក់ឈ្នួលខ្ពស់ ហើយថែមទាំងបានដាក់ចេញនិងអនុវត្តនូវគោលនយោបាយ និងយន្តការគាំពារពលករទេសន្តរប្រវេសន៍ប្រកបដោយជោគជ័យ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការគាំពារ ការការពារសិទ្ធ និងផលប្រយោជន៍ពលករខ្មែរយើងនៅបរទេស តាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេស ទទួល និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋាននានាដោយប្រើប្រាស់គោលការណ៍ យន្តការ និងនីតិវិធីនានាផងដែរ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងខិតខំបន្តជម្រុញការអនុវត្ត នូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ពិសេសការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់ នៅក្រៅប្រទេស, ទប់ស្កាត់ទេសសន្តរប្រវេសន៍ការងារដោយខុសច្បាប់, លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ, កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្ត តាមរយៈការទទួលស្គាល់ជំនាញ, ការផ្ទេរបេបសន្តិសុខសង្គមមកក្នុងប្រទេស, ការផ្តល់ប្រឹក្សាការងារធ្វើ និង ការបង្កើតមុខរបរ ដោយខ្លួនឯង។ ក្រសួង បានបន្តខិតខំយកចិត្តទុកដាក់ដល់ពលករដែលធ្វើការនៅក្រៅប្រទេស និងពង្រីកទីផ្សារនៅក្រៅប្រទេស ដោយបន្តផ្តល់សេវា ៥យ៉ាង ជូនពលករកម្ពុជា នៅឯបរទេស៖

ទី១-អនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពី ការការពារនិងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។ បាន និងកំពុងខិតខំជួយពលករដែលធ្វើការនៅបរទេស ដើម្បីធានានូវផលប្រយោជន៍ស្របច្បាប់។ ជួយផ្តល់ភាពស្រប ច្បាប់ដល់ពលករដែលមិនស្របច្បាប់។ ចាត់តាំងទីប្រឹក្សាការងារនៅតាមស្ថានទូតនៃ ប្រទេសដែលមានពលករ ដូច ជាថៃ កូរ៉េ ម៉ាឡេស៊ី និងជប៉ុន។

ទី២-សហការជាមួយប្រទេសដៃគូ ក្នុងការទទួលស្គាល់ជំនាញទៅវិញទៅមក ដូចជាកម្ពុជា-ថៃ បានទទួល ស្គាល់ជំនាញផ្នែកសំណង់ ដូចជាជាងកំបោរ និងតបណ្តាញអគ្គិសនី។ នៅសាធារណរដ្ឋកូរ៉េ ផ្តល់ឱកាសឱ្យពលករ ទៅរៀនបន្ថែមនៅ តាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់។ បន្ទាប់ពី ត្រឡប់មក ប្រទេសកម្ពុជាវិញ អាចមានជំនាញច្បាស់លាស់។

ទី៣-កំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យរបបសន្តិសុខសង្គម

ទី៤-កំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធនិវត្តដោយពលករអាចផ្ទេរ សមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គម ពីប្រទេសមួយទៅប្រទេសមួយ បន្ទាប់ពីចប់កិច្ចសន្យាការងារ និងដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធនិវត្ត។

ទី៥-បានសម្រួលបែបបទជូនពលករធ្វើការនៅបរទេសអាចផ្ទេរសិទ្ធិជូនគ្រួសារនៅក្នុងប្រទេស ធ្វើជា តំណាង សម្រាប់ស្នើសុំធ្វើលិខិតថ្កោលទោស ឬលិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណបណ្ណផ្ទាល់ខ្លួន ដោយ មិនចាំបាច់សាមីខ្លួនវិលត្រឡប់មកស្រុកកំណើតវិញ។

គួសបញ្ជាក់ផងដែរថា បច្ចុប្បន្ន ប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសបានចំនួន៦ ប្រទេសគឺ ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន សឹង្ហបូរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់។ ហើយកន្លងមកពួកគាត់បានផ្ញើរថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ ពួកគាត់ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ។ នៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញ ពួកគាត់នឹងក្លាយជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពីព្រោះតាមរយៈ ការធ្វើការងារ នៅបរទេស ពួកគាត់មិនត្រឹមតែអាចរកប្រាក់ចំណូលបានបន្ថែមទេ ថែមទាំងទទួលបាននូវជំនាញ បទពិសោធន៍ ចំណេះដឹងភាសា និងរបៀបរបបរស់នៅក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង៕

## ក្រសួងសង្គមកិច្ចចុះកិច្ចព្រមព្រៀងជាមួយអង្គការ ១១ លើគម្រោងសុខុមាលភាពកុមារ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 27 January 2020 | 14:39 ICT

**ភ្នំពេញៈ** ក្រសួងសង្គមកិច្ចកាលពីថ្ងៃទី ២៤ ខែមករា បានចុះកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ១១ ក្នុង ទំហំថវិកាជាង ១២ លានដុល្លារ លើការអនុវត្តគម្រោងរយៈពេល ៣ ឆ្នាំ (២០២០-២០២២) ដើម្បីជួយដល់វិស័យ សង្គមកិច្ច សុខុមាលភាពសង្គម សុខុមាលភាពកុមារ ការប្រឆាំងការជួញដូរមនុស្ស និងការងារពិការភាព។

លោក តូច ចាន់នី អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស និងជាអ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធ ជន និងយុវនីតិសម្បទាបានថ្លែងប្រាប់ភ្នំពេញប៉ុស្តិ៍ កាលពីថ្ងៃអាទិត្យម្សិលមិញថា ការចុះហត្ថលេខាលើអនុស្សរណៈ នៃកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ១១ ក្នុងទំហំទឹកប្រាក់សរុប ១២ ៧២៤ ៧៤៥ ដុល្លារអាមេរិកដែលជាថវិកា របស់អង្គការក្រៅរដ្ឋាភិបាល និងប្រើប្រាស់ក្នុងរយៈពេល ៣ ឆ្នាំ (២០២០-២០២២) នេះ គឺដើម្បីជួយក្នុងវិស័យ សង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាដែលជាការងារស្នូលរបស់ក្រសួងសង្គមកិច្ចផងដែរ។ លោកថ្លែងថាៈ « ការចុះកិច្ចព្រមព្រៀងនេះ យើងបានផ្តោតទៅលើកិច្ចការងារសុខុមាលភាពសង្គម សុខុមាលភាពកុមារ ការងារ ប្រឆាំងការជួញដូរ និងការងារពិការភាពនៅទូទាំងប្រទេសកម្ពុជា។ ការចុះកិច្ចព្រមព្រៀងជាមួយអង្គការទាំង ១១ នេះក៏បានចូលរួមជួយការងាររបស់ក្រសួងយើងច្រើនលើការអភិវឌ្ឍគោលនយោបាយរបស់រដ្ឋាភិបាលផងដែរ»។

លោក តូច ចាន់នី បញ្ជាក់ថារហូតដល់បច្ចុប្បន្ន អង្គការដែលបានចូលរួមសហការជាមួយក្រសួងសង្គមកិច្ច ធ្វើការងារលើផ្នែកសុខុមាលភាពសង្គម សុខុមាលភាពកុមារ ការងារប្រឆាំងការជួញដូរ ការងារពិការភាព និងមុខសញ្ញាផ្សេងៗទៀតដែលជាគោលនយោបាយក្រសួងកំពុងអនុវត្តទូទាំងប្រទេសកម្ពុជា មិនមែនមានតែ ១១ អង្គការនោះទេ ប៉ុន្តែមានអង្គការប្រមាណជាង ១៣៤ អង្គការទៀតនៅទូទាំងប្រទេស។ ក្នុងនោះអង្គការទាំង ១៣៤ ក៏បានសហការជាមួយក្រសួងធ្វើការងារលើគ្រប់មុខសញ្ញារយៈពេល ៣ ឆ្នាំ (២០២០-២០២២) ដែលអង្គការទាំងនេះមានថវិកាប្រមាណ ១៥០ លានដុល្លារផងដែរ។ លោកបញ្ជាក់ថា៖ «អង្គការទាំង ១៣៤ ដែលមានថវិកាប្រមាណ ១៥០ លានដុល្លារអាមេរិកនេះបានជួយគាំទ្រដល់មុខសញ្ញាការងារ ដែលក្រសួងសង្គមកិច្ច ទទួលខុសត្រូវ និងចូលរួមបដិភាគជួយសង្គមជាមួយគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល»។

បើតាមរបាយការណ៍ក្រសួងសង្គមកិច្ច អង្គការចំនួន ១១ ដែលបានចុះកិច្ចព្រមព្រៀងកាលពីថ្ងៃទី ២៤ ខែមករារួមមាន ១- អង្គការសម្ព័ន្ធចាប់ដៃ ២- អង្គការក្តីសង្ឃឹម និងយុត្តិធម៌ ៣- អង្គការសកម្មភាពដើម្បីកុមារ ៤- អង្គការក្តីស្រឡាញ់គ្មានព្រំដែន ៥- អង្គការសង្គ្រោះ និងថែទាំអន្តរជាតិស៊ីជីកញ ៦- អង្គការសមាគមសហប្រតិបត្តិការកម្ពុជា ជប៉ុន ៧- អង្គការតំណក់ទឹក ៨- អង្គការបេសកកម្មជីវិតថ្មី ៩- អង្គការបុគ្គលសាវន្តកម្ពុជា ១០- អង្គការ Joy Fountain Foundation និង ១១- អង្គការ World Togethe Cambodia។

លោក តូច ចាន់នី លើកឡើងថា ការចូលរួមសហការរបស់អង្គការដៃគូពិតជាសំខាន់ណាស់ក្នុងការលើកកម្ពស់វិស័យសង្គមកិច្ចនៅកម្ពុជា។ ប៉ុន្តែលោកក៏បានស្នើឱ្យក្រុមការងារក្រសួង និងអង្គការដៃគូទាំងអស់គ្នាធ្វើការងារដោយយកចិត្តទុកដាក់ឱ្យខ្លាំងបំផុតតាមដែលអាចធ្វើបាន។ លោកថ្លែងថា ក្រសួងសង្គមកិច្ចនៅតែបន្តស្វាគមន៍ជាមួយដៃគូពាក់ព័ន្ធ ដើម្បីជួយដល់ជនរងគ្រោះ ងាយរងគ្រោះនៅកម្ពុជាឱ្យមានជីវភាព និងជីវិតរស់នៅល្អប្រសើរថែមមួយកម្រិតទៀត។ លោកបន្ថែមថា រាល់អង្គការដៃគូទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសូមធ្វើប្រតិបត្តិការទៅតាមលក្ខខណ្ឌហើយសុំធ្វើតែកិច្ចការការងារសង្គមតែប៉ុណ្ណោះ មិនត្រូវធ្វើការងារនយោបាយឡើយ ប្រសិនបើក្រសួងរកឃើញថា អង្គការណាមួយមិនបានគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង យកការងារសង្គមមកធ្វើជាការងារនយោបាយក្រសួងនឹងបញ្ចប់កិច្ចព្រមព្រៀងភ្លាមនឹងឈានដល់បញ្ឈប់សកម្មភាព។

លោក សំ សុវណ្ណរិទ្ធិ ប្រធានអង្គការតំណក់ទឹកថ្លែងកាលពីម្សិលមិញថា តាមរយៈគម្រោងរយៈពេល ៣ ឆ្នាំ ដែលសហការជាមួយក្រសួងសង្គមកិច្ចសម្រាប់អង្គការតំណក់ទឹកនឹងប្រើប្រាស់ថវិកាចំនួន ៩៥ ម៉ឺនដុល្លារដែលជាថវិកាជំនួយបានមកពីសហភាពអឺរ៉ុប និងអង្គការ unicef នឹងត្រូវយកទៅអនុវត្តក្នុងខេត្តចំនួន ៣ គឺខេត្តបន្ទាយមានជ័យ ខេត្តកែប និងខេត្តព្រៃវែង សម្រាប់គាំទ្រដល់ការសង្គ្រោះកុមារងាយរងគ្រោះពីការជួញដូរពិការភាពកុមារត្រូវគេបោះបង់ និងកុមារដែលក្រីក្រនៅក្នុងសហគមន៍។ លោកថ្លែងថា៖ «យើងនឹងផ្តល់សេវាថែទាំ និងការឧបត្ថម្ភដល់កុមារដែលរងគ្រោះដោយផ្តល់ការអប់រំការរស់នៅដល់ពួកគេរហូតដល់ពួកគេបញ្ចប់ការសិក្សា ឬទទួលបានជំនាញវិជ្ជាជីវៈរហូតពួកគេមានអាយុលើសពី ១៨ ឆ្នាំ ទើបយើងធ្វើសមាហរណកម្មឱ្យពួកគេត្រឡប់ទៅកាន់សហគមន៍ ឬគ្រួសាររបស់ពួកគេវិញ»។ លោក សុវណ្ណរិទ្ធិ បញ្ជាក់ថាបច្ចុប្បន្នអង្គការតំណក់ទឹកកំពុងថែទាំកុមាររងគ្រោះប្រមាណ ១ ពាន់នាក់ក្នុងខេត្តគោលដៅទាំង ៣ ខាងលើ។ បច្ចុប្បន្នអង្គការកំពុងបន្តតាមដាន និងពិនិត្យតាមខេត្តគោលដៅដើម្បីស្វែងរកជនរងគ្រោះដើម្បីផ្តល់សេវាថែទាំផងដែរ៕

# ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២០

## អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ប្រកាសជួយពង្រឹងសមត្ថភាពមន្ត្រីក្រសួងសង្គមកិច្ច និង ស្វែងរកជំនួយគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2020-01-29

**(ភ្នំពេញ)៖** ក្នុងជំនួបរវាងថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងនាយកអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ នាទីស្តីការក្រសួងសង្គមកិច្ច នាយកអង្គការ IJM បានប្រកាសជួយពង្រឹងសមត្ថភាពមន្ត្រីក្រសួងសង្គមកិច្ច និងស្វែងរកជំនួយគាំទ្រ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងចូលរួមស្វែងរកជំនួយ និងអ្នកឧបត្ថម្ភ ព្រមទាំងគាំទ្រលើគម្រោងអនាគតនៃការរបស់ក្រសួងសង្គមកិច្ច អំពីការសាងសង់មណ្ឌលស្តារនីតិសម្បទា នៅរាជធានីភ្នំពេញ។

កិច្ចជំនួបនាពេលនោះដឹកនាំដោយ លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាតំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានជួបពិភាក្សាការងារជាមួយ នាយកអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ជុំវិញទិសដៅការងារបន្ត ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

នៅក្នុងជំនួបនោះ នាយកអង្គការ IJM បានលើកឡើងថា អង្គការរបស់លោក នឹងជួយ ជំនួយគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងពង្រឹងសមត្ថភាពដល់មន្ត្រី នៃក្រសួងសង្គមកិច្ច និងចូលរួមស្វែងរកជំនួយ និងអ្នកឧបត្ថម្ភ ព្រមទាំងគាំទ្រលើគម្រោងអនាគតនៃការរបស់ក្រសួងសង្គមកិច្ច អំពីការសាងសង់មណ្ឌលស្តារនីតិសម្បទា នៅរាជធានីភ្នំពេញ។

ជាមួយគ្នានោះ លោក ញ៉ឹក វណ្ណារ៉ា បានទទួលស្វាគមន៍ លើការជួយរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) មកកាន់ប្រទេសកម្ពុជា។ លោក ញ៉ឹក វណ្ណារ៉ា រំពឹងថា ការជួយរបស់អង្គការ IJM នឹងកាន់តែធ្វើឲ្យវិស័យសង្គមកិច្ចនៅកម្ពុជា អាចចូលរួមចំណែក កាន់តែខ្លាំងថែមទៀត ក្នុងការជួយទៅដល់ជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

គួរបញ្ជាក់ថា រយៈពេលជាង១៥ឆ្នាំកន្លងមកនេះ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បានចូលរួមចំណែកធ្វើការងារមនុស្សធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈ តាមរយៈកិច្ចសហប្រតិបត្តិការល្អជាមួយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសអំពើជួញដូរពលកម្មនៅក្នុងស្រុក និង ឆ្លងដែនលើពលរដ្ឋកម្ពុជា។

ការបង្កើតគម្រោងជួយជាបន្តបន្ទាប់របស់ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ គឺធ្វើឡើងបន្ទាប់ពីពិនិត្យឃើញថា នៅតែមានជនរងគ្រោះដែលបន្តរងគ្រោះដោយអំពើជួញដូរ ៥ កម្លាំងពលកម្ម ជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចកម្លាំងពលកម្មជាដើម។គម្រោងនេះអនុវត្តនៅរាជធានីភ្នំពេញ និងមានវិសាលភាពគ្រប់ដណ្តប់ ២៥ រាជធានី-ខេត្ត៕

# ក្រសួងការងារ ប្រកាសឱ្យប្រើក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ដោយធានាថា នឹងពង្រឹងការពារសិទ្ធិពលករ

http://www.freshnewsasia.com/ 2020-01-29

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ដោយជឿជាក់ថានឹងធានាការធ្វើទេសន្តរប្រវេសន៍ ការងាររបស់ពលករ ទទួលបានលទ្ធផលជោគជ័យ និងបទពិសោធន៍ជាវិជ្ជមាន ក៏ដូចជាទទួលបាននូវការការពារសិទ្ធិពួកគេផងដែរ។ ការប្រកាសដាក់ឱ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជានេះ ត្រូវបានធ្វើឡើងក្រោមអធិបតីភាពលោក អ៊ិត សំហេង នាព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ នៅសណ្ឋាគារភ្នំពេញ។

ក្រមសីលធម៌នេះ គឺជាឧបករណ៍មួយដែលអាចអនុវត្តបានដោយទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាទាំងអស់ ដោយបានដាក់ចេញនូវគោលការណ៍គ្រឹះជាមូលដ្ឋានស្របតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាទាំងអស់អនុវត្តប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ និងគោរពក្រមសីលធម៌ខ្ពស់ក្នុងការគ្រប់គ្រងការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស។ ក្រមសីលធម៌នេះនឹងរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការការពារ ការលើកកម្ពស់សិទ្ធិការងារ ក៏ដូចជាសុខុមាលភាពរបស់ពលករទាំងនៅក្នុងស្រុក និងនៅបរទេស។ លើសពីនេះទៀត នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ប្រកបដោយគណនេយ្យភាពផង ហើយក៏ជាប្រភពដែលមានសារៈប្រយោជន៍ សម្រាប់ពលករទេសន្តរប្រវេសន៍អាចបញ្ជាក់បាន អំពីការរំពឹងទុករបស់ពលករពីទីភ្នាក់ងារជ្រើសរើសឯកជន ដែលទាក់ទងទៅនឹងបទពិសោធន៍ទេសន្តរប្រវេសន៍ការងាររបស់ពួកគេ។

តំណាងជាន់ខ្ពស់របស់អង្គការ ILO លោកស្រី Anna Engblom បានលើកឡើងថា ពិធីដាក់ឲ្យផ្សព្វផ្សាយក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជននៅកម្ពុជានាថ្ងៃនេះថា ផលប្រយោជន៍នឹងទទួលបានដល់ប្រទេសដែលបញ្ជូនទៅផង និងប្រទេសដែលជាគោលដៅទទួលផង។

ចំណែកលោក Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានលើកឡើងដែរថា ការដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា នៅពេលនេះ ពិតជាមានសារៈសំខាន់ណាស់ ហើយប្រទេសអូស្ត្រាលី ជាមួយប្រទេសជាសមាជិកអាស៊ានបានខិតខំលុបបំបាត់ពលករទេសន្តប្រវេសន៍ ដូចជា ការយកថ្លៃហួសហេតុ ការយកជំនួសកិច្ចសន្យា ពលកម្មដោយបង្ខំ និងការជួញដូរមនុស្សជាដើម។

**លោករដ្ឋមន្ត្រី អ៊ិត សំហេង បានបន្តថា ក្រសួងការងារបានបន្តខិតខំយកចិត្តទុកដាក់ដល់ពលករដែលធ្វើការនៅក្រៅប្រទេស និងពង្រីកទីផ្សារនៅក្រៅប្រទេស ដោយបន្តផ្តល់សេវា ៥យ៉ាង ជូនពលករកម្ពុជានៅឯបរទេស៖**

**ទី១៖** អនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពី ការការពារនិងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។ បាន និងកំពុងខិតខំជួយពលករដែលធ្វើការនៅបរទេស ដើម្បីធានានូវផលប្រយោជន៍ស្របច្បាប់។ ជួយផ្តល់ភាពស្របច្បាប់ដល់ពលករដែលមិនស្របច្បាប់។ ចាត់តាំងទីប្រឹក្សាការងារនៅតាមស្ថានទូតនៃ ប្រទេសដែលមានពលករ ដូចជាថៃ កូរ៉េ ម៉ាឡេស៊ី និងជប៉ុន។

**ទី២៖** សហការជាមួយប្រទេសដៃគូ ក្នុងការទទួលស្គាល់ជំនាញទៅវិញទៅមក ដូចជាកម្ពុជា-ថៃ បានទទួលស្គាល់ជំនាញផ្នែកសំណង់ ដូចជាជាងកំបោរ និងតបណ្តាញអគ្គិសនី។ នៅសាធារណរដ្ឋកូរ៉េ ផ្តល់ឱកាសឱ្យពលករទៅរៀនបន្ថែមនៅ តាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់។ បន្ទាប់ពី ត្រឡប់មកប្រទេសកម្ពុជាវិញ អាចមានជំនាញច្បាស់លាស់។

**ទី៣៖** កំពុងសហការជាមួយបណ្តាប្រទេសអាស៊ានក្នុងកិច្ចសហប្រតិបត្តិការលើវិស័យរបបសន្តិសុខសង្គម

**ទី៤៖** កំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធនិវត្តដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានរបបឡាសន្តិសុខសង្គម ពីប្រទេសមួយទៅប្រទេសមួយ បន្ទាប់ពីចប់កិច្ចសន្យាការងារ និងដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធនិវត្ត។

**ទី៥៖** បានសម្រួលបែបបទជូនពលករធ្វើការនៅបរទេសអាចផ្ទេរសិទ្ធិជូនគ្រួសារនៅក្នុងប្រទេស ធ្វើជាតំណាង សម្រាប់ស្នើសុំធ្វើលិខិតថ្កោលទោស ឬលិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណបណ្ណផ្ទាល់ខ្លួន ដោយមិនចាំបាច់សាមីខ្លួនវិលត្រឡប់មកស្រុកកំណើតវិញ។

គួសបញ្ជាក់ផងដែរថា បច្ចុប្បន្ន ប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសបានចំនួន៦ប្រទេសគឺ ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់៕

## ក្រសួងការងារ ជំរុញទីភ្នាក់ងារបញ្ជូនពលករបង្កើនកិច្ចគាំពារពលករនៅក្រៅប្រទេស

https://www.information.gov.kh/ មករា 29, 2020 ចេម ហួត វិទ្យុជាតិកម្ពុជា ៖ លោក អ៊ឹម ភិរក្សនារីរតនៈ

MC ៖ ក្រសួងការងារ ជំរុញឲ្យសមាគមភ្នាក់ងារបញ្ជូនពលករ បង្កើនកិច្ចគាំពារពលករកម្ពុជានៅក្រៅប្រទេសឲ្យកាន់តែមានភាពល្អប្រសើរដើម្បីធានាដល់សុខសុវត្ថិភាពនិងឧត្តមប្រយោជន៍របស់ពលករចំណាកស្រុក។ ថ្លែងក្នុងពិធីផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារជ្រើសរើសពលករឯកជនកម្ពុជា នៅព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ណែនាំឲ្យសមាគមន៍ ដែលបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសទាំងអស់ត្រូវបន្តខិតខំយកចិត្តទុកដាក់ និងជួយលើកកម្ពស់ការគាំពារសិទ្ធិនិងផលប្រយោជន៍សុខភាព សុវត្ថិភាពការងារ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ។ ឯកឧត្តមបណ្ឌិត បន្តទៀតថា រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការទប់ស្កាត់ទេសសន្តរប្រវេសន៍ការងារដោយខុសច្បាប់ ក្នុងការស្វែងរកការងារជូនដល់បងប្អូនប្រជាពលរដ្ឋធ្វើការងារនៅក្រៅប្រទេស ឲ្យទទួលបានប្រាក់ឈ្នួលខ្ពស់ ទទួលបាននូវជំនាញ បទពិសោធន៍ ចំណេះដឹងភាសានិងរបៀបរបបរស់នៅក្នុងប្រទេសអភិវឌ្ឍន៍ និងបានដាក់ចេញគោលនយោបាយ និងយន្តការគាំពារពលករទេសន្តរប្រវេសន៍ប្រកបដោយជោគជ័យ ។

សំលេង ៖ ក្នុងរយៈពេលជាមួយគ្នានេះដែរ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ស្នើដល់សមាគមទាំង២សហការគ្នាឲ្យបានស្អិតល្មួត និងសមាជិកទីភ្នាក់ងារជ្រើសរើសពលករទាំងអស់ ដោយធ្វើយ៉ាងណាផ្តល់នូវការការពារសុវត្ថិភាព សុខមាលភាពសង្គម ដល់ពលករធ្វើការនៅក្រៅប្រទេសឲ្យបានជាអតិបរមា ផ្តល់សេវាធានារ៉ាប់រងដល់ពលករ និងការធានាគ្រោះថ្នាក់ ឬការដោះស្រាយវិវាទរវាងនិយោជក ស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់រាជរដ្ឋាភិបាល ។

សូមបញ្ជាក់ថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនពលករទៅបម្រើការងារនៅក្រៅប្រទេសបានចំនួន៦ប្រទេសរួមមាន ៖ ទី១ ប្រទេសថៃ ទី២ សាធារណរដ្ឋកូរ៉េ ទី៣ ម៉ាឡេស៊ី ទី៤ ជប៉ុន ទី៥ សឹង្ហបូរី និងទី៦ ហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់ ជាពិសេសនៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញពួកគាត់នឹងក្លាយជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ ៕

## ជនបរទេសជាង១,៥០០នាក់ ស្មើ៦៣សញ្ជាតិ ត្រូវបានបណ្តេញចេញពីកម្ពុជាក្នុងឆ្នាំ២០១៩ ក្រោយរកឃើញប្រព្រឹត្តបទល្មើស

http://www.freshnewsasia.com/ 2020-01-30

**(ភ្នំពេញ)៖** ក្នុងឆ្នាំ២០១៩កន្លងទៅ ជនបរទេសចំនួន១,៥៣៣នាក់ ស្មើនឹង៦៣សញ្ជាតិ ត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជា ក្រោយកម្លាំងនគរបាលអន្តោប្រវេសន៍ឃាត់ខ្លួន ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស។ នេះបើតាមរបាយការណ៍ ដែលបានបង្ហាញក្នុងសន្និបាតបូកសរុប លទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងលើកទិសដៅបន្ត នៅព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

របាយការណ៍ដែលបានបង្ហាញទៀតថា ក្នុងចំណោមជនបរទេសដែលបានប្រព្រឹត្តបទល្មើស ហើយត្រូវបានបណ្តេញចេញពីកម្ពុជានេះ ច្រើនជាងគេគឺជនជាតិចិន ដែលមានចំនួន១,០១៣នាក់, ថៃ២២០នាក់, វៀតណាម ១៤៩នាក់, នីហ្សេរីយ៉ា៩៤នាក់, ឥណ្ឌា៣១នាក់, កូរ៉េខាងត្បូង២៥នាក់, អាមេរិក១៧នាក់។

បទល្មើសដែលជនបរទេសទាំងអស់នេះបានប្រព្រឹត្ត រួមមាន៖ ករណីជំរិតទារប្រាក់តាមប្រព័ន្ធ VOIP និងបទល្មើសហ្គេមអនឡាញចំនួន៨៩០នាក់ មាន០៩សញ្ជាតិ (ចិន តៃវ៉ាន់ ថៃ ហ្វីលីពីន ឥណ្ឌូនេស៊ី ឡាវ វៀតណាម ឥណ្ឌា និងម៉ាឡេស៊ី), ការស្នាក់នៅគ្មានលិខិតឆ្លងដែន ចំនួន២៤២នាក់ មាន៤០សញ្ជាតិ (នីហ្សេរីយ៉ា៦៧នាក់, វៀតណាម៤៣នាក់, ចិន២៩នាក់ និង៣៧សញ្ជាតិទៀតពីម្នាក់ ដល់១០នាក់), ការស្នាក់នៅលើសទិដ្ឋាការ ចំនួន ១២៦នាក់ មាន៣២សញ្ជាតិ (នីហ្សេរីយ៉ា ៤៩នាក់, ឥណ្ឌា១៣នាក់ និង៣០សញ្ជាតិទៀតពី ០១ដល់០៦នាក់) និងប្រើប្រាស់សារធាតុញៀនចំនួន២០០នាក់។

គួរជម្រាបថា គិតចាប់ពីបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ឆ្នាំ២០១៤ មកដល់ដំណាច់ខែធ្នូ ឆ្នាំ២០១៩ នេះ បានបណ្តេញចេញជនបរទេសខុសច្បាប់ចំនួន ១៦,៧២០នាក់ មាន ៩៦សញ្ជាតិ។

ទន្ទឹមនេះ ដើម្បីការពារជោគវាសនាពលរដ្ឋខ្មែរ ពីការបោកប្រាស់យកទៅជួញដូរធ្វើបាបនៅក្រៅប្រទេសនាឆ្នាំ២០១៩ តាមសំណើរបស់ក្រុមការងារ ច្រកចេញចូលតែមួយក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានបានពិនិត្យបញ្ជាក់សមាសភាពជនបរទេស ដែលបានស្នើសុំរៀបអាពាហ៍ពិពាហ៍ ជាមួយពលរដ្ឋខ្មែរចំនួន១,៩២៨នាក់ មាន៣៩សញ្ជាតិ និងបានឆ្លើយតបទាន់ពេលតាមការស្នើសុំ៕

## កម្ពុជាដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសពលករ ផ្តល់សារៈសំខាន់ដល់ពលករ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ម៉ោង ១៥:៣០ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ កម្ពុជាបានការដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ដែលមានសារៈសំខាន់ណាស់ ដើម្បីធានាការធ្វើទេសន្តរប្រវេសន៍ការងាររបស់ពលករទេសន្តប្រវេសន៍ ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងពិធីផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាបានលើកឡើងក្នុងពិធីប្រកាសឲ្យប្រើប្រាស់ក្រមនេះ នាព្រឹកថ្ងៃទី២៩ ខែមករានេះ នៅសណ្ឋាគារភ្នំពេញថា ក្រមនេះនឹងជួយពលករទទួលបានលទ្ធផលជោគជ័យ និងបទពិសោធន៍ជាវិជ្ជមានក៏ដូចជា ទទួលបាននូវការការពារសិទ្ធិ និងគាំទ្រដល់ពួកគេក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្នសម្រាប់ពលករផ្ទាល់ខ្លួនសមាជិកគ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល ។ លោកបន្តថា ក្រមសីលធម៌នេះ គឺជាឧបករណ៍មួយដែលអាចអនុវត្តបានដោយទីភ្នាក់ងារជ្រើសរើសឯក

ជនកម្ពុជាទាំងអស់ដោយបានដាក់ចេញនូវគោលការណ៍គ្រឹះ ជាមូលដ្ឋានស្របតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិសម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាទាំងអស់អនុវត្តប្រកបដោយប្រសិទ្ធភាពការទទួលខុសត្រូវ និងគោរពក្រមសីលធម៌ខ្ពស់ក្នុងការគ្រប់គ្រងការជ្រើសរើសការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស ។ លោកបន្ថែមថា ក្រមសីលធម៌នេះនឹងរួមចំណែកពង្រឹងប្រសិទ្ធិភាពនៃការការពារការលើកកម្ពស់សិទ្ធិការងារក៏ដូចជា សុខុមាលភាពរបស់ពលករទាំងនៅក្នុងស្រុក និងនៅបរទេស ។ លើសពីនេះទៀតនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាប្រកបដោយគណនេយ្យភាពផង ហើយក៏ជាប្រភពដែលមានសារៈប្រយោជន៍សម្រាប់ពលករទេសន្តប្រវេសន៍អាចបញ្ជាក់បានអំពីការរំពឹងទុករបស់ពលករពីទីភ្នាក់ងារជ្រើសរើសឯកជនដែលទាក់ទងទៅនឹងបទពិសោធន៍ទេសន្តប្រវេសន៍ការងាររបស់ពួកគេ ។

លោក អ៊ិត សំហេង ក៏បានលើកឡើងពីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លៀសវៃរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលបាននាំកម្ពុជាទទួលបាននូវសុខសន្តិភាពពេញលេញស្ថិរភាពនយោបាយសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧%ក្នុងមួយឆ្នាំកំណើនវិនិយោគិនទុន និងពាណិជ្ជកម្មបានបង្កើតនូវការងារក្នុងស្រុកជូនប្រជាពលរដ្ឋប្រមាណជិត១០លាននាក់ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលក៏បានខិតខំបើកច្រកទីផ្សារការងារនៅបរទេសជូនបងប្អូនប្រជាពលរដ្ឋ ដើម្បីផ្តល់ឱកាសក៏ដូចជាជម្រើសជូនពួកគាត់ស្វែងរកការងារដែលពួកគាត់ពេញចិត្ត និងទទួលបានប្រាក់ឈ្នួលខ្ពស់ ហើយថែមទាំងបានដាក់ចេញ និងអនុវត្តនូវគោលនយោបាយ និងយន្តការគាំពារពលករ ទេសន្តប្រវេសន៍ប្រកបដោយជោគជ័យ ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការគាំពារការការពារសិទ្ធ និងផលប្រយោជន៍ពលករខ្មែរយើងនៅបរទេសតាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេស ទទួល និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋាននានាដោយប្រើប្រាស់គោលការណ៍យន្តការ និងនីតិវិធីនានាផងដែរ ។ តំណាងជាន់ខ្ពស់របស់អង្គការ ILO លោកស្រី Anna Engblom បានលើកឡើងថា ពិធីដាក់ឲ្យផ្សព្វផ្សាយក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជននៅកម្ពុជានាថ្ងៃនេះថា ផលប្រយោជន៍នឹងទទួលបានដល់ប្រទេសដែលបញ្ជូនទៅផង និងប្រទេសដែលជាគោលដៅទទួលផង ។ ប្រទេសបញ្ជូននោះដូចជា ប្រទេសកម្ពុជា វាអាចកាត់បន្ថយភាពក្រីក្រ ចំណែកប្រទេសគោលដៅវិញអាចជួយដល់សកម្មភាពសេដ្ឋកិច្ច ផ្ទុយទៅវិញប្រទេសគោលដៅមិនអាចរីកចម្រើនបានឡើង បើសិនគ្មានការបញ្ជូនពលករទៅ ។

ចំណែកលោក Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជាបានលើកឡើងដែរថា ការដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជានៅពេលនេះពិតជាមានសារៈសំខាន់ណាស់ ហើយប្រទេសអូស្ត្រាលីជាមួយប្រទេសជាសមាជិកអាស៊ានបានខិតខំលុបបំបាត់ពលករទេសន្តប្រវេសន៍ដូចជា ការយកថ្លៃហួសហេតុ ការយកជំនួសកិច្ចសន្យា ពលកម្មដោយបង្ខំ និងការជួញដូរមនុស្សជាដើម ។ លោកសង្ឃឹមថា ពលករទេសន្តប្រវេសន៍អាចមានឱកាសចូលរួមនូវកម្លាំងពលកម្មប្រកបដោយអត្ថន័យ និងអាចផ្លាស់ទីដោយសេរីក្នុងតំបន់នេះ ដើម្បីច្បាមយកឱកាសការងារនៅពេលមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ។ម្យ៉ាងវិញទៀត ពលករទេសន្តប្រវេសន៍ក៏អាចចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស និងក្រុមគ្រួសារផងដែរ ។ លោកបញ្ជាក់ថា ៖«អូស្ត្រាលីសង្ឃឹមថា ក្រមសីលធម៌នេះ គឺជាឧបករណ៍ធានាយ៉ាងណាឲ្យទីភ្នាក់ងារជ្រើសរើសពលករអនុវត្តឲ្យបានត្រឹមត្រូវទៅតាមការចាំបាច់ និងលើកកម្ពស់សិទ្ធិពលករទេសន្តប្រវេសន៍លើសពីនេះទៀតវាក៏ជាឧបករណ៍ដ៏មានអនុភាពដល់ពលករដឹងពីអ្វីដែលពួកគេអាចទទួលបានពីទីភ្នាក់ងារជ្រើសរើសពលករផងដែរ» ។

## វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ លើស្ត្រី និងក្មេងស្រី

https://grandnewsasia.com/ 29-01-2020

កោះកុងៈ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ លោក ផៃធូន ផ្លាមកេសន អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង បានអញ្ជើញស្វាគមន៍ លោកស្រី ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី ក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ លើស្ត្រី និងក្មេងស្រី ដែលមានអ្នកចូលរួមសរុបចំនួន ៤២ នាក់ មកពីខេត្តកោះកុង ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តពោធិ៍សាត់។

លោកអភិបាលរងខេត្ត សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានលោកស្រីរដ្ឋលេខាធិការ និងសូមឱ្យអាជ្ញាធរមូលដ្ឋាន បានសហការចូលរួមទប់ស្កាត់ឱ្យបានល្អប្រសើរ និងមានផ្សព្វផ្សាយដល់ឃុំ សង្កាត់ ឱ្យបានទូលំទូលាយផងដែរ ហើយគណៈកម្មការថ្នាក់ខេត្ត ក៏បានយកចិត្តទុកដាក់ លើការងារស្ត្រី និងកុមារ និងគាំទ្រយ៉ាងពេញទំហឹងក្នុងការទប់ស្កាត់រាល់ករណីអំពើហិង្សាក្នុងគ្រួសារទូទាំងខេត្ត៕

## ក្រមសីលធម៌ការពារសិទ្ធិពលករត្រូវបានបង្កើត សម្រាប់ភ្នាក់ងារជ្រើសរើសឯកជន

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 30 January 2020 | 10:28 ICT

**ភ្នំពេញៈ** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រកាសគាំទ្រការដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនដែលរំពឹងថា ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់នៅកម្ពុជានឹងអនុវត្តឲ្យបានត្រឹមត្រូវ ខណៈបច្ចុប្បន្នកម្ពុជាបានបញ្ជូនពលករប្រមាណ ១ លាន ២ សែននាក់ ទៅកាន់ ៦ ប្រទេសតាមរយៈទីភ្នាក់ងាររដ្ឋ និងឯកជន។ កាលពីម្សិលមិញមានក្រុមហ៊ុនទីភ្នាក់ងារឯកជន និងមន្ត្រីរដ្ឋាភិបាលសង្គមស៊ីវិលប្រមាណជាង ១០០ នាក់ បានចូលរួមពិធីដាក់ឲ្យប្រើប្រាស់នូវក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជានៅសណ្ឋាគារភ្នំពេញដែលមានគោលការណ៍ចំនួន ១២ មាត្រារៀបចំដោយទីភ្នាក់ងារឯកជនចំនួន ២ គឺសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងក្នុងឱកាសនោះថា ក្រសួងការងារត្រៀមខ្លួនជានិច្ចសម្រាប់ផ្តល់ការគាំទ្រដល់ទីភ្នាក់ងារទាំងអស់ឲ្យអនុវត្តក្រមសីលធម៌នេះឲ្យបានពេញលេញប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីលើកកម្ពស់ និងការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូបទទួលបានសេវាយុត្តិធម៌ ខណៈកម្ពុជាមានច្បាប់ជាច្រើនសម្រាប់គ្រប់គ្រងរួចមកហើយ។ លោកបញ្ជាក់ថាៈ «ការរៀបចំឲ្យមានក្រមសីលធម៌នេះគឺជាការឆ្លើយតបមួយ ដែលផ្តើមចេញពីទីភ្នាក់ងារខ្លួនឯង សម្រាប់រំឭកខ្លួនឯងផ្ទាល់ចំពោះក្រមសីលធម៌នេះក្នុងការអនុវត្តដោយមានមនសិការត្រឹមត្រូវរបស់ខ្លួនក្នុងការប្រកបរបរដើម្បីរកកម្រៃផង និងគិតពីសិទ្ធិរបស់ពលករផង»។ លោក អ៊ិត សំហេង ថ្លែងថាបច្ចុប្បន្នប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសចំនួន ៦ ប្រទេសគឺប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី និងហុងកុងដែលមានពលករសរុបចំនួនប្រមាណ ១ លាន ២ សែននាក់ ដែលកន្លងមកពួកគាត់បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ប្រមាណជាង ២ ពាន់លានដុល្លារក្នុង ១ ឆ្នាំៗ។ ក្នុងនោះទីភ្នាក់ងារឯកជនដែលបានចុះបញ្ជីនៅក្រសួងការងារក្នុងការនាំពលករទៅធ្វើការនៅក្រៅប្រទេសមានចំនួន ១២០ ដែលពួកគេក៏បានរួមចំណែកក្នុងការធ្វើឲ្យប្រសើរឡើងចំពោះការនាំពលករកម្ពុជាទៅក្រៅប្រទេសនេះផងដែរ។

តាមសៀវភៅក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាបានឲ្យដឹងថា ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ត្រូវតែគោរព អនុវត្តច្បាប់ជាតិ និងអន្តរជាតិជាមូលដ្ឋាន ហើយត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព

ការទទួលខុសត្រូវ និងគោរពក្រមសីលធម៌ខ្ពស់ក្នុងការគ្រប់គ្រងការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេសធ្វើឲ្យមានសុវត្ថិភាព សេរីភាពនៃការបំផ្លាស់ទី ការពារសិទ្ធិពលករ។ សៀវភៅក្រមសីលធម៌ដដែលក៏បានកំណត់ឲ្យទីភ្នាក់ងារឯកជនទាំងអស់ គោរព និងអនុវត្តឲ្យមានតម្លាភាពក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម និងការផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវស្តីពីទេសន្តរប្រវេសន៍ ហើយក៏ត្រូវធ្វើជាទីភ្នាក់ងារមួយដែលចូលរួមកាត់បន្ថយថ្លៃចំណាយបន្ទាប់បន្សំ និងថ្លៃសេវារបស់ពលករក្នុងការធ្វើចំណាកស្រុកផងដែរ។

បើទោះជាក្រមសីលធម៌នេះមិនបានកំណត់ពីការដាក់ទណ្ឌកម្ម ប៉ុន្តែលោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានថ្លែងថា វានឹងចូលរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពសម្រាប់ទីភ្នាក់ងារទាំងអស់អាចអនុវត្តតាម និងទទួលខុសត្រូវចំពោះមុខច្បាប់។ លោកថា៖ «កន្លងទៅមានទីភ្នាក់មួយចំនួន អនុវត្តមិនបានត្រឹមត្រូវក្នុងការបញ្ជូនពលករទៅក្រៅប្រទេសទេ។ ក្រមសីលធម៌នេះនឹងជាឧបករណ៍អនុវត្ត និងជាឯកសារយោងសម្រាប់ប្រើប្រាស់នៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ទីភ្នាក់ងារជ្រើសរើសឯកជនក្នុងការជ្រើសរើស បណ្តុះបណ្តាល និងគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ»។

លោក ម៉ា ច័ន្ទស៊ីម អគ្គនាយកក្រុមហ៊ុននាំពលករទៅប្រទេសជប៉ុន Bridge JC Co,Ltd បានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា ក្រមសីលធម៌នេះអាចដើរតួនាទីក្នុងការគាំទ្រការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនឲ្យមានគណនេយ្យភាពក្នុងការប្រកួតប្រជែងស្របទៅតាមច្បាប់។ ប៉ុន្តែលោកផ្ទាល់មិនមានជំនឿ ១០០ ភាគរយនោះទេថា គ្រប់ទីភ្នាក់ងារទាំងអស់នឹងអាចអនុវត្តបានទាំងស្រុងតាមក្រមសីលធម៌នេះដែលទាមទារឲ្យក្រសួង និងស្ថាប័នពាក់ព័ន្ធយកចិត្តទុកដាក់បន្ថែមទៀត។ លោកបញ្ជាក់ថា៖ «ទីភ្នាក់ងារយើងអាចធ្វើតាមក្រមសីលធម៌នេះខ្លះៗ កន្លងមកហើយពេលនេះទីភ្នាក់ងារឯកជនអាចនឹងមិនអាចអនុវត្តបានទាំងស្រុងទៅតាមក្រមសីលធម៌នេះទេ ព្រោះវាថ្មីដោយត្រូវការពេលវេលាច្រើនទៀត»។

លោកស្រី Anna Engblom ប្រធានជាន់ខ្ពស់នៃកម្មវិធីត្រីកោណក្នុងតំបន់អាស៊ាន ILO បានថ្លែងដោយយោងតាមការស្រាវជ្រាវរបស់អង្គការ ILO ថា ការចំណាយរបស់ពលករទេសន្តរប្រវេសន៍ដើម្បីបានទៅធ្វើការនៅក្រៅប្រទេស នៅតែមានកម្រិតខ្ពស់ដែលអាចស្មើនឹងប្រាក់ខែដែលពួកគេទទួលបានចន្លោះពី ៩ ទៅ ១២ ខែ។ ដូច្នេះលោកស្រីនិយាយថា ក្រមសីលធម៌ថ្មីនេះក៏បានបញ្ញត្តិជុំវិញការកាត់បន្ថយថ្លៃចំណាយបន្ទាប់បន្សំ និងថ្លៃសេវារបស់ពលករក្នុងការធ្វើចំណាកស្រុកដែលផ្តើមចេញពីទីភ្នាក់ងារខ្លួនឯង។ លោកស្រីបានបញ្ជាក់ថា៖ «ក្រមសីលធម៌នេះអាចឲ្យទីភ្នាក់ងារខ្លួនឯង គ្រប់គ្រងខ្លួនឯង និងគោរពតាមគោលការណ៍ដែលបានចែងទុកដែលជាសមាជិកនៃទីភ្នាក់ងារទាំងអស់នៅកម្ពុជា។ ដើម្បីឲ្យក្រមសីលធម៌នេះ មានតម្លៃ យើងត្រូវតែមានប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃដែលយើងនឹងបង្កើតវានៅឆ្នាំក្រោយ»៕

## អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បង្ហាញចំនួនពលរដ្ឋខ្មែរដែលត្រូវបរទេសបញ្ជូនមកវិញ

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 13:27

គិតត្រឹមដើមឆ្នាំ២០២០ នេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានទទួលពលរដ្ឋខ្មែរ ដែលទៅធ្វើការដោយខុសច្បាប់នៅ ១៤ប្រទេស បានចំនួនជិត ១ម៉ឺន ៥ពាន់នាក់ បើធៀបទៅនឹងឆ្នាំ២០១៨ ថយចុះជាង ១ម៉ឺន ៧ពាន់ នាក់ស្មើនឹង ៥៣ ភាគរយ។ ការថ្លែងនេះនៅក្នុងកម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ នៅថ្ងៃទី ៣០ មករា នេះ នៅទីស្តីការក្រសួងមហាផ្ទៃ។

លោក ណុប វី អគ្គនាយកដ្ឋានរងអន្តោប្រវេសន៍ បានថ្លែងបញ្ជាក់ថា ពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរចំនួន ១៤ប្រទេសបញ្ជូនមកវិញនោះ រួមមានប្រទេសថៃ ១ម៉ឺន ៣ពាន់នាក់ ,ជប៉ុន ២០៥នាក់,ម៉ាឡេស៊ី ១៨២នាក់ , ចិន ១៤៧នាក់ ,កូរ៉េខាងត្បូង ១៤១នាក់ ,អាមេរិក ៧៧នាក់ និងប្រទេសវៀតណាម ៥២នាក់។

ទន្ទឹមនឹងនេះ ពលករខ្មែរចេញទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់តាមរយៈក្រុមហ៊ុនចំនួន ៤២ មានជាង៧ម៉ឺននាក់ ប្រៀបធៀបនឹងឆ្នាំ២០១៨ តិចជាងចំនួនជាង៣ម៉ឺននាក់ ស្មើ២៩,៣២%។អត្ថបទ៖ កុសល

## ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២០

### ឆ្នាំ២០១៩ ក្រសួងការបរទេស ជួយសង្គ្រោះពលរដ្ឋខ្មែរ រងគ្រោះដោយការជួញដូរ និងរំលោភបំពាន នៅក្រៅប្រទេសជាង ៣ម៉ឺននាក់

https://www.dap-news.com/ ByKD102 Posted on January 30, 2020

ភ្នំពេញ៖ លោក អ៊ុច បូរិទ្ធ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ នៃក្រសួងការបរទេសខ្មែរ បានលើឡើងថា ក្នុងឆ្នាំ២០១៩កន្លងទៅនេះ ក្រសួងបានជួយអន្តរាគមន៍សង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ជាពិសេសពលករខ្មែរ រងគ្រោះដោយការជួញដូរ និងការរំលោភបំពាននៅបរទេសចំនួន ៣៦.២៦២នាក់ ។

ក្នុងពិធីបើកសន្និបាតបូកសរុប លទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅបន្តសម្រាប់ឆ្នាំ២០២០ នៅថ្ងៃទី៣០ មករា លោក អ៊ុច បូរិទ្ធ បានមានប្រសាសន៍ថា ដើម្បីបន្តលើកកម្ពស់ផលប្រយោជន៍ និងកិត្យានុភាពជាតិ នៅឆ្នាំ២០២០នេះ កម្ពុជា ក៏បានត្រៀមខ្លួនជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំផ្សេងៗ ដូចជា "កិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុបលើកទី១៣" "កិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គ (GMS) លើកទី៧" * យុទ្ធសាស្រ្តសហប្រតិបត្តិការ សេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី – ចៅប្រាយ៉ា – មេគង្គ (ACMECS)" និងកិច្ចប្រជុំទៅតាមជំនាញផ្សេងៗទៀតជាច្រើន។ លោករដ្ឋលេខាធិការប្រចាំការបញ្ជាក់ថា "ទន្ទឹមនឹងនេះដែរ ក្រសួងតែងតែបាន យកចិត្តទុកដាក់ខ្ពស់ ក្នុងការការពារផលប្រយោជន៍ ពលរដ្ឋខ្មែរនៅបរទេស ដោយបានជួយអន្តរាគមន៍សង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ជាពិសេសពលករ ពលការិនីខ្មែរ ដែលរងគ្រោះដោយការជួញដូរ និងការរំលោភបំពាននៅបរទេសសរុប ៣៦.២៦២នាក់ ពីប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី វៀតណាម ឥណ្ឌូណេស៊ី និងចិន ជាដើម" ។ លោកបន្ថែមថា ក្រសួងបានចរចាជាមួយភាគីអាមេរិក រៀបចំអនុស្សារណៈយោគយល់គ្នាថ្មី ដើម្បីសម្របសម្រួលលក្ខខណ្ឌនៃ ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ មកពីអាមេរិក។ លោកគូសបញ្ជាក់ថា ក្រសួងក៏បានជួយដោះស្រាយបញ្ហាពលករ និងផ្ដល់សេវាកិច្ចការកុងស៊ុលនានា ទាន់ពេលវេលា និងមានប្រសិទ្ធភាពដល់ ពលរដ្ឋខ្មែរនៅបរទេស ៕

### ពលរដ្ឋខ្មែរជាងមួយម៉ឺននាក់ធ្វើការខុសច្បាប់នៅប្រទេសចំនួន១៤

http://www.rasmeinews.com/ January 30, 2020, 9:48 PM

*ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ* ប្រជាពលរដ្ឋខ្មែរជាងមួយម៉ឺននាក់ ទៅធ្វើការដោយខុសច្បាប់នៅប្រទេសចំនួន១៤ គិតត្រឹមដើមឆ្នាំ២០២០នេះ បើធៀបទៅនឹងឆ្នាំ២០១៨ ថយចុះជាង ១៧.០០០ នាក់ស្មើនឹង៥៣ភាគរយ។ នេះបើតាមរបាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ ដែលបានផ្សព្វផ្សាយនៅក្នុងកម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ កាលពីថ្ងៃទី៣០ មករា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ។

លោក ណុប វី អគ្គនាយកដ្ឋានរងអន្តោប្រវេសន៍ បានបញ្ជាក់ថា ពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរចំនួន១៤ ប្រទេសបញ្ជូនមកកម្ពុជាវិញមានដូចប្រទេសថៃ ១៣.០០០នាក់ ជប៉ុន ២០៥នាក់ ម៉ាឡេស៊ី ១៨២នាក់ ចិន ១៤៧ នាក់ កូរ៉េខាងត្បូង ១៤១នាក់ អាម៉េរិក ៧៧នាក់ និងប្រទេសវៀតណាម ៥២នាក់។ ទន្ទឹមនឹងនេះ ពលករខ្មែរចេញទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់តាមរយៈក្រុមហ៊ុនចំនួន ៤២ មានជាង ៧០.០០០នាក់ ប្រៀបធៀបនឹងឆ្នាំ២០១៨ តិចជាងចំនួនជាងបីម៉ឺននាក់ ស្មើ ២៩,៣២%។ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក៏បានដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេស បានចំនួនជិតបួន ម៉ឺនឯកសារ ក្នុងចំណោមជាងពីរម៉ឺនគ្រួសារ ដែលមានមនុស្សជិត៧ ម៉ឺននាក់ ភាគច្រើនគឺជាជនជាតិវៀតណាម។

គិតត្រឹមចុងឆ្នាំ២០១៩ កន្លងទៅនេះ បន្ទាប់ពីបិទឱសានវាទ នៃការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានទទួលពាក្យសុំប្រកាសទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន៍បានចំនួន ជាងបី ម៉ឺនគ្រួសារ ដែលមានមនុស្សជាងមួយសែននាក់ ក្នុងនោះ ក្រសួងបានចេញប្រកាសទទួលស្គាល់ជាជនអន្តោប្រវេសន៍ ចំនួនជាងពីរម៉ឺនគ្រួសារ ។

យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ បានឲ្យដឹងថា ជនបរទេសអន្តោប្រវេសន៍ក្នុងព្រះរាជាណាចក្រកម្ពុជាមានចំនួនជិតបីម៉ឺនគ្រួសារ ក្នុងចំណោម១១ សញ្ជាតិ ដែលមានមនុស្សជិតប្រាំបួនម៉ឺននាក់ ក្នុងនោះ សញ្ជាតិវៀតណាម មានចំនួន ជិតប្រាំបួនម៉ឺននាក់៕*សរន*

## ក្រសួងការបរទេស ជួយសង្គ្រោះពលរដ្ឋ និងពលករខ្មែរនៅបរទេសជាង៣ម៉ឺននាក់ ក្នុងឆ្នាំ២០១៩

http://www.freshnewsasia.com/ 2020-01-30

**(ភ្នំពេញ)៖** ប្រជាពលរដ្ឋខ្មែរ និងពលករខ្មែរ ដែលរងគ្រោះដោយសារការជួញដូរ និងការរំលោភបំពាននៅបរទេស ជាង៣ម៉ឺននាក់ ត្រូវបានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកវិញ នៅឆ្នាំ២០១៩ កន្លងទៅនេះ។

នេះបើយោងតាមរបាយការណ៍ ដែលត្រូវបានអានដោយ លោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការប្រចាំការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅក្នុងពិធីសន្និបាតសរុបការងារឆ្នាំ ២០១៩ និងទិសដៅឆ្នាំ២០២០ របស់ក្រសួងការបរទេស នៅព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០នេះ។ លោក អ៊ុច បូរិទ្ធ បានបញ្ជាក់យ៉ាងដូច្នេះថា៖ «ក្រសួងតែងតែបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស ដោយបានជួយអន្តរាគមន៍សង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ជាពិសេសពលករ-ពលការិនីខ្មែរ ដែលរងគ្រោះដោយការជួញដូរ និងការរំលោភបំពាននៅបរទេស សរុប៣៦,២៦២នាក់ ពីប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី វៀតណាម ឥណ្ឌូណេស៊ី និងចិនជាដើម»។ បើតាម លោករដ្ឋលេខាធិការ, រយៈពេលកន្លងមកនេះ កម្ពុជាតាមរយៈក្រសួងការបរទេស ថែមទាំងបានជួយដោះស្រាយបញ្ហាពលករ និងផ្តល់សេវាកិច្ចការកុងស៊ុលនានា ទាន់ពេលវេលា និងមានប្រសិទ្ធភាពដល់ពលរដ្ឋខ្មែរនៅបរទេសផងដែរ។

គិតមកដល់ពេលនេះ កម្ពុជាមានទំនាក់ទំនងការទូត ជាមួយប្រទេសចំនួន១៧៤ និងនៅលើពិភពលោក។ នេះបើតាមការបញ្ជាក់ពីលោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ដោយឡែកពាក់ព័ន្ធនឹងការបញ្ជូនពលករវិញ បច្ចុប្បន្នប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅប្រទេសចំនួន៦ រួមមាន ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់។ ពួកគាត់បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំ។៕

## សម្តេចក្រឡាហោម ស ខេង ផ្តល់អនុសាសន៍ ៩ចំណុច ដល់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រមូលផ្តុំអនុវត្តនៅឆ្នាំ២០២០

http://www.freshnewsasia.com/ 2020-01-30

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៩ និងទិសដៅបន្ត របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅរសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០នេះ បានដាក់ចេញនូវអនុសាសន៍ ចំនួន៩ចំណុចសំខាន់ៗ ដើម្បីអគ្គនាយកដ្ឋានប្រមូលផ្តុំអនុវត្តនៅឆ្នាំ២០២០។

**អនុសាសន៍ដែលបានដាក់ចេញដោយសម្តេចក្រឡាហោម ស ខេង ទាំង៩ចំណុចនោះរួមមាន៖**

*ទី១៖ បន្តជម្រុញការងារដោះស្រាយបញ្ហាអន្តោប្រវេសន្ត ដែលនៅសេសសល់ឲ្យបានចប់សព្វគ្រប់ តាមគោលការណ៍ដែលបានដាក់ចេញ និងត្រូវចាត់វិធានការ ដឹកនាំស្រាវជ្រាវត្រួតពិនិត្យជាប្រចាំគ្រប់មូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបទាន់ពេល មិនទុកឲ្យមានការលួចជ្រៀតចូលមកស្នាក់នៅបន្តបន្ទាប់ ដែលអាចធ្វើឲ្យកើតមានបញ្ហាប្រឈមសារជាថ្មីបាន។ ត្រូវជម្រុញការផ្តល់លិខិតស្នាមដល់ជនអន្តោប្រវេសន្ត ដែស្ថិតក្នុងក្របខណ្ឌ បញ្ជីស្នាមពេលបិទឱសានវាទឲ្យបានគ្រប់ៗគ្នា ព្រមជាមួយនោះត្រូវមានកម្មវិធីដឹកនាំ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ឲ្យយកចិត្តទុកដាក់គ្រប់គ្រងហ្មត់ចត់ក្នុងភូមិសាស្ត្រទទួលខុសត្រូវនីមួយៗ រាប់ទាំងការត្រួតពិនិត្យហ្មត់ចត់វត្តមានស្នាក់នៅ ការផ្លាស់ប្តូរលំនៅដ្ឋាន ការបន្តសុពលភាពបណ្ណស្នាក់នៅ និងការមកធ្វើបណ្ណស្នាក់នៅពេលគម្រប់អាយុ ១៨ឆ្នាំផងដែរ។

*ទី២៖ ត្រូវបន្តលើកកម្ពស់តួនាទីជាកងកម្លាំងជួរមុខរបស់ប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ និងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិទាំងអស់ ក្នុងការបង្ការ រារាំងសមាសភាពអាក្រក់ មិនទុកឲ្យមានលទ្ធភាពយកកម្ពុជាធ្វើជាទីជម្រក ដើម្បីលាក់ខ្លួនចាត់តាំងសកម្មភាពភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ឬគេចពីសំណាញ់ច្បាប់ នៅប្រទេសក្រៅ។

*ទី៣៖ ត្រូវមានវិធានការគ្រប់គ្រងវត្តមានស្នាក់នៅរបស់ជនបរទេសនៅក្នុងផ្ទៃក្នុងប្រទេស ឲ្យបានហ្មត់ចត់ ដើម្បីម្យ៉ាងធានាដល់ការងារស្រាវជ្រាវស៊ើបអង្កេត និងការតម្រង់ទិសឲ្យបានជាប្រយោជន៍សម្រាប់ជាតិ និងម្យ៉ាងដើម្បីមានវិធានការការពារសុវត្ថិភាពពួកគេ ជាជនបរទេសបានសមស្របផងដែរ។

*ទី៤៖ ត្រូវបន្តយកចិត្តទុកដាក់ជម្រុញសកម្មភាព អធិការកិច្ចហត្ថពលករបរទេសឲ្យកាន់តែមានប្រសិទ្ធភាព សំដៅកាត់បន្ថយជាអតិបរមា នូវការលួចប្រើកម្លាំង ពលកម្មបរទេស ដោយមិនបង់អាករ និងរួមចំណែករក្សាទីផ្សារការងាររបស់ប្រជាពលរដ្ឋខ្មែរ។ ត្រូវកំណត់គោលដៅមានពលករបរទេសឲ្យបានអស់ ហើយខិតខំធ្វើ អធិការកិច្ចឲ្យបានកាន់តែសកម្ម និងត្រូវពិចារណាដាក់ចេញផែនការត្រួតពិនិត្យឲ្យបាននៅតាមទីតាំងអាជីវកម្មខ្នាតតូច ចល័តអាជីវកម្មលើផ្ទៃទឹក លើកោះ និងតាមដំបន់ដាច់ស្រយ៉ាល ឬព្រំដែន ដើម្បីរឹតបន្តឹងការអនុវត្តច្បាប់ ស្តីពីការងារឲ្យមានប្រសិទ្ធិភាព។

*ទី៥៖ ត្រូវប្រមូលផ្តុំ តាមដានសភាពការណ៍ប្រែប្រួលនៅក្នុងតំបន់ ក៏ដូចជាអន្តរជាតិទាក់ទងនឹងចលនាបម្លាស់ទី និងចលនាជនភៀសខ្លួនឲ្យបានជាប្រចាំ ដើម្បីដាក់ចេញនូវវិធានការសមស្របទាន់ពេលវេលា ក្នុងការទប់ស្កាត់ និងដោះស្រាយប្រកបដោយការឈ្លាសវៃនូវលំហូរអ្នកសុំសិទ្ធិជ្រកកោន ឬជនភៀសខ្លួនមកកាន់កម្ពុជា សំដៅជៀសវាងបាននូវការចោទប្រកាន់ពីអន្តរជាតិ និងធានាបាននូវក្នុងការកម្រិតមួយសមស្រប សម្រាប់ស្ថានភាពរបស់ប្រទេសយើង។ ត្រូវខិតខំគ្រប់គ្រងឲ្យបានហ្មត់ចត់សកម្មភាពជនភៀសខ្លួន និងការសុំសិទ្ធិជ្រកកោនដែលមានបច្ចុប្បន្ន និងខិតខំបញ្ចប់បញ្ហាជនម៉ុងតាញ៉ា ២៧នាក់ ដែលនៅសេសសល់។

*ទី៦៖ យោងតាមនិន្នាការរីកចម្រើន និងសំណូមពរចាំបាច់ នៃការងារអន្តោប្រវេសន៍ សម្តេចយល់ថា ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ គឺជាវិញ្ញាសាដ៏មានសារៈសំខាន់ ដែលត្រូវគិតគូរធ្វើឲ្យមានការវិវឌ្ឍល្អប្រសើរស្របតាមតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចាំបាច់ត្រូវខិតខំពង្រឹង និងពង្រីក មន្ត្រីដែលមានសមត្ថភាព I.T បង្កើនការបណ្តុះបណ្តាលជំនាញ និងសិក្សាស្រាវជ្រាវ ដើម្បីពង្រីកប្រព័ន្ធដែលមានស្រាប់ និងរៀបចំឲ្យទៅជាបណ្តាញតភ្ជាប់ (Networking) ដែលអាចក្លាយជាស្តង់ដាប្រើប្រាស់សម្រាប់គ្រប់ផ្នែកជំនាញ។

*ទី៧៖ តាមរបាយការណ៍បូកសរុបបានបង្ហាញថា ឆ្នាំកន្លងទៅនេះ មានការលេចឡើងគួរចាប់អារម្មណ៍ នូវបាតុភាពប្រព្រឹត្តបទល្មើសផ្សេងៗ និងការលួចស្នាក់នៅ ហួសរយៈពេលកំណត់ រយៈពេលវែងរបស់ជនបរទេសជាមួយនឹងការលួចជ្រៀតចូលមកស្នាក់នៅធ្វើការ ដោយគ្មានលិខិតស្នាម ក្នុងនោះមានមួយចំនួនបានបង្កសកម្មភាពបំផ្លាញទ្រព្យសម្បត្តិ បង្កអសន្តិសុខ បាត់សណ្តាប់ធ្នាប់នៅតាមទីប្រជុំជន និងរមណីយដ្ឋានផងដែរ។

ក្នុងនាមក្រសួងមហាផ្ទៃ សម្តេចស្នើអគ្គនាយកដ្ឋាន និងលោកស្នងការនគរបាលរាជធានី-ខេត្ត ទាំងអស់ចាំបាច់ត្រូវបង្កើនសកម្មភាពស្រាវជ្រាវស៊ើបអង្កេត ឲ្យបានសកម្មថែមទៀត ដើម្បីបោសសម្អាត ដោះស្រាយកុំឲ្យបាតុភាពអវិជ្ជមាននេះកើតមាន រំខានដល់ដំណើរការវិវឌ្ឍដ៏ល្អ នៃខឿនសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមនៃយើង ក្នុងនោះត្រូវយកចិត្តទុកដាក់កំណត់គោលដៅ គ្រប់គ្រងស្រាវជ្រាវ និងត្រូវមានវិធានការតាមនីតិវិធីម៉ឺងម៉ាត់ចំពោះជនបរទេសល្មើសច្បាប់ និងត្រូវបណ្តេញចេញផុតពីកម្ពុជា។

*ទី៨៖ ស្នើឲ្យពង្រឹងជាប្រចាំនូវតួនាទីរបស់ក្រុមប្រឹក្សាវិន័យគ្រប់លំដាប់ថ្នាក់ និងត្រូវចាត់តាំងកម្មវិធីលើកសរសើរ ជូនរង្វាន់ចំពោះមន្ត្រីមានស្នាដៃ និងដាក់វិន័យចំពោះមន្ត្រីមានកំហុសឲ្យបានម៉ឺងម៉ាត់។

*ទី៩៖ ស្នើដល់មន្ត្រីច្រកទ្វារព្រំដែនគ្រប់រូប ត្រូវសហការល្អជាមួយភ្នាក់ងារក្រសួងសុខាភិបាល ដើម្បីបង្កលក្ខណៈងាយស្រួល ឲ្យពួកគាត់បានបំពេញភារកិច្ចនៅទីនោះ។ ជាមួយនោះក៏ត្រូវយកចិត្តទុកដាក់ប្រុងប្រយ័ត្នការឆ្លងមេរោគមកកាន់ខ្លួនឯងផងដែរ៕

## យុទ្ធនាការ«១00កោដិសំឡេង» បំផុសស្មារតីឲ្យគ្រប់គ្នាបញ្ចប់ហិង្សាលើស្ត្រីនិងក្មេងស្រី ធ្វើនៅកំពង់ស្ពឺ

https://thmeythmey.com/ 30, Jan 2020 , 7:11 pm ដោយ: ផាត ដាណេ

ភ្នំពេញ៖ ខណៈដែលស្ត្រី និងក្មេងស្រីកម្ពុជា ក៏ទទួលរងនូវការរំលោភបំពានទាំងផ្លូវកាយ និងសតិអារម្មណ៍ ក្នុងចំណោមស្រី៣០០លាននាក់នៅទូទាំងពិភពលោក ទើបអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) រៀបចំកម្មវិធីបោះជុំរុំ១០០កោដិសំឡេងក្រោមប្រធានបទ«សំឡេងរួម កម្លាំងរួម ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី»។ យុទ្ធនាការនេះ នឹងប្រព្រឹត្តនៅថ្ងៃទី១-២ ខែកុម្ភៈខាងមុខ នៅវិទ្យាល័យ ជាស៊ីមឱរ៉ាល់ ដែលស្ថិតនៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

លោក ម៉េត រ៉ូពី អ្នករៀបចំកម្មវិធីនេះ បានឲ្យដឹងថា ការប្រារព្ធយុទ្ធនាការ ១០០កោដិសំឡេង ដើម្បីបំផុសស្មារតីដល់មនុស្សគ្រប់គ្នាឲ្យបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីនេះ គឺដោយសារកន្លងមកធ្លាប់មានស្ត្រី១០០លាននាក់ ក្នុងចំណោមស្ត្រី៣០០លាននាក់ បានជួបបញ្ហាអំពើហិង្សាក្នុងគ្រួសារ, ការរំលោភបំពានផ្លូវភេទ, ការរំលោភសិទ្ធិ ហើយក៏ដូចជារូបភាពនៃអំពើហិង្សា ឬការរំលោភបំពានផ្សេង ក្នុងនោះក៏មានស្ត្រី និងក្មេងស្រីកម្ពុជាទទួលរងនូវបញ្ហានេះផងដែរ។ គោលបំណងសំខាន់នៃកម្មវិធីបោះជុំរុំ ដែលមានអ្នកចូលរួម១០០នាក់ ដោយមាន៦០នាក់ជាស្ត្រីនេះ ត្រូវបានអ្នករៀបចំកម្មវិធីបញ្ជាក់ថា គឺផ្តោតសំខាន់ទៅលើយុវជន ជាពិសេសនិស្សិត ដើម្បីឲ្យពួក

គាត់យល់ដឹងអំពីបញ្ហាអំពើហិង្សា និងការរំលោភបំពាន ក៏ចូលរួមផ្សព្វផ្សាយឲ្យមានភាពទូលំទូលាយដល់ពលរដ្ឋកម្ពុជាផងដែរ។

សូមរម្លឹកថា យុទ្ធនាការ «១០០កោដិសំឡេង» របស់អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) បានបង្កើតឡើងតាំងពីឆ្នាំ២០១២ រហូតមកដល់ពេលបច្ចុប្បន្ន ពោលគឺបានរយៈពេល៨ឆ្នាំហើយ។ តាំងពីចាប់ផ្តើម រហូតដល់ឆ្នាំ២០១៨ យុទ្ធនាការនេះធ្វើឡើងតែនៅទីក្រុងភ្នំពេញប៉ុណ្ណោះ។ ប៉ុន្តែ នៅឆ្នាំ២០១៩ អង្គការបានប្រារព្ធធ្វើនៅស្រុកបាភ្នំ ក្នុងខេត្តព្រៃវែង ហើយនៅដើមឆ្នាំ២០២០នេះ នឹងធ្វើនៅវិទ្យាល័យជាស៊ីមឱរ៉ាល់ នៃ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ នៅថ្ងៃទី១-២ កុម្ភៈខាងមុខនេះ៕

## ក្មេងស្រី៣នាក់ ត្រូវបានជួយសង្គ្រោះពីការជួញដូរទៅប្រទេសថៃ, អភិបាលខេត្តប៉ៃលិន ជំរុញមន្ត្រីជំនាញទាំងអស់ ត្រូវរួមសហការគ្នាទប់ស្កាត់រាល់អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ

http://freshnewsasia.com/ 2020-01-31

**(ប៉ៃលិន)៖** ក្នុងឱកាសអញ្ជើញជួបសួរសុខទុក្ខ ក្មេងស្រីដែលរងគ្រោះដោយសារចាញ់បោកជនខិលខូចយកទៅលក់នៅប្រទេសថៃ នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ នៅមណ្ឌលគ្រួសារខេត្តប៉ៃលិន លោក ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន បានជំរុញមន្ត្រីជំនាញដែលពាក់ព័ន្ធទាំងអស់ ត្រូវរួមសហការគ្នាទប់ស្កាត់ឲ្យបានដាច់ខាត នៅគ្រប់រូបភាព គ្រប់ទីកន្លែង ចំពោះការឆបោកដែលឈាន ដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ គឺចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ និងបង្ក្រាបឲ្យបានទាន់ពេលវេលា ព្រោះថា អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសាកលដែលនៅតែបន្តកើតមាន អាស្រ័យដោយកត្តាសំខាន់៣ គឺការអប់រំសង្គម ការអនុវត្ត ច្បាប់ នឹងការឆក់ឪកាសពីជនល្មើស។

អភិបាលខេត្ត ក៏បានណែនាំក្មួយស្រីទាំង ៣នាក់ ដែលបានរំដោះរួចផុតពីការបោកប្រាស់របស់ជនខិលខូច ហើយពេលត្រលប់ទៅស្រុកកំណើតវិញ ត្រូវមានការប្រុងប្រយ័ត្ន កុំឱ្យចាញ់បោកគេទៀត និងត្រូវ ខិតខំរៀន សូត្រ យកចំនេះជំនាញ តាមរយៈការគាំទ្រពីមន្ទីរកិច្ចការនារីខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទាខេត្ត និងអង្គការឧបត្ថម្ភគ្រួសារកម្ពុជា ដែលជាគ្រូបង្គោល ដើម្បីយកចំនេះដឹង ជំនាញយកទៅអនុវត្ត ប្រកបមុខរបរចិញ្ចឹមជីវិត និងបង្កើនសេដ្ឋកិច្ចគ្រួសារទាំងមូលអោយបានការរីកចំរើនជាបន្តបន្ទាប់។

លោកស្រី ចន្ទ ថាវី ប្រធានមន្ទីរកិច្ចការនារីខេត្តប៉ៃលិន បានឱ្យដឹកថា៖ ក្មេងស្រីរងគ្រោះទាំង០៣នាក់នេះ ត្រូវបានជនខិលខូចលួងលោម យកទៅលក់ឱ្យថៅកែនៅប្រទេសថៃ ដោយឆ្លងកាត់តាមច្រកស្រុកកំរៀង ហើយត្រូវបានសមត្ថកិច្ចស្រុកកំរៀងឃោតខ្លួន បន្ទាប់មកសមត្ថកិច្ចស្រុកកំរៀង ក៏បានប្រគល់ជនរងគ្រោះឲ្យមកស្នាក់នៅមណ្ឌលគ្រួសារខេត្តប៉ៃលិន ដើម្បីធ្វើការប្រគល់ជនរងគ្រោះជូនដល់ឪពុកម្តាយត្រលប់ទៅផ្ទះរៀងៗខ្លួនវិញ។

សូមបញ្ជាក់ថា៖ ក្មេងស្រីរងគ្រោះទាំង ០៣នាក់រួមមាន៖ ទី១/ឈ្មោះ ឈ.ភ អាយុ១៨ឆ្នាំ រស់នៅស្រុកកំពងត្រាច ខេត្តកំពត ទី២/ឈ្មោះ ភ.គ.រ អាយុ១៨ឆ្នាំ រស់នៅស្រុងកំពងត្រាច ខេត្តកំពត និងទី៣ ឈ្មោះ ធ.ស.ន អាយុ១៤ឆ្នាំ រស់នៅស្រុកកំរៀង ខេត្តបាត់ដំបង៕

## ពលករខ្មែរធ្វើការសំណង់០១នាក់ ដេកស្លាប់ដោយមិនដឹងមូលហេតុ

https://www.facebook.com/ បណ្ដាញពលករខ្មែរ 30-01-2020

ប្រភពពីខេត្តរ៉ាក់យ៉ងប្រទេសថៃ នៅថ្ងៃព្រហស្បតិ៍ ទី៣០ ខែមករា ឆ្នាំ២០២០នេះបានអោយដឹងថា មានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ ថៃ និត ភេទប្រុស អាយុ ៣៩ឆ្នាំ ស្រុកកំណើតរស់នៅ ភូមិតាហ៊ើលក ឃុំរាធរ ស្រុកព្រះសម្ដេច ខេត្តព្រៃវែង បច្ចុប្បន្នជាពលករចំណាកស្រុកមកធ្វើការសំណង់នៅក្នុងតំបន់និគមផាត់ណា ស្ថិតក្នុងខេត្តរ៉ាក់យ៉ង ប្រទេសថៃ រយៈពេលជាង ១ឆ្នាំ បានដេកស្លាប់ នៅក្នុងបន្ទប់ស្នាក់នៅក្នុងការដ្ឋានសំណង់មួយកន្លែងកាលពីវេលាម៉ោង០៣ទៀបភ្លឺ នាយប់ថ្ងៃពុធ ទី២៩ ខែមករា ឆ្នាំ២០២០ម្សិលមិញនេះ។

ប្រភពពីស្ត្រីជាប្រពន្ធ ឈ្មោះ ចាន់ ស្រី អាយុ ៣៤ឆ្នាំ បានប្រាប់(ក្រុមការងារបណ្ដាញពលករខ្មែរ)អោយដឹងថា សាកសពប្ដីគាត់ត្រូវបានរៀបចំធ្វើបុណ្យសពតាមប្រពៃណី នៅក្នុងវត្តមួយក្បែរកន្លែងធ្វើការនៅក្នុងថ្ងៃព្រហស្បតិ៍ ទី៣០ ខែមករា ឆ្នាំ២០២០នេះដោយខាងភាគីក្រុមហ៊ុនសំណង់ជាម្ចាស់ដើមបុណ្យសពពលករខ្មែរខាងលើនេះ។ ក្នុងនោះដែរខាងភាគីក្រុមហ៊ុនសំណង់បានឧបត្ថម្ភថវិកាដល់គ្រួសារសព ចំនួន៥០.០០០បាត ក្រៅពីរៀបចំបុណ្យសព នេះបើតាមការអះអាំងរបស់សាច់ញាតិម្នាក់ដែលធ្វើការជាមួយ។